# ធម៌នមស្ការព្រះបរមសារីរិកធាតុ

# និង ព្រះពោធិព្រឹក្ស



- បោះពុម្ពផ្សាយ
- ដើម្បីធ្វើជាធម្មទាន
- វត្តគិរីរតនៈ  ១៥កើត ខែ អស្សុជ ឆ្នាំច
- សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៨

**ចំណងជើងសៀវភៅ**

**ព្រះត្រៃសូត្រស្គាំវត្តគិរីរតនៈ**

១. ភិក្ខុបណ្ឌិតបញ្ញោ **វៃញ៉ម ប៊ុនដង**

**អ្នកវាយកុំព្យូទ័រ**

*១. គ្រូភាសាបាលី* ***ឈុំ នាយស្មេន***

*២. លោកម្ចាស់* ***នឿន វ៉ាណន***

*(និស្សិតសកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច UME)*

**កែប្រែអត្ថបទ ទំហំអក្សរ**

**ពុម្ពអក្សរ**

❖ *ដោយលោកម្ចាស់* ***នឿន វ៉ាណន***

**ត្រួតពិនិត្យអត្ថបទ**

*១.ព្រះភិក្ខុ* ***ហុក សេងហុង***

បោះពុម្ពផ្សាយ

ដើម្បីធ្វើជាធម្មទាន

វត្តគិរីរតនៈ ១៥កើត ខែ អស្សុជ ឆ្នាំច

សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៨

# អារម្ភកថា

សៀវភៅនេះឈ្មោះថា **ធម៌នមស្ការព្រះបរមសារីរិកធាតុ** និង **ព្រះពោធិព្រឹក្ស ។ លើកទី ២** ដែលរៀបចំដោយខ្ញុំព្រះករុណាអាត្មាភាព ជាព្រះសង្ឃស្នាក់នៅក្នុងវត្តគិរីរតនៈ និងញាតិញោមពុទ្ធបរិស័ទចំណុះជើងវត្ត បាននឹកឃើញដល់គុណព្រះរតនត្រៃ ហើយក៏បានរៀបចំចងក្រងជាសៀវភៅនមស្ការសូត្របែបជាពាក្យកាព្យនេះឡើង ។ដើម្បីចែកជា ធម្មទានដល់ ពុទ្ធសាសនិកជន យកទៅសិក្សាស្វាធ្យាយនូវព្រះធម៌របស់បណ្ឌិតដែលមានព្រះសម្មាសម្ពុទ្ធជាដើម ដែលចាស់ព្រឹទ្ធាចារ្យលោកបានចងក្រងទុកមកដល់សព្វថ្ងៃនេះ ។ ម្យ៉ាងវិញទៀត ការរៀបចំសៀវភៅនេះ ប្រសិនបើមានការខុសឆ្គាំឆ្គង ដោយអក្ខរាវិរុទ្ធ ឬការសរសេរភ្លេចភ្លាំងដោយប្រការណា សូមមេត្តាខន្តីអភ័យទោសចំពោះកំហុសឆ្គងនេះផងដោយសារអត្ថបទនេះពេលវេលាមិនអំណោយផលគឺខ្ញុំព្រះករុណាអាត្មាភាព មិនបានពិនិត្យមើលឲ្យបានហ្មត់ចត់ទៅលើអក្ខរាវិរុទ្ធឲ្យបានសព្វគ្រប់នោះទេ ។ ដូច្នេះហើយ សូមលោកអ្នកប្រាជ្ញ បណ្ឌិត អត្ថកោវិទ ជួយពិនិត្យគិតលៃសេចក្តីតាមអត្ថន័យ បំបាត់កំហុសឆ្គងដោយជួយកែអក្ខរាឬអត្ថបទផងចុះ ។

ជាចុងក្រោយខ្ញុំព្រះករុណា សូមប្រមូលនូវកងការមហាកុសលដែលកើតអំពីធម្មទាន និង អាមិសទាន ដែលខ្ញុំព្រះករុណាបានធ្វើហើយកន្លងមក ប្រគេនដល់ព្រះករុណាគុណម្ចាស់គ្រប់អង្គ និង ញាតិញោមទាំងឡាយ ឲ្យជួបតែពុទ្ធពរទាំងឡាយបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

*ថ្ងៃ ១៥កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨*
*ធ្វើនៅវត្តគិរីរតនៈ ស្រុកកំរៀង ខេត្តបាត់ដំបង*

# មាតិកា

ថ្ងៃបូជាដែលសំខាន់ៗជាងគេនៅក្នុងព្រះពុទ្ធសាសនា........................................ ១
ពុទ្ធភាសិត.................................................................................... ២
បទសរភញ្ញ និងនមស្ការ..................................................................... ៣
រតនត្តយវន្ទនគាថា............................................................................ ៤
នមស្ការព្រះពុទ្ធគ្រប់ព្រះអង្គ ................................................................ ៤

# នមស្ការព្រះរតនៈត្រៃ

ព្រះរតនត្រ័យ.................................................................................. ៥
ថ្វាយផ្កាព្រះរតនត្រៃ ........................................................................... ៥
ពាក្យវេរប្រទីបថ្វាយចំពោះព្រះរតនត្រ័យ ..................................................... ៦
នមស្ការ(ឧបមា)............................................................................... ៧
រតនត្តយបូជា .................................................................................. ៧
ពុទ្ធរតនប្បណាម .............................................................................. ៨
ធម្មរតនប្បណាម ............................................................................. ១១
សង្ឃរតនប្បណាម............................................................................ ១៤
បណាមគាថា(យោកប្បកោដី)............................................................. ១៧
នមស្ការបូជនីយវត្ថុជាទីគោរព ............................................................ ២០
ពុទ្ធបាទនមស្ការគាថា ..................................................................... ២១

ឈ្មោះធម៌ បញ្ជីមាតិកាធម៌ ទំព័រ

ពាក្យសូមខមាទោសព្រះរតនត្រ័យ ........................................ ២២

ពាក្យថ្វាយខ្លួន ........................................ ២៣

វិធីសមាទានសីល ៥ ........................................ ២៣

នមោ ៣ (ចប់) ........................................ ២៥

បណាមគាថា(បាលីវេយ្យាករណ៍) ........................................ ២៦

សុខាភិយាចនគាថា ........................................ ២៧

ពុទ្ធបាទនមស្ការ ........................................ ២៨

បារមី-៣០ ........................................ ២៩

ពុទ្ធជយមង្គល ........................................ ៣១

ពុទ្ធកិច្ច ៥ យ៉ាង ........................................ ៣៤

រក្សាព្រះត្រៃបិដក ........................................ ៣៥

វិសាខបូជា ........................................ ៣៦

ជយឃោស ........................................ ៣៨

ជយបរិត្តគាថា ........................................ ៣៩

ធម៌សុខោ ........................................ ៤០

## ធម៌បទផ្សេងៗ

បទលើកទង់ព្រះពុទ្ធសាសនា ........................................ ៤១

បទដាក់ទង់ព្រះពុទ្ធសាសនា ........................................ ៤១

| ឈ្មោះធម៌ | បញ្ជីមាតិកាធម៌ | ទំព័រ |
|---|---|---|


អត្ថន័យទង់ព្រះពុទ្ធសាសនា ........................................ ៤២

ធម្មនិយាម ៣០ ........................................ ៤៣

គោតមប្រវត្តិ ........................................ ៤៦

បទព្រហ្មអារាធនាធម៌ទេសនា ........................................ ៤៨

អារាធនាធម្មកថិកសម្តែងធម៌ទេសនា ........................................ ៤៩

សរសើធម៌ទេសនា ........................................ ៤៩

ពុទ្ធប្បវត្តិសង្ខេប ........................................ ៥០

គុណរបស់ទាន ........................................ ៥១

ហេតុនាំឲ្យកើតបុណ្យមាន៣យ៉ាង ........................................ ៥១

សេចក្តីត្រិះរិះរបស់នាងវិសាខា ........................................ ៥២

ចែកបុណ្យដល់ទេវតា ........................................ ៥២

ពុទ្ធសាសនាសូមតាំងនៅយូរអង្វែង ........................................ ៥២

ថ្ងៃពេញបូណ៌មីនៃព្រះគោតម ........................................ ៥៣

ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ ........................................ ៥៤

ទង់ព្រះពុទ្ធសាសនា ........................................ ៥៤

អនុមោទនារក្ខាយាចនគាថា ........................................ ៥៥

បុរាណភាសិត ........................................ ៥៦

ធាតុចេតិយនមស្ការគាថា ........................................ ៥៧

# វិធីបវរណា(ប្រាក់ ធម៌ឧទ្ទិសផ្សេងៗ)និងពាក្យទេរ


វិធីបវរណារូបិយៈ(ប្រាក់) ........................................................... ៦១

មហាផល ៩ យ៉ាង ........................................................... ៦២

ធញ្ញជាតិបានដល់ស្រូវ ៧ ប្រភេទគឺ ........................................................... ៦៣

សមណកប្ប ........................................................... ៦៣

កិច្ចក្នុងវិន័យ ........................................................... ៦៤

អង្គនៃការប្រគេន ៥ យ៉ាង ........................................................... ៦៤

ភិក្ខុធ្វើការចែកសប្បិរបស់សង្ឃ ........................................................... ៦៥

ភិក្ខុធ្វើការចែកចង្ហាន់បិណ្ឌបាត ........................................................... ៦៦

សាច់ទាំង១០យ៉ាង ........................................................... ៦៦

រំលឹកគុណព្រះពុទ្ធ ........................................................... ៦៨

អានិសង្សអង្គសីល ........................................................... ៦៩

ធម៌ឧទ្ទិសទាន ........................................................... ៦៩

សុមង្គលកថា ........................................................... ៧០

យំកិញ្ចិ ........................................................... ៧០

បត្តិទានគាថា ........................................................... ៧១

ឥមិនាបុញ្ញកម្មេ ........................................................... ៧៣

យំកិញ្ចិ(ប្រែកាព្យ) ........................................................... ៧៤

យំកិញ្ចិមួយបែបទៀត ......................................................................... ៧៥

វេរកឋិនទាន ......................................................................... ៧៥

ពាក្យវេរសេនាសនៈថ្វាយ ......................................................................... ៧៦

ពាក្យវេរបិណ្ឌបាតថ្វាយចំពោះព្រះសង្ឃ ......................................................................... ៧៧

ការវេរសង្ឃទាន ......................................................................... ៧៧

បូជាព្រះបរមសារីរិកធាតុ ......................................................................... ៧៨

ចែកព្រះបរមសារីរិកធាតុ ......................................................................... ៧៨

ចេតិយ របស់ព្រះពុទ្ធជាម្ចាស់ចែកចេញជា ៤យ៉ាង ......................................................................... ៨០

ការផ្សាយមេត្តាទៅកាន់ទិសទាំង១០ ......................................................................... ៨០

ការផ្សាយមេត្តាចិត្តដល់សព្វសត្វ ......................................................................... ៨២

អធិដ្ឋានកថា ......................................................................... ៨៤

## ពុទ្ធប្បវត្តិ

ពុទ្ធកាលប្បវត្តិសង្ខេប ......................................................................... ៨៤

-រាជវង្ស កំណើត ......................................................................... ៨៤

-ពិធីថ្វាយព្រះនាម ......................................................................... ៨៦

-រាជពិសេក ......................................................................... ៨៦

-និមិត្ត៤យ៉ាង ......................................................................... ៨៧

-សាងផ្នួស ......................................................................... ៨៩

| ឈ្មោះធម៌ | បញ្ជីមាតិកាធម៌ | ទំព័រ |
|---|---|---|


-ធ្វើទុក្ករកិរិយា ........................................ ៩០

-ត្រាស់ដឹង ........................................ ៩១

-ផ្ចាញ់មារ ........................................ ៩២

-បឋមទេសនា ........................................ ៩៥

-ពុទ្ធកិច្ច ........................................ ៩៦

-ដាក់ព្រះជន្ម ........................................ ៩៦

-បរិនិព្វាន ........................................ ៩៧

ព្រះបឋមឧទាន ........................................ ៩៨

មជ្ឈិមពុទ្ធវចនៈ ........................................ ៩៩


## របៀបសំពះ


របៀបសំពះខ្មែរ ........................................ ៩៩

១.សំពះកម្ពស់ត្រឹមដើមទ្រូង ........................................ ៩៩

២.សំពះកម្ពស់ត្រឹមមាត់ ........................................ ៩៩

៣.សំពះកម្ពស់ត្រឹមចុងច្រមុះ ........................................ ១០០

៤.សំពះកម្ពស់ចិញ្ចើម ........................................ ១០០

ឧទ្ទិសកថា ........................................ ១០០

បរាភវសូត្រ ........................................ ១០២

សន្លឹកប្រាប់ពាក្យខុសត្រូវ ........................................ ១០៨

# ធម៌នមស្ការព្រះបរមសារីរិកធាតុ

# និង ព្រះពោធិព្រឹក្ស



រៀបរៀងដោយ

ភិក្ខុបណីតបញ្ញោ ញ៉ែម ប៊ុនដន

# ថ្ងៃបូជាដែលសំខាន់ៗជាងគេនៅក្នុងព្រះពុទ្ធសាសនា

**ថ្ងៃបូជាដែលសំខាន់ៗជាងគេនៅក្នុងព្រះពុទ្ធសាសនាមាន៣គឺៈ**

១.ថ្ងៃ ១៥កើត ខែអាសាធ

២.ថ្ងៃ ១៥កើត ខែមាឃ

៣.ថ្ងៃ ១៥កើត ខែពិសាខ

**១.ថ្ងៃ១៥កើត ខែអាសាធ មានចំណុចសំខាន់៥យ៉ាងដែលយើងគួរតែគោរពគួរតែរលឹក គួរតែបូជាគឺៈ**

ជាថ្ងៃដែលព្រះអង្គចុះចាប់បដិសន្ធិ ។

ជាថ្ងៃដែលព្រះអង្គយាងចេញសាងព្រះផ្នួស ។

ជាថ្ងៃដែលព្រះអង្គទ្រង់សម្ដែងបឋមទេសនា ។

ជាថ្ងៃដែលព្រះអង្គទ្រង់សម្ដែងយមកប្បាដិហារ្យ ។

**២.ថ្ងៃ ១៥កើត ខែមាឃ មានចំណុចសំខាន់៥ សម្រាប់ការបូជាគឺៈ**

-ជាថ្ងៃដែលព្រះសារីបុត្រ(សាវ័កស្ដាំ) បានសម្រេចធម៌ជាន់ខ្ពស់ ។

-ជាថ្ងៃដែលព្រះអង្គប្រជុំសាវ័កសន្និបាតប្រកបដោយអង្គ៤ ។

-ជាថ្ងៃមាឃនក្ខត្តឫក្ស គឺព្រះចន្ទភ្លឺច្បាស់ល្អ ។

-ជាថ្ងៃភិក្ខុសង្ឃចំនួន ១២៥០អង្គ មកប្រជុំគ្នាដោយមិនបានណាត់ទុកជាមុន។ ភិក្ខុទាំងនោះសុទ្ធតែជាព្រះអរហន្តខីណាស្រពជាឯហិភិក្ខុ ។

-ជាថ្ងៃដែលព្រះអង្គសំដែងនូវឱវាទបាតិមោក្ខ ។

-ជាថ្ងៃដែលទ្រង់ទទួលការអារាធនារបស់មារចូលបរិនិព្វាន(៣ខែក្រោយ)

**៣.ថ្ងៃ ១៥កើត ខែពិសាខ មានចំណុចសំខាន់៧យ៉ាងសម្រាប់ការគោរពបូជាគឺៈ**

- ជាថ្ងៃដែលព្រះអង្គបានទទួលការព្យាករណ៍ថា នឹងបានត្រាស់ដឹងជាព្រះពុទ្ធនៅពេលដែលព្រះអង្គជាព្រះពោធិសត្វ(សុមេធបណ្ឌិត)

-ជាថ្ងៃដែលព្រះអង្គប្រសូត ។

-ជាថ្ងៃដែលព្រះពោធិព្រឹក្សដុះឡើង ។

-ជាថ្ងៃដែលព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ។

-ជាថ្ងៃដែលព្រះអង្គទ្រង់សម្ដែងនូវឱវាទចុងក្រោយបង្អស់ ។

-ជាថ្ងៃដែលព្រះអង្គទ្រង់យាងចូលបរិនិព្វាន ។

-ជាថ្ងៃដែលព្រះធាតុបរិនិព្វាន(នឹងមានក្នុងអនាគត)

ពុទ្ធបរិស័ទ កាលបើបានដល់ថ្ងៃបូជាទាំងបីនេះហើយ គួរធ្វើកុសលបីប្រការគឺៈ ការឲ្យទាន ការរក្សាសីល និងចម្រើនភាវនាឲ្យពិសេសជាប្រក្រតី ព្រោះថា កុសលបីប្រការនេះ ជាការបដិបត្តិតាមលោកុត្តរធម៌ ។

## ពុទ្ធភាសិត

**អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ**
**សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។**

បើបុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា គប្បីធ្វើខ្លួនយ៉ាងនោះ ទាល់តែទូន្មានខ្លួនល្អសិន សឹមទូន្មានអ្នកដទៃ លោកថាខ្លួនហ្នឹងហើយដែលបុគ្គលទូន្មានបានដោយក្រ ។

**យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ**
**កល្យាណការី កល្យាណំ បាបការី ច បាបកំ ។**

អ្នកធ្វើអំពើល្អ រមែងបានផលល្អ អ្នកធ្វើអំពើអាក្រក់រមែងបានផលអាក្រក់ដូចបុគ្គលសាបព្រោះពូជបែបណា រមែងបានផ្កាផ្លែបែបនោះ ។

**អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ**
**ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ ។**

នរជនណាឲ្យរបស់ដ៏លើស ឲ្យរបស់ដ៏ល្អ ឲ្យទីឋានដ៏ប្រសើរ នរជននោះទៅកើតក្នុងភពណាៗ រមែងជាអ្នកមានអាយុវែងមានយសបរិវារ(ក្នុងភពនោះៗ) ។

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ**
**អសមាហិតោ ឯកាហំ ជីវិតំ**
**សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

បុគ្គលណាមួយឥតប្រាជ្ញា មានចិត្តមិនតាំងមាំទោះបីរស់នៅអស់រយនៃឆ្នាំពុំប្រសើរស្មើការរស់នៅមួយថ្ងៃរបស់អ្នកមានប្រាជ្ញាមានឈានហើយ

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា**

**អប្បមាទេន សម្បាទេថ ។**
ភិក្ខុទាំងឡាយណ្ហើយចុះ ឥឡូវតថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយមានសេចក្ដីសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ។ ដូច្នេះឈ្មោះថា “**បច្ឆិមពុទ្ធវចនៈ**”។

# បទសរភញ្ញ និងនមស្ការ

(*បទនិពន្ធរបស់សម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ* **ជួន ណាត**)

១-សូមថ្វាយបង្គំ ព្រះសម្ពុទ្ធ ប្រសើរបំផុត ក្នុងលោកា
ជាគ្រូនៃមនុស្ស និងទេព្ដា ទ្រង់ត្រាស់ទេសនា ប្រដៅសត្វ ។
ចង្អុលឲ្យដើរ ផ្លូវកណ្ដាល មាគ៌ាត្រកាល អាចកម្ចាត់
ទុក្ខភ័យចង្រៃ ឲ្យខ្ចាយបាត់ អាចកាត់សង្សារៈ ទុក្ខបាន ។
២-សាសនាព្រះអង្គ នៅសព្វថ្ងៃ សត្វមាននិស្ស័យ ពីបុរាណ
ប្រឹងរៀនប្រឹងស្ដាប់ ចេះចាំបាន កាន់តាមលំអាន បានក្ដីសុខ ។
ឥតមានសុខណា ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ តទៅមុខ ក្ដីសុខនឹងមាន ព្រោះធម៌ស្ងប់ ។
៣-ខ្ញុំសូមបង្គំ ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរ ទាំងគ្រប់សព្វ
រួមជាត្រៃរតន៍ គួរគោរព ជាម្លប់ត្រជាក់ នៃលោកា ។
ព្រះរូបព្រះធាតុ នៃព្រះពុទ្ធ វិសុទ្ធតាងអង្គ ព្រះសាស្ដា
សូមគុណត្រៃរតន៍ ជួយខេមរា ឲ្យបានសុខា តរៀងទៅ ។

*អរហត្តផលឈ្នះកិលេស ប្រាជ្ញចេះយូរទៅឈ្នះពួកល្ងង់*
*សន្តិភាពយូរឈ្នះសង្គ្រាមផង ធម៌ល្អឥតហ្មងឈ្នះអាក្រក់ ។*

# រតនត្តយវន្ទនគាថា

(គាថានមស្ការព្រះរតនត្រ័យ)

## នមត្ថុ រតនត្តយស្ស

កិរិយានមស្ការនៃខ្ញុំព្រះករុណា សូមមានចំពោះប្រជុំបីនៃវត្ថុជាគ្រឿងត្រេកអរ របស់ពួកជនអ្នកត្រូវការនិព្វាន ។

**អរហំ សម្មាសម្ពុទ្ធោ ភគវា** ព្រះមានព្រះភាគព្រះអង្គឆ្ងាយចាកកិលេសហើយ ត្រាស់ដឹងនូវព្រះធម៌ទាំងពួង ដោយប្រពៃនិងព្រះអង្គឯង,**ពុទ្ធំ ភគវន្តំ អភិវាទេមិ** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ហើយ ។

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះធម៌ដែលព្រះមានព្រះភាគសម្តែងប្រពៃហើយ

**ធម្មំ នមស្សាមិ** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ ។

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ **សង្ឃំ វន្ទាមិ** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសង្ឃ ។

## នមស្ការព្រះពុទ្ធគ្រប់ព្រះអង្គ

(ប្រែសម្ពុទ្ធេ)

-ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ២៨ព្រះអង្គផងមួយម៉ឺន២ពាន់ព្រះអង្គផង ដោយត្បូង(របស់ខ្ញុំព្រះករុណា) ។

-ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ៥៥ព្រះអង្គផង២ម៉ឺន៤ពាន់ព្រះអង្គផង ១លានព្រះអង្គផង ដោយត្បូង(របស់ខ្ញុំព្រះករុណា) ។

-ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១០៩ព្រះអង្គផង៤ម៉ឺន ៨ពាន់ព្រះអង្គផង ២លានព្រះអង្គផង ដោយត្បូង(របស់ខ្ញុំព្រះករុណា) ។

-ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ** ដោយអានុភាពនៃកិរិយានមស្សការថ្វាយបង្គំ សូមកម្ចាត់បង់នូវឧបទ្រព

ទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសទៅកុំបីមានសេសសល់ឡើយ ។

## ព្រះរតនត្រ័យ

ព្រះរតនត្រ័យ វិសេសថ្លៃបីប្រការ
ដែលមនុស្សនិងទេវតា តែងបូជាគ្រប់ទីឋាន ។
ទីមួយព្រះសម្ពុទ្ធ បញ្ញាមុតអនន្តញាណ
ព្រះធម៌ទុកដូចជាយាន នាំសត្វបានជាទីពីរ ។
ព្រះសង្ឃបរិសុទ្ធ វិសេសផុតល្វង់ឥន្រ្ទីយ៍
ជួយអង្គព្រះមុនី គ្រប់ទិសទីជាទីបី ។
អ្នកដល់រតនត្រ័យ ផុតទុកភ័យមានសិរី
ចាប់តាំងពីលោកីយ៍ រៀងដរាបដល់និព្វាន ។
កុំគប្បីប្រមាទ ត្រូវសង្វាតខំសូត្ររៀន
ធម៌អាថ៌ព្រះទ្រង់ញាណ កុំបីខានគ្រប់ៗគ្នា ។
នាំគ្នាបដិបត្តិ រៀងរាល់រត្តិន្ទិវា
ជោគជ័យសិរីសុខា ឈ្នះមារាគ្រប់ៗគ្នា ។

## ថ្វាយផ្កាព្រះរតនត្រៃ

យើងខ្ញុំមានចិត្តត្រេក អរពន់ពេកកើតជ្រះថ្លា
នាំគ្នាបូជាផ្កា ថ្វាយសាស្តាដោយគោរព ។
សាងទានសីលភាវនា ដើម្បីលាចេញចាកភព
ចាកភ័យចាកឧបទ្រព ដោយសារម្លប់ពុទ្ធសាសនា ។
យើងខ្ញុំយកផ្កាឈើ ចងក្រងធ្វើភ្ជួងមាលា
មានពណ៌ផ្សេងៗគ្នា សូមបូជាដល់ព្រះពុទ្ធ ។
ព្រះធម៌និងព្រះសង្ឃ ប្រសើរអង្គសីលបរិសុទ្ធ
ត្រៃរតន៍នេះខ្ពស់ផុត វិសេសសុទ្ធលើភពបី ។

ខ្ញុំម្ចាស់ទាំងអស់គ្នា តែងកំព្រាទាំងប្រុសស្រី
ព្រាត់ប្រាសក្នុងលោកិយ ព្រាត់ស្វាមីបុត្រភរិយា ។
តែងជួបនឹងឈឺចាប់ និងកើតស្លាប់ជាធម្មតា
មានក្តីទុក្ខក្តៅផ្សា រកនរណាជួយពុំបាន ។
តេជៈ ខ្ញុំបូជា ភួងមាលាល្អកុំផាន
ត្រៃរតន៍ទាំងបីឋាន ឲ្យខ្ញុំបានផុតទុក្ខទោស ។
ផុតចាស់ផុតឈឺចាប់ នឹងកើតស្លាប់ជាធម្មតា
ឲ្យខ្ញុំបានសុខា ឆ្លងដល់ត្រើយមហានិព្វាន ។
ពាក្យពោលប៉ងប្រាថ្នា ធ្វើសច្ចាប្រណិធាន
សូមមគ្គផលនិព្វាន ឲ្យខ្ញុំបានប្រាកដហោង ។

# ពាក្យវេរប្រទីបថ្វាយចំពោះព្រះរតនត្រ័យ

**ឱកាស មយំ ភន្តេ បទីបគន្ធមាលាទីនិ សក្ការានិ រតនត្តយស្ស អភិបូជយាម មាតាបិតុអាទីនញ្ច ញាតិមិត្តានញ្ច ព្រហ្មានញ្ច ភូតានញ្ច ទេវានញ្ច នាគានញ្ច យក្ខានញ្ច ចតុន្នំ មហារាជានញ្ច សបរិវារានំ សព្វសត្តានញ្ច អម្ហានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...។ តតិយម្បិ...។**

ខ្ញុំសូមគោរព! បពិត្រព្រះមានព្រះភាគដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងឡាយមានចិត្តជ្រះថ្លាហើយ បាននាំមកនូវគ្រឿងសក្ការៈទាំងឡាយ មានប្រទីប ផ្កាកម្រង និងគ្រឿងក្រអូបជាដើមនេះ សូមបូជាថ្វាយ ចំពោះព្រះរតនត្រ័យ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់មាតាបិតាជាដើមផង ដល់ញាតិទាំងឡាយផង ដល់ព្រហ្មទាំងឡាយផង ដល់គន្ធព្វទាំងឡាយផង ដល់ទេវតាទាំងឡាយផង ដល់នាគទាំងឡាយផង ដល់យក្សទាំងឡាយផង ដល់ស្តេច
មហារាជទាំង៤ ព្រមទាំងបរិវាររបស់ខ្លួនផង ដល់សព្វសត្វទាំងអស់គ្នាផង ដល់យើងខ្ញុំព្រះអង្គទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។...អស់វារៈពីរដងផង។...អស់វារៈបីដងផង ។

## នមស្ការ( ឧបមា )

**សីសំ មេ បទុមំ កត្វា ទីបញ្ច**

( សីសាំង មេ ប៉ាក់ទុមាំង កាត់ត្វា ទីប៉ាញ់ចាក់)

**នយនទ្វយំ វចសា ធូបការេន**

(នាក់យាក់ណាត់ទ្វាក់យ៉ាំង វាក់ចាក់សា ធូប៉ាក់ការ៉េនាក់)

**មនសា ច សុគន្ធកំ ។**

(មាក់នាក់សា ចាក់ សុគាន់ធាក់កាំង) ។ **ប្រែថា:** ខ្ញុំសូមឱនសិរសា ទុកជាផ្កាឈូក ឧត្តម និងភ្នែកទាំងពីរផ្សំទុកជាគ្រឿង ប្រទីបថ្លៃ ព្រមទាំងសុវាចា ខ្ញុំធ្វើជាធូបប្រពៃ ចិត្តនឹកព្រះរតនត្រៃ ទុកជាក្លិនក្រអូបហោង ។

## រតនត្តយបូជា

(ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ)

**ឥមេហិ ទីបធូបាទិ សក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ**

(អ៊ិមេហិ ទីប៉ាក់ធូប៉ាទិ សាក់ការ៉េហិ ពុទធាំង ធ័មមាំង សាំងឃាំង)

**អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច**

(អាក់ភិប៉ូជាក់យាមិ មាតាប៉ិតាទីនាំង គុណាក់វ័នតាណាញ់ចាក់)

**មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ**

(ម៉ៃហាញ់ចាក់ ទីឃាក់រ៉ាត់តាំង អាត់ថាយាក់ ហិតាយាក់ សុខាយាក់)

*ប្រែថា:* ខ្ញុំព្រះករុណា សូមបូជាចំពោះនូវ { **ព្រះពុទ្ធ** **ព្រះធម៌** **ព្រះសង្ឃ** }

ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមរបស់នេះដើម្បីសេចក្តី ចម្រើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មាន មាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែង ទៅហោង ។

*( ថ្វាយបង្គំម្តង )*

# ពុទ្ធរតនប្បណាម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** (៣ដង)

(នាក់មោ តាស់សាក់ ភាក់គាក់វាក់តោ អាក់រាក់ហាក់តោ ស័មម៉ាស័មពុទធាស់សាក់)

ប្រែថា: វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគ អង្គនោះព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

(ថ្វាយបង្គំម្តង)

**យោ សន្និសិន្នោ វរពោធិមូលេ**

(យោ សាន់ និសិនណោ វាក់រាក់ ពោធិមូលេ)

**មារំ សសេនំ មហតឹ វិជេយ្យោ**

(មារាំង សាក់សេណាំង មាក់ហាក់តឹង វិជៃយោ)

**សម្ពោធិមាគច្ឆិ អនន្តញាណោ**

(ស័មពោធិមាគាច់ឆិ អាក់ណាន់តាក់ញាណោ)

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ**

(លោកុតតាក់ម៉ោ តាំង ប៉ាក់នាក់ម៉ាមិ ពុទធាំង)

*ប្រែថា:* ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើន នូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើនហើយ ទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណមានប្រាជ្ញារកទីបំផុតគ្មានព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

(យេ ចាក់ ពុទធា អាក់តីតា ចាក់ យេ ចាក់ ពុទធា អាក់ណាគាក់តា)

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា**

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ ពុទធា អាក់ហាំង វ៉ន់ទាមិ សាប់ពាក់ទា)

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុង

កាលខាងមុខក្ដី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះក្ដី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង។

*(ថ្វាយបង្គំម្ដង)*

**ឥតិបិ សោ ភគវា អរហំ**

(អ៊ិតិបិសោ ភាគ់គាគ់វា អាគ់រ៉ាគ់ហាំង)

**សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ**

(ស័មម៉ាស័មពុទធោ វិជ្ជាចាគ់រ៉ាគ់ណាគ់សាំប៉ាន់ណោ)

**សុគតោ លោកវិទូ អនុត្តរោ**

(សុគាគ់តោ លោកាគ់វិទូ អាគ់នុតតាគ់រ៉ោ)

**បុរិសទម្មសារថិ សត្ថា**

(ប៉ុរិសាគ់ទ័មម៉ាកសារ៉ាគ់ថិ សាត់ថា)

**ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**

(ទេវាគ់ម៉ាកនុសសាណាំង ពុទធោ ភាគ់គាគ់វាតិ)

*ប្រែថា:* **ឥតិបិសោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណ-សម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា៨ និងចរណៈ១៥ **សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គ ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គ ជា

សាស្តាចារ្យ នៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ។

(*ថ្វាយបង្គំម្តង*)

**នត្ថិ មេ សរណំ អញ្ញំ**

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញុំាង)

**ពុទ្ធោ មេ សរណំ វរំ**

(ពុទធោ មេ សាក់រ៉ាក់ណាំង វាក់រ៉ុាង)

**ឯតេន សច្ចវជ្ជេន**

(អេតេនាក់ សាច់ចាក់វ៉ាច់ជេនាក់)

**ហោតុ មេ ជយមង្គលំ**

(ហោតុ មេ ជាក់យាក់ម៉ង់គាក់លាំង)

*ប្រែថា:* **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណា មិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

**ឧត្តមង្គេន វន្ទេហំ**

(អ៊ុតតាក់ម៉ាំងគេនាក់ វ៉ន់ទេហាំង)

**បាទបំសុំ វរុត្តមំ ពុទ្ធេ យោ**

(ប៉ាទាក់ប៉ុងសុង វ៉ាក់រុតតាក់ម៉ាំង ពុទធេ យោ)

**ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ**

(ខាក់លិតោ ទោសោ ពុទធោ ខាក់ម៉ាក់តុ តាំង មាក់មាំង)

*ប្រែថា:* **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តម គឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែល

ខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

*(ថ្វាយបង្គំម្តង)*

*(ចប់ពុទ្ធរតនប្បណាម)*

❀❀❀

## ធម្មរតនប្បណាម

*(ថ្វាយបង្គំព្រះធម្មរតនៈ)*

**អដ្ឋង្គិកាកាវិយបថោ ជនានំ**

(អាត់ថាំងគិការិយាក់ប៉ាក់ថោ ជាក់នានាំង)

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

(មោកខាប់ប៉ាក់វេសាយ៉ាក់ អ៊ុជូ ចាក់ មាក់គោ)

**ធម្មោ អយំ  សន្តិករោ បណីតោ**

(ធ័មមោ អាក់យុំាង សាន់តិកាក់រ៉ោ ប៉ាក់ណីតោ)

**និយ្យានិកោ តំ បនមាមិ ធម្មំ**

(នៃយានិកោ តាំង ប៉ាក់នាក់ម៉ាមិ ធ័មមាំង)

*ប្រែថា:* ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជនដែលប្រាថ្នានូវព្រះនិព្វានឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញុំាងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព។

*(ថ្វាយបង្គំម្តង)*

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**

(យេ ចាក់ ធ័មមា អាក់តីតា ចាក់ យេ ចាក់ ធ័មមា អាក់ណាគាក់តា)

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា**

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ ធ័មមា អាក់ហាំង វ៉ាន់ទាមិ សាប់ពាក់ទា)

*ប្រែថា:* ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែល

និព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង។

(*ថ្វាយបង្គំម្តង*)

**ស្វាក្ខាតោ ភគវតា ធម្មោ**

(ស្វាក់ខាតោ ភាគ់គាក់វាក់តា ធ័មមោ)

**សន្ទិដ្ឋិកោ អកាលិកោ**

(សាន់ទិដឋិកោ អាក់កាលិកោ)

**ឯហិបស្សិកោ ឱបនយិកោ**

(អេហិប៉ាស់សិកោ អោប៉ាក់ណាក់យិកោ)

**បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ**

(ប៉ាច់ចាត់តាំង វេទិតាប់ពោ វិញញូហីតិ)

*ប្រែថា:* **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយ ដោយល្អ (**ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ប្រការគឺ មគ្គ ៤ ផល ៤ និព្វាន ១) **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណគឺ ថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេគឺឃើញច្បាស់ ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាលគឺថាកាលបើ ព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា កាលបើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផល ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វវិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹង គប្បីឃើញ ច្បាស់ក្នុងចិត្តនៃខ្លួន។

(*ថ្វាយបង្គំម្តង*)

**នត្ថិ មេ សរណំ អញ្ញំ**

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញ៉ាំង)

**ធម្មោ មេ សរណំ វរំ**

(ធ័មមោ មេ សាក់រ៉ាក់ណាំង វ៉ាក់រ៉ាំង)

**ឯតេន សច្ចវជ្ជេន**

(អេតេនាក់ សាច់ចាក់វ៉ាច់ជេនាក់)

**ហោតុ មេ ជយមង្គលំ**

(ហោតុ មេ ជាក់យាក់មាំងគាក់លាំង)

*ប្រែថា:* **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណា មិនមាឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តី ជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច**

(អ៊ុតតាក់ម៉ាំងគេនាក់ វ័នទេហាំង ធ័មម៉ាញ់ចាក់)

**ទុវិធំ វរំ ធម្មេ យោ**

(ទុវិធាំង វ៉ាក់រ៉ាំង ធ័មមេ យោ)

**ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ**

(ខាក់លិតោ ទោសោ ធ័មមោ ខាក់ម៉ាក់តុ តាំង មាក់មាំង)

*ប្រែថា:* **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំវរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

*(ថ្វាយបង្គំម្តង)*

*(ចប់ធម្មរតនប្បណាម)*

# សង្ឃរតនប្បណាម

*( ថ្វាយបង្គំព្រះសង្ឃរតនៈ )*

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

(សាំងឃោ វិសុទធោ វាក់រាក់ទាក់ខិណៃយ៉ោ)

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

(សាន់តិនទ្រិយោ សាប់ពាក់មាក់ឡាប់ប៉ាក់ហីណោ)

**គុណេហិ នេកេហិ សមិទ្ធិបត្តោ**

(គុណេហិ នេកេហិ សាប់មិទធិប៉ាត់តោ)

**អនាសវោ តំ បនមាមិ សង្ឃំ**

(អាក់ណាសាក់វ៉ោ តាំង ប៉ាក់នាក់ម៉ាមិ សាំងឃាំង)

*ប្រែថា:* ព្រះអរិយសង្ឃឯណាដ៏បរិសិទ្ធវិសេសជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រីយ៍រម្ងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព។

*( ថ្វាយបង្គំម្តង )*

**យេ ច សង្ឃា អតីតា ច**

(យេ ចាក់  សាំងឃា អាក់តីតា ចាក់)

**យេ ច សង្ឃា អនាគតា**

(យេ ចាក់ សាំងឃា អាក់ណាគាក់តា)

**បច្ចុប្បន្នា ច យេ សង្ឃា**

(ប៉ាច់ចុបប៉ាន់ណា  ចាក់ យេ សាំងឃា)

**អហំ វន្ទាមិ សព្វទា**

(អាក់ហាំង វ៉ៃនទាមិ សាប់ពាក់ទា)

*ប្រែថា:* ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល កន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ

នឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង។

(*ថ្វាយបង្គំម្តង*)

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

(សុប៉ាក់ដិប៉ាន់ណោ ភាគ់គាក់វាក់តោ សាវាក់កាក់សាំងឃោ)

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

(អ៊ុជុប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ សាវាក់កាក់សង្ឃោ)

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

(ញាយាក់ប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ សាំងវាក់កាក់សាំងឃោ)

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

(សាម៉ីចិប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ សាវាក់កាក់សាំងឃោ)

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា**

(យទិទាំង ចាត់តារិ ប៉ុរិសាក់យុគានិ អាត់ឋាក់ ប៉ុរិសាក់ប៉ុកគាក់លា)

**ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ**

(អេសាក់ ភាក់គាក់វាក់តោ សាវាក់គាក់សាំងឃោ អាហុណៃយ៉ោ)

**បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ**

(បាហុណៃយ៉ោ ទាក់ខិណៃយ៉ោ អាញ់ជាក់លិកាក់រាក់ណៃយ៉ោ)

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ**

(អាក់នុតតាក់រ៉ាំង ប៉ុញញ៉ាក់ខេតតាំង លោកកាស់សាតិ)

*ប្រែថា:* **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏

មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្មគឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤គូគឺ ព្រះសង្ឃដែលបានសម្រេចនូវ **សោតាបត្តិមគ្គ** និង **សោតាបត្តិផល** ជាគូ១ **សកទាគាមិមគ្គ** និង **សកទាគាមិផល** ជាគូ១ **អនាគាមិមគ្គ** និង **អនាគាមិផល** ជាគូ១ **អរហត្តមគ្គ** និង **អរហត្តផល** ជាគូ១ **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨គឺ ព្រះសង្ឃដែលបានសម្រេចនូវ **សោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទាន ដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន។

*(ថ្វាយបង្គំម្តង)*

**នត្ថិ មេ សរណំ អញ្ញំ**

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញាំង)

**សង្ឃោ មេ សរណំ វរំ**

(សាំងឃោ មេ សាក់រ៉ាក់ណាំង វាក់រ៉ាំង)

**ឯតេន សច្ចវជ្ជេន**

(អេតេនាក់ សាច់ចាក់វ៉ាច់ជេនាក់)

**ហោតុ មេ ជយមង្គលំ**

(ហោតុ មេ ជាក់យាក់មាំងគាក់លាំង)

*ប្រែថា:* **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណា មិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងជារលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។ **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច**

(អ៊ុតតាក់មាំងគេនាក់ វ៉ន់ទេហាំង សាំងឃាញ់ចាក់)

**ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ**

(ទុវិធោតាក់មាំង សាំងឃេ យោ ខាក់លិតោ ទោសោ)

**សង្ឃោ ខមតុ តំ មមំ**

(សាំងឃោ ខាក់ម៉ាក់តុ តាំង មាក់មាំង)

*ប្រែថា:* **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការគឺ សម្មតិសង្ឃ និង អរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

*( ថ្វាយបង្គំម្តង )*

*( ចប់សង្ឃរតនប្បណាម )*

❀❀❀

**បណាមគាថា**

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

(យោ កាប់ប៉ាក់កោដីហិបិ អាប់ប៉ាក់ម៉េយ៉ាំង)

**កាលំ ករោន្តោ អតិទុក្ករានិ**

(កាលាំង ការរ៉ោនតោ អាក់តិទុកកាក់រ៉ានិ)

**ខេទំ គតោ លោកហិតាយ នាថោ**

(ខេទាំង គាក់តោ លោកាក់ហិតាយាក់ នាថោ)

**នមោ មហាការុណិកស្ស តស្ស**

(នាក់មោ មាក់ហាការុណិកាស់សាក់ តាស់សាក់)

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន។
ធ្វើកម្មជាកម្រ សត្វនិករគ្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**

(អាក់ស័មពុទធាំង ពុទធាក់និសេវិតាំង យ៉ាំង)

**ភវាភវំ គច្ឆតិ ជីវលោកោ**

(ភាក់វាភាក់វាំង គាច់ឆាក់តិ ជីវាក់លោកោ)

**នមោ អវិជ្ជាទិកិលេសជាលំ**

(នាក់មោ អាក់វិជ្ជាទិកិលេសាក់ជាលាំង)

**វិទ្ធំសិនោ ធម្មវរស្ស តស្ស**

(វិទធាំងសិណោ ធ័មមាក់វាក់រាក់សាក់ តាស់សាក់)

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឲ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ។

**គុណេហិ យោ សីលសមាធិបញ្ញា**

(គុណោហិ យោ សីលាក់សាក់ម៉ាធិប៉ាញ់ញ៉ា)

**វិមុត្តិញ្ញាណបច្ចត្តភូតីហិ យុត្តោ**

(វិមុទតិញញាណាប់ប៉ាក់ភូតីហិ យុតតោ)

**ខេត្តញ្ញូនានំ កុសលត្ថិកានំ**

(ខេត្តតាញ់ជាក់នាណាំង កុសាក់ឡាត់ថិកាណាំង)

**តមរិយសង្ឃំ សិរសា នមាមិ**

(តាប់មាក់រិយាក់សាំឃាំង សិរាក់សា នាកមាមិ)

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ។

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ**

(អ៊ិចចេវាក់ម៉ាច់ចាន់តាក់ នាក់ម៉ាស់សាក់ណៃយ៉ាំង)

**នមស្សមានោ រតនត្តយំ យំ**

(នាក់ម៉ាស់សាក់ម៉ាណោ រាក់តាក់ណាត់តាក់យ៉ាំង យ៉ាំង)

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**

(ប៉ុញញាភិសាន់ទាំង វិប៉ុលាំង អាក់ឡាត់ថាំង)

**តស្សានុភាវេន ហតន្តរាយោ**

(តាស់សានុភាវេនាក់ ហាក់តាន់តាក់រ៉ាយ៉ោ)

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ
សូមឲ្យកម្ចាត់បង់ អពមង្គលទាំងឡាយ

ឲ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង។

(ថ្វាយបង្គំម្តង)

# នមស្ការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ**

(វ៉ន់ទាមិ ចេតិយ៉ាំង សាប់ពាំង

**សព្វដ្ឋានេសុ បតិដ្ឋិតំ**

(សាប់ពាត់ឋានេសុ ប៉ាក់តិដឋិតាំង)

**សារីរិកធាតុមហាពោធឹ**

(សារីរឹកកាក់ធាតុមាក់ហាពោធឹង)

**ពុទ្ធរូបំ សកលំ សទា**

(ពុធធាក់រូប៉ាំង សាក់កាក់ឡាំង សាក់ទា)

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធិ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលោះ រំដោះទុក្ខភ័យអន្តរាយ ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត។
សូមទាន់ព្រះអរិ- យមេត្រីថ្លៃវិសិដ្ឋ

សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង។

(ថ្វាយបង្គំម្តង)

## ពុទ្ធបាទនមស្ការគាថា

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**
**តិលោកកេតុំ តិភវេកនាថំ**
**យោ លោកសេដ្ឋោ សកលំ**
**កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ**

*ប្រែថា:* ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បាន ហើយញ៉ាំងជនជាអនន្តឲ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោកា មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

**យំ នម្មទាយ នទិយា បុលិនេ**
**ច តីរេ យំ សច្ចពន្ធគិរិកេ**
**សុមនា ចលគ្គេ យំ តត្ថ យោនកបុរេ**
**មុនិនោ ច បាទំ តំ បាទលញ្ជនមហំ សិរសា នមាមិ**

ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក លើផ្ទៃខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងយោនកបុរីខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូងចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ**
**សុមនកូដេ យោនកបុរេ**
**នម្មទាយ នទិយា បញ្ចបាទវរំ**
**ឋានំ អហំ វន្ទាមិ ទូរតោ**

ខ្ញុំសូមនមស្ការអំពីចម្ងាយនូវស្ថាន ដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺ ស្ថានលើភ្នំសុវណ្ណមាលិក១ លើភ្នំសុវណ្ណបព៌ត១ លើភ្នំសុមនកូដ១ ក្នុងយោនកបុរី១ ក្បែរស្ទឹងនម្មទា១ ។

(ថ្វាយបង្គំម្តង)

## ពាក្យសូមខមាទោសព្រះរតនត្រ័យ

**អច្ចយោ នោ ភន្តេ អច្ចគមា/ យថាពាលេ/ យថាពាលា/ យថាមុឡ្ហេ/ យថាមុឡ្ហា/ យថាអកុសលេ/ យថាអកុសលា/ យេ/យា មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ /ពុទ្ធស្ស វា / ធម្មស្ស វា/ សង្ឃស្ស វា អគារវំ អករិម្ហា/តេសំ /តាសំ /នោ ភន្តេ/ ភគវា / អយ្យោ / អយ្យា/ សង្ឃោ/ អច្ចយំ អច្ចយតោ/ បដិគ្គណ្ហាតុ /បដិគ្គណ្ហន្តុ/ អាយតី សំវរាយ ។**

(*ប្រែថា*) បពិត្រព្រះដ៏មានព្រះភាគ/ ព្រះករុណា/ព្រះករុណាទាំងឡាយ ព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះដ៏មានព្រះភាគ/ព្រះករុណាទាំងឡាយ/ព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះដ៏មានព្រះភាគ/ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃ ក្តី/ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះដ៏មានព្រះភាគ/ព្រះករុណា/ព្រះករុណាទាំងឡាយ ព្រះសង្ឃដ៏ចម្រើនសូមព្រះដ៏មានព្រះភាគ/ព្រះករុណា/ព្រះករុណាទាំងឡាយ/ព្រះសង្ឃ អត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិតដើម្បីនឹងបានសង្រួមគឺថានឹងប្រព្រឹត្តឲ្យល្អទៅក្នុងខាងមុខនោះហោង ។

**សូមបញ្ជាក់:** បើបុរសត្រូវថា **យថាពាលេ យថាមុឡ្ហេ យថាអកុសលេ,យេ មយំ**ថា **តេសំ នោ** បើស្ត្រីត្រូវថា **យថាពាលា យថាមុឡ្ហា យថាអកុសលា,យា មយំ** ថា **តាសំ នោ** បើទុកជាគ្នាច្រើនមានបុរសមានស្ត្រីលាយគ្នា ហើយសូត្រសូមខមាទោសព្រមគ្នានោះ ក៏ត្រូវតែសូត្រខុសគ្នាត្រង់បទដែល

ខណ្ឌដោយគំនូសទ្រេតនោះផងដែរ ។ វៀរលែងតែត្រង់បទ៣អន្លើ គឺត្រង់បទថា ភគវតោ វា ពុទ្ធស្ស វា, ភគវា អយ្យោ អយ្យា សង្ឃោ, បដិគ្គណ្ហតុ បដិគ្គណ្ហន្តុ នេះសូត្រដូចគ្នាទាំងបុរសទាំងស្ត្រីតែបើគ្នាច្រើន ហើយសូត្រសូមខមាទោសព្រមគ្នាទាំងអស់នោះ ។

## ពាក្យថ្វាយខ្លួន

(ជាឧបាសកឧបាសិកា)

**មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ**
**គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកេ ឧបាសិកាយោ**
**នោ ភគវា ធារេន្តុ អជ្ជតគ្គេ បាណុបេតេ បាណុបេតា**
**សរណំ គតេ សរណំ គតា ។**

បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលបរិនិព្វានទៅ អស់កាលយូរអង្វែងហើយនោះឯង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះករុណាទាំងឡាយ ជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសក ឧបាសិកា បានដល់ហើយនូវព្រះរតនត្រៃ ជាទីពឹងទីរលឹកស្មើដោយជីវិតតាំងពីពេលនេះជាដើមតរៀងទៅ ។

## វិធីសមាទានសីល ៥

**ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(អ៊ុកាសាក់ មាក់យ៉ាំង ភាន់តេ វិសុង វិសុង រាក់ខាក់ណាត់ថាយាក់)

**តិសរណេន សហបញ្ចសីលានិ យាចាម**

(តិសាក់រ៉ាក់ណេនាក់ សាក់ហាក់ប៉ាញ់ចាក់សីលានិ យាចាមាក់)

**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(ទុតិយ៉មបិ មាក់យ៉ាំង ភាន់តេ វិសុង វិសុង រាក់ខាក់ណាត់ថាយាក់)

**តិសរណេន សហបញ្ចសីលានិ យាចាម**

(តិសាក់រ៉ាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីលានិ យាចាម)

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(តាក់តិយ៉មបិ មាក់យ៉ាំង ភាន់តេ វិសុង វិសុង រាក់ខាក់ណាត់ថាយាក់)

**តិសរណេន សហ បញ្ចសីលានិ យាចាម**

(តិសាក់រ៉ាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីលានិ យាចាមាក់)

# កិច្ចឲ្យសីល និងទទួលសីល

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** (សូធ្យ ៣ ចប់)
រីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធជាទីពឹង ទីរលឹក។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះធម៌ជាទីពឹង ទីរលឹក។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះសង្ឃជាទីពឹង ទីរលឹក។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធជាទីពឹង ទីរលឹក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះធម៌ជាទីពឹងទីរលឹក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះសង្ឃជាទីពឹងទីរលឹកជាគម្រប់ពីរដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធជាទីពឹង ទីរលឹក ជាគម្រប់បីដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះធម៌ជាទីពឹងទីរលឹក ជាគម្រប់បីដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវ ព្រះសង្ឃជាទីពឹងទីរលឹកជាគម្រប់បីដងផង ។

**តិសរណគ្គហណំ បរិបុណ្ណំ** កិរិយាកាន់យកនូវត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ

**អាម ភន្តេ** ព្រះករុណាលោកម្ចាស់ (អ្នកឆ្លើយ)

**១.បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

**២.អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យ ដោយកាយ ឬ ដោយវាចា ។

**៣.កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**៤.មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

**៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទគឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ។

**ព្រះសង្ឃពោលរំលឹក:**

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** អ្នកទាំងឡាយគប្បីធ្វើ នូវសិក្ខាបទទាំងឡាយ៥នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

**អ្នកទទួលពោលថា: អាម ភន្តេ** ព្រះករុណាលោកម្ចាស់

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

សត្វទាំងឡាយបានទៅកាន់ស្ថានសួគ៌ ក៏ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរលត់ទុក្ខគឺព្រះនិព្វាន ក៏ព្រោះសីលព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលកុំឲ្យសៅហ្មងឡើយ ។

# នមោ ៣ (ចប់)

*(ប្រសព្វដោយគុណ ៣ យ៉ាង)*

**នមោ តស្ស** ពាក្យប្រារព្ធ កិច្ចការសព្វគ្រប់ក្នុងពុទ្ធសាសន៍
ប្រកាសកិត្តិគុណយ៉ាងជាក់ច្បាស់ ឥតមានវិបល្លាសបីប្រការ ។
**ភគវតោ** ជាបឋម ឈ្មោះគុណឧត្តមគឺ **ករុណា**
ព្រះទ័យអាណិតសត្វលោកា ប្រទានទេសនាបង្ហាញត្រើយ ។
**អរហតោ** ប្រសើរផុត ដោយព្រះវិសុទ្ធិគុណហើយ
គ្មានសល់កិលេសតិចតួចឡើយ ព្រះទ័យបានស្បើយពីបាបា ។
ឯ **សម្មាសម្ពុទ្ធស្ស** ទ្រង់ត្រាស់ដឹងជាក់នូវធម្មា
ដោយគុណទីបីគឺ **បញ្ញា** ធ្វើឲ្យលោកាមានរស្មី
យើងខ្ញុំព្រះអង្គទាំងអស់គ្នា ជាសត្វកំព្រាទាំងប្រុសស្រី
ស្លាប់កើតៗស្លាប់សែនភិតភ័យ មិនស្គាល់វិថីចប់ទុក្ខា។
សូមដល់ព្រះអង្គជាទីពឹង ជាទីពំនឹងក្នុងអាត្មា
និងសូមបានស្តាប់ព្រះធម្មា កសាងនាវាឆ្លងទុក្ខហោង ។

---

*ដោយលោកម្ចាស់គ្រូ វជិរប្បញ្ញោ* **សាន សុជា**

# បណាមគាថា

អរហន្តតថាគត ជ្រាបគ្រប់បទស្វែងគុណធំ
ទ្រង់ជាលោកុត្តម ច្បងជាងសព្វគ្រូលើសលន់ ។
ជាសាស្តានៃលោក ចេះឥតស្មោកទូន្មានជន
ខ្ញុំវន្ទាបន្ទន់ ទ្រង់ដែលជនគួរបូជា ។
ព្រះធម៌នៃសាស្តា ឧបមាដូចពន្លឺ
តែងធ្វើលោកឲ្យភ្លឺ ចាកងងឹតឲ្យសូន្យផុត ។
ដែលប្រាជ្ញសម្គាល់អាង ថាតំណាងសព្វញ្ញុពុទ្ធ
ខ្ញុំវន្ទាលំអុត ធម៌នោះសុទ្ធជនបូជា ។
សាវ័កព្រះសុគត ស្អាតម៉ត់ចត់វិសេសថ្លា

ប្រាថ្នាត្រៃសិក្ខា លោកសិក្សាធម៌ឧត្តម ។
ជាសង្ឃថ្នាក់ខាងលើ មិនអើពើលោកធម្ម
ខ្ញុំវន្ទាប្រណម្យ សង្ឃឧត្តមជនបូជា ។
ដោយអំណាចវន្ទា ត្រៃរតនាជាអម្ចាស់
សូមឲ្យពុទ្ធសាសន៍ លូតលាស់ក្រាស់ចម្រើនផង ។
សូមឲ្យសង្ឃព្រមព្រៀង កុំឲ្យល្មៀងខុសគន្លង
សូមសាធុជនផង កុំមានហ្មងបានសុខសាន្ត ។
ដោយតេជៈត្រៃរតន៍ ខ្ញុំប្រណិប័តន៍ដោយគោរព
សូមឲ្យការរៀនគ្រប់ របស់ខ្ញុំបានវឌ្ឍនា ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទា
សូមឲ្យការសិក្សា របស់ខ្ញុំសម្រេចឆាប់ ។
ដោយអំណាចត្រៃរតន៍ មានពុទ្ធរតន៍ជាប្រធាន
ប្រសិនបើកើតមាន អន្តរធានចង្រៃរោគ
សូមឲ្យវិនាសខ្ពោក កុំសល់រោគតិចតួចឡើយ ។

---

*ដកស្រង់ចេញពី(**បាលីវេយ្យាករណ៍**)*

# សុខាភិយាចនគាថា

ព្រះពុទ្ធដូចអាទិត្យ ឧត្តមពិតជាងពួកជន
កម្ចាត់នូវមោហន្ធ ហើយចេញចាកសព្វកិលេស ។
ទ្រង់បិតនៅលើភ្នំ ដ៏ឧត្តមមគ្គវិសេស
ដាស់សត្វជាប់កិលេស ឲ្យភ្លឺថែសក្នុងលោកា ។
សូមទ្រង់ប្រោសគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។
ស្វាក្ខាតធម៌ណា ផូរផង់ថ្លាគ្មានសៅហ្មង
ជាធម៌ដែលអ្នកផង ឃើញច្បាស់ពិតដោយខ្លួនឯង ។
ធ្វើនៅសន្តិភាព ធុរៈភាពដ៏ចិញ្ចែង
គួរបូជាយ៉ាងស្ដែង ឲ្យនិព្វានឲ្យសុខា ។

សូមធម៌នោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។
រីព្រះអរិយសង្ឃ ជាបុត្រអង្គព្រះសម្ពុទ្ធ
លោកស្អាតបរិសុទ្ធ ងាយចិញ្ចឹមរៀងរាល់ថ្ងៃ ។
ចិញ្ចឹមដោយអាត្មា កិលេសាលះស្រឡះ
សង្គ្រាមក៏លោកលះ ជ្រះស្រឡះបានក្សេមក្សាន្ត ។
ជាអ្នកស្តាប់ឱវាទ ដែលលោកនាថទ្រង់ទូន្មាន
ជាសាវ័កកល្យាណ ស្រែបុណ្យទាននៃជនា ។
សូមសង្ឃនោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

📖📖📖

| |
|---|
| *ជាងអ្វីមិនស្មើជាងសង្ខារ អ្នកប្រាជ្ញធម៌អាចិមិនស្មើពុទ្ធ* |
| *សភាវៈមិនស្មើធម៌បរិសុទ្ធ អ្វីមុតមិនស្មើនឹងចិត្តមុត ។* |

# ពុទ្ធបាទនមស្ការ

(ប្រែជាកាព្យ)

ព្រះសព្វញ្ញូពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មមារណាប្រដូចបាន ។
កម្ចាត់នូវកិលេស គ្មានឲ្យសេសនូវសល់ខាន
ញ៉ាំងជនទាំងប៉ុន្មាន ជាអនន្តឲ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេវតា និងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។
សូមថ្វាយបង្គំ ទសករប្រណម្យ ឆ្ពោះត្រង់ស្នាមព្រះបាទា

ដែលព្រះមានជោគ ទ្រង់ព្រះមេត្តា ជាន់ទុកឲ្យជាស្ពានថ្លៃ ។
បាទមួយនៅនា ស្ទឹងនម្មទា ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ
បាទមួយទ្រង់ជាន់ ទុកនៅឰ ដ៏ភ្នំគិរីសច្ចពន្ធ ។
បាទមួយនៅភ្នំ សុមនកូដ រហូតកំពូលដ៏សោភ័ណ
ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ ទុកនៅនាយោនកបុរី ។
ខ្ញុំសូមបន្ទន់ កាយវាចា និងចិត្តជ្រះថ្លាឱនសិរសី
បង្គំព្រះបាទ ព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។
ខ្ញុំសូមនមស្សការអំពីចម្ងាយ ឋានទាំងឡាយដែលមានព្រះបាទ
ទាំង៥កន្លែងដែលព្រះមុនីនាថ ទ្រង់ឈានព្រះបាទលើកំពូលភ្នំ ។
សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបព៌ត
មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជរដ្ឋយោនកបុរី ។
មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំងប្រាំនេះទីដែលទ្រង់ប្រទាន
ទុកឲ្យសព្វសត្វប្រតិបត្តិជាស្ពាន ដោយព្រះទ្រង់ញាណប្រទានទុកឲ្យ ។

---

*ដកស្រង់ចេញពី* **គហិបដិបត្តិ**

## បារមី-៣០

**ឥតិបិ ទានបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ ទានឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ ទានបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ ទានបារមី ទានឧបបារមី ទានបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ សីលបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ សីលឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ សីលបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ សីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ នេក្ខម្មបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ នេក្ខម្មឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ នេក្ខម្មបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ នេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្មបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ បញ្ញាបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ បញ្ញាឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ បញ្ញាបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ បញ្ញាបារមី បញ្ញាឧបបារមី បញ្ញាបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ វីរិយបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ វីរិយឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ វីរិយបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ វីរិយបារមី វីរិយឧបបារមី វីរិយបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ ខន្តីបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ ខន្តីឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ ខន្តីបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ ខន្តីបារមី ខន្តីឧបបារមី ខន្តីបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ សច្ចបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ សច្ចឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ សច្ចបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ សច្ចបារមី សច្ចឧបបារមី សច្ចបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ អធិដ្ឋានបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ អធិដ្ឋានឧបបារមីសម្បន្នោ សោ ភគវា**
**ឥតិបិ អធិដ្ឋានបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ អធិដ្ឋានបារមី អធិដ្ឋានឧបបារមី អធិដ្ឋានបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ មេត្តាបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តាឧបបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តាបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ អធិដ្ឋានបារមី អធិដ្ឋានឧបបារមី អធិដ្ឋានបរមត្ថបារមី ដូច្នេះផង ។

**ឥតិបិ ឧបេក្ខាបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ ឧបេក្ខាឧបបារមីសម្បន្នោ សោ ភគវា**

**ឥតិបិ ឧបេក្ខាបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ ឧបេក្ខាបារមី ឧបេក្ខាឧបបារមី ឧបេក្ខាបរមត្ថបារមី ដូច្នេះផង ។

**សមត្តឹសបារមិតានុភាវេន មយ្ហំ ហន្ត្វា សព្វេ ទុក្ខសោករោគភយូបទ្ទវទោមនស្សុបាយាសេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាព (នៃបារមីទាំង៣០ នៃព្រះដ៏មានព្រះភាគអង្គនោះ) សូមកម្ចាត់បង់នូវទុក្ខសោក រោគភ័យឧបទ្រព ទោមនស្ស និងឧបាយាសៈទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយរបស់ខ្ញុំ ចូរឲ្យវិនាសបាត់ទៅកុំបីមានសេសសល់ឡើយ។

*(ចប់បារមី៣០)*

## ពុទ្ធជយមង្គល

**ព្រះមុនិន្ទលោកាចារ្យ** ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សាស្រ្តាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឹកលន់កងសព្វស៊ាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។

| | |
|---|---|
| រីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជៈជយា | ព្រះឈ្នះមារគ្រានោះហោង ។ |
| **ព្រះមុនិន្ទពិននាយកៈ** | ផ្ចាញ់អាឡវកយក្សឃោរឃៅ |
| រឹងរូសមិនតាំងនៅ | ក្នុងខន្តីគុណសត្យា ។ |
| រហូតដល់រាត្រី | ព្រះជិនស្រីទ្រង់យុទ្ធនា |
| ក្រៃលែងក្រុងមារា | ក្នុងបឋមសម្ពោធិ ។ |
| ដោយព្រះពិធីញាណ | ទ្រង់ទូន្មានដោយខន្តី |
| ញ៉ាំងចិត្តអសុរី | ឲ្យបង់ព្យុះចុះវន្ទា ។ |
| រីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជៈជយា | ព្រះឈ្នះអាឡវកយក្ខហោង ។ |
| **ព្រះមុនិន្ទពិនជិនស្រី** | ផ្ចាញ់ដំរីឈ្មោះនាឡា |
| គិរីវរគជា | ដ៏ហានក្លាចុះព្រេងព្រេច ។ |
| សាហាវឆាវឆេះក្រៃ | ដូចភ្លើងព្រៃឆេះកំទេច |
| មុតដូចចក្រក្រុតពេជ្រ | ខ្លាំងដូចកាំអសនី ។ |
| ដោយព្រះពិធីស្រេព | ស្រោចទឹកអប់គឺបារមី |
| មេត្តាព្រះជិនស្រី | ញ៉ាំងដំរីឲ្យជ្រះថ្លា ។ |
| រីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជៈជយា | ព្រះឈ្នះនាឡាគិរី ។ |
| **ព្រះមុនិន្ទពិនលោកត្រៃ** | មានព្រះទ័យធ្វើបាដិហារ្យ |
| ផ្ចាញ់ចោរអង្គុលិមាល៍ | មានកម្រងគឺម្រាមដៃ ។ |
| នៃមនុស្សដែលគាត់កាត់ | មកដោតចាក់ជាមាល័យ |
| អង់អាចអំណាចក្រៃ | ដ៏មានដៃស្ទាត់ប្រហារ ។ |
| កាន់ដាវងារគ្រវី | ដេញព្រះមុនីសាស្តាចារ្យ |
| ចម្ងាយផ្លូវកន្តារ | កណ្តាលព្រៃបីយោជនា ។ |
| រីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជៈជយា | ព្រះឈ្នះអង្គុលិមាល៍ ។ |

**ព្រះមុនិន្ទមានព្រះភាគ**    ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា    ស្រីមានគភ៌ចាស់ចើលពោះ ។
យកឈើធ្វើជាកូន    ព័ទ្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ    ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល    នាកណ្ដាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី    គឺសច្ចំពាក្យសត្យា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះសាស្ដាឈ្នះចិញ្ចា ។
**ព្រះមុនិន្ទពិនអ្នកប្រាជ្ញ**    រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា    និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់    ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ    លើកកម្ពស់ដូចដងទង់ ។
បង្អើតម្បូរងងឹត    ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កម្ចាត់បង់    ដោយប្រទីបគឺបញ្ញា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះឈ្នះសច្ចកៈនិគ្រន្ថ ។
**ព្រះមុនិន្ទពិនទ្រង់ញាណ**    ញាំងមោគ្គល្លានមានអំណាច
ឲ្យប្លែងជានាគរាជ    ទៅទូន្មានព្យុះភុជង្គ ។
ឈ្មោះនន្ទោបនន្ទ    ចិត្តមោហន្ធរឿងឫទ្ធិរង្គ
ទិដ្ឋិកាចទ្រនង់    ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឲ្យឧបទេស    ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន    ឱនចុះចាញ់ព្រះចេស្ដា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះភគវាឈ្នះនាគហោង ។
**ព្រះមុនិន្ទពិនគោតម**    ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សម្គាល់ថាអាត្មា    រុងរឿងដោយគុណបរិសុទ្ធ ។

ដៃកាន់អាសិរ្វិស គឺចិត្តទ្រឹស្តដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះព្រហ្មាឥតមានហ្មង ។
**យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្លៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វៗថ្ងៃ កើតមង្គលជានិរន្តន៍ ។
**សោ នរោ** វីជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

# ពុទ្ធកិច្ច ៥ យ៉ាង

គ្រាកាលព្រះសម្ពុទ្ធ ប្រសើរផុតដ៏ឧត្តម
បានត្រាស់ជាបឋម សែសិបប្រាំព្រះវស្សា ។
បំពេញពុទ្ធកិច្ច មិនដែលដាច់វេលាណា
សន្មតឈ្មោះហៅថា ពុទ្ធក្រឹត្យាមានប្រាំយ៉ាង ។
**ទី-១** គឺពេលព្រឹក ដ៏ពន្លឹកពន្លឺស្វាង
ព្រះអង្គស្តេចទ្រង់យាង ចេញបិណ្ឌបាតប្រោសសព្វសត្វ ។
**ទី-២** រសៀលជ្រេ ព្រះសុរិយេពេលទៀបថ្ងាត់
ទេសនាប្រោសសព្វសត្វ មិនកំណត់ថាសត្វណា ។
**ទី-៣** ពេលព្រលប់ ព្រះចមភពត្រៃលោកា
ប្រទានធម៌ទេសនា ឲ្យឱវាទភិក្ខុសង្ឃ ។

**ទី-៤** ពេលអធ្រាត្រ ព្រះលោកនាថទ្រង់ផ្ចិតផ្ចង់
ព្រះទ័យល្អស្មោះត្រង់ ទ្រង់ដោះស្រាយនូវប្រស្នា ។
ផ្សេងៗកើតឡើងពិត នៅក្នុងចិត្តនៃទេវតា
រឿងឆ្ងល់ធម៌ត្រង់ណា ព្រះសាស្តាទ្រង់អារកាត់ ។
**ទី-៥** ពេលទៀបភ្លឺ ប្រមើលមើលនិស្ស័យសត្វ
នៅក្នុងសង្សារវដ្ត ឲ្យប្រាកដគួរសន្តោស ។
សត្វណាមានសំណាង ព្រះអង្គយាងចេញទៅប្រោស
ប្រទានធម៌ទាបខ្ពស់ ឲ្យទៅតាមឧបនិស្ស័យ ។
ធម៌នេះឈ្មោះហៅថា ពុទ្ធក្រឹត្យាប្រសើរក្រៃ
វិជ្ជាទិវថ្ងៃ នៃព្រះពុទ្ធពីបូរាណ ។
បំពេញឥតនឿយណាយ រៀងរាល់ថ្ងៃមិនដែលខាន
លុះចូលព្រះនិព្វាន ទើបឈប់ខានទាំងអស់ហោង ។
ហៃសាធុជនណា អ្នកប្រាថ្នានឹងប៉ុនប៉ង
ចង់ឃ្លាតពីចំណង ត្រៃលោកនេះពិតប្រាកដ ។
ត្រូវខំរៀនសិក្សា នូវធម៌អាថ៌ដែលជាបទ
ពុទ្ធកិច្ចប្រាំប្រាកដ នេះកំណត់គួរយល់ដឹង ។
ជននោះនឹងស្មើបាន នឹងនាឋានជាទីពឹង
ឬនៅនាលោកហ្នឹង នឹងបានខ្លួនជាអ្នកធំ ។
លើសជនផងទាំងឡាយ សុខសប្បាយដ៏ឧត្តម
ក្សេមក្សាន្តសុខមនោរម្យ រៀងរួចដល់និព្វានហោង ។

# រក្សាព្រះត្រៃបិដក

សិក្សាបិដកមរតកព្រះ មានជ័យជំនះឈ្នះមោហា
គឺជាកុសលផ្តល់បញ្ញា ឆ្លងវដ្តសង្សារឆ្ពោះនិព្វាន ។
ដូច្នេះយើងត្រូវថែរក្សា បិដកថ្លៃថ្លាជាធម្មទាន
ព្រះធម្មចេតិយប្រាជ្ញាញាណ សាស្តានៅមានយើងត្រូវប្រឹង ។

រក្សាបិដកមានគុណក្រៃ លកលៃបែងចែកញែកឲ្យដឹង
ប្រាំពីរប្រការគិតជញ្ជឹង ល្អម្លឹងប្រឹងថែខ្មែរមានធម៌ ។
**មួយ**-គឺរក្សាព្រះសាសនា មរតកអស្ចារ្យជាពុទ្ធពរ
ពាក្យពិតពាក្យពុទ្ធសុទ្ធបវរ ចេតិយព្រះធម៌ **វិ.សុ.អ** ។
**ពីរ**-គឺរក្សាព្រះសាស្តា វិន័យធម៌អាថ៌ចារទុកដាក់
ឋិតនៅជាគ្រូដ៏សមសក្តិ ប្រចក្សធម្មាជាសាស្តា ។
**បី**-គឺរក្សាការងារសង្ឃ ទ្រទ្រង់តម្រង់ព្រះសាសនា
សង្គាយនាធម៌វិន័យណា ត្រាស់អស់វស្សាសែសិបប្រាំ ។
**បួន**-គឺរក្សាគុណសម្បត្តិ នៃពុទ្ធបរិស័ទចាត់ជាឆ្នាំ
ព្រះធម៌វិន័យព្រះអង្គផ្តាំ ឋិតច្រើនពាន់ឆ្នាំព្រោះបរិស័ទ។
**ប្រាំ**-គឺរក្សាត្រៃសទ្ធម្ម បរិយត្តិនាំចំបដិបត្តិ
បដិវេធៈជាក់កម្ចាត់ កិលេសបង់បាត់ស្ងាត់សន្តាន។
**ប្រាំមួយ**-រក្សាត្រៃរតនៈ ឋិតនៅប្រចក្សសរណដ្ឋាន
ព្រះពុទ្ធព្រះធម៌នាំសុខសាន្ត ព្រះសង្ឃកល្យាណមានវិន័យ។
**ប្រាំពីរ**-រក្សាត្រៃសិក្ខា សាសនាចារជាប់ដួងហរទ័យ
សីលសមាធិធម៌ប្រពៃ ផុតភ័យអាស្រ័យដោយបញ្ញា។
ព្រះត្រៃបិដកមានប្រវត្តិ រឿងរ៉ាវបានកត់ចារអក្ខរា
អរិយធម៌វប្បធម៌មនុស្សទេវតា បុព្វេយ៉ាងណាចារឲ្យដឹង។
បិដកជាច្បាប់ប្រាប់ភពត្រៃ អ្នកមាននិស្ស័យលៃលកប្រឹង
សិក្សាបិដកកំចាត់ខឹង ជញ្ជឹងសម្លឹងដឹងត្រៃលក្ខណ៍។
បិដកច្បាប់ដើមព្រះសាសនា បាលីអក្ខរាសាស្តាជាក់
បដិបត្តិបូជាធានាមគ្គ កំណត់ត្រៃលក្ខណ៍លាត្រៃលោក។
កសាងចេតិយបិដកខ្មែរ យើងនាំគ្នាហែព្រះមានជោគ
សាធុ!សាធុ!ផុតចាករោគ សាធុផុតលោកអនុមោទនា ។

## វិសាខបូជា

វិសាខបុណ្ណមីគឺថ្ងៃវិសេស

យើងបានចាំចេះថ្ងៃព្រះភគវា
ប្រាំពីរប្រការជ្រះថ្លាវន្ទា
វិសាខបូជាឫក្សពារសែនល្អ ។
**ទីមួយ** គឺថ្ងៃសុមេធបណ្ឌិត
ពោធិសត្វពិតមានឫទ្ធិបវរ
ចាប់ផ្តើមទទួលព្រះពុទ្ធព្យាករណ៍
លោកធាតុញាប់ញ័រសោទរក្រៃ ។
**ទីពីរ** គឺថ្ងៃក្សត្រថ្លៃប្រសូត
អស្ចារ្យរហូតសម្ពោតព្រឹក្សព្រៃ
កំណើតចុងក្រោយជាប់ដោយអត្ថន័យ
ផុតចាកភពត្រៃលែងភ័យលែងព្រួយ ។
**ទីបី** គឺថ្ងៃព្រះស្រីមហាពោធិ៍
ដុះចេញលេចឆ្លោពោធិ៍ពិតមានត្រួយ
ថ្ងៃព្រះប្រសូតស្រួតដុះជាមួយ
ជំនួយឲ្យចិត្តបរិស័ទជ្រះថ្លា ។
**ទីបួន** គឺថ្ងៃចមត្រៃត្រាស់ដឹង
ថ្ងៃមានទីពឹងពំនឹងលោកា
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ
ពួកជនជ្រះថ្លាចិន្តាល្អស្អាត ។
**ទីប្រាំ** គឺថ្ងៃអង្គថ្លៃនិព្វាន
ថ្ងៃព្រះទ្រង់ញាណមានពុទ្ធោវាទ
បច្ឆិមវាចាថាកុំប្រមាទ
ឱវាទពិសិដ្ឋឋិតនៅជាគ្រូ ។
**ប្រាំមួយ** គឺថ្ងៃប្រល័យព្រះធាតុ
ចេតិយលោកនាថនៅទៀតមិនយូរ
ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍

តែជៅរំលាយរលត់ពុទ្ធសាសន៍ ។
**ឆ្នាំពីរ** គឺថ្ងៃជោគជ័យពុទ្ធា
គ្រប់ព្រះភគវាឈ្នះមារបានត្រាស់
នាំមកនូវសុខវិសេសខ្លាំងណាស់
គ្រប់អង្គទ្រង់ត្រាស់ព្រះធម៌ទេសនា ។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត
យើងខ្ញុំមានចិត្តនឹងធឹងជ្រះថ្លា
វន្ទាសំពះអង្គព្រះសាស្តា
សូត្រធម៌ថ្វាយផ្កាបូជាប្រទីប ។

---

*អគ្គបណ្ឌិត* **ប៊ុត សាវង្ស**

# ជយឃោស

៙៙៙

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ
បរាជយោ ឧគ្ឃោសិយំ បោធិមណ្ឌេ ទេវគ្គណា
ព្រហ្មគ្គណា ជយំ តទា មហេសិនោ ។**

ពេលនោះ ពួកទេវតាទាំងឡាយផង ពួកព្រហ្មទាំងឡាយផង មកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល ហើយមានចិត្តត្រេកអររីករាយ ថ្វាយទិព្វបុប្ផា ថ្វាយព្រះពរជ័យដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំ យ៉ាងនេះថា ព្រះពុទ្ធដ៏មានសិរីព្រះអង្គឈ្នះមារហើយ មារមានចិត្តបាប ចុះចាញ់ព្រះអង្គហើយ ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ
បរាជយោ ឧគ្ឃោសិយំ បោធិមណ្ឌេ នាគគ្គណា
សុបណ្ណគ្គណា ជយំ តទា មហេសិនោ ។**

ពេលនោះ ពួកនាគទាំងឡាយផង ពួកគ្រុឌទាំងឡាយផង មកជួបជុំគ្នាហើយត្រង់ពោធិមណ្ឌល ហើយមានចិត្តត្រេកអររីករាយ ថ្វាយទិព្វបុប្ផា ថ្វាយព្រះពរជ័យដល់ព្រះមហាឫស្សី ដែលព្រះអង្គស្វែងរកគុណដ៏ធំ យ៉ាងនេះថា ព្រះពុទ្ធដ៏មានសិរីព្រះអង្គឈ្នះមារហើយ មារមានចិត្តបាប ចុះចាញ់ព្រះអង្គហើយ ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ បរាជយោ ឧគ្ឃោសិយុំ បមោទិតា ពោធិមណ្ឌេ មយំ ជយំ ឥទានិ មហេសិនោ ។**

ពេលនោះ ពួកយើងខ្ញុំព្រះករុណាទាំងឡាយផង(ទាំងបព្វជិត ទាំងគ្រហស្ថ) បានមកជួបជុំគ្នាហើយ ត្រង់ពោធិមណ្ឌល(នាអារាម...) ហើយមានចិត្តត្រេកអររីករាយ ថ្វាយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូប ផ្កាភ្ញី ព្រមទាំងគ្រឿងក្រអូបផ្សេងៗ ចំពោះព្រះរតនត្រៃ ហើយថ្វាយព្រះពរជ័យ ដល់ព្រះមហាឫស្សីដែលព្រះអង្គស្វែងរកគុណដ៏ធំ យ៉ាងនេះថា ព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាប ចុះចាញ់ព្រះអង្គហើយ ។

## ជយបរិត្តគាថា

៙៙៙

**មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ**

ព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួង ដើម្បីប្រយោជន៍ដល់សត្វទាំងអស់ហើយទ្រង់បានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ

**ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ** ដោយកិរិយាពោលនូវពាក្យសច្ចៈនេះសូមជយមង្គលកើតមានដល់អ្នក(ដល់ខ្ញុំ) ។

**ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ អបរាជិតបល្លង្កេ សីសេ បឋវិបោក្ខរេ អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ** ព្រះសម្មាសម្ពុទ្ធ ទ្រង់ញ៉ាំងសេចក្ដីត្រេកអរនៃសាក្យទាំងឡាយឱ្យចំរើនព្រះអង្គទ្រង់ឈ្នះមារហើយ បានដល់នូវភាពជាបុគ្គលដ៏ប្រសើរបំផុត ទ្រង់រីករាយ ចំពោះព្រះធម៌ដែលព្រះអង្គត្រាស់ដឹង លើអបរាជិតបល្ល័ង្កជាជយមង្គលទៀបគល់ពោធិព្រឹក្ស ត្រង់ផ្ចិតផែនដីដូចស្លឹកឈូកជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះ យ៉ាងណាមិញ សូមឱ្យអ្នកជាបុគ្គលមានជ័យជំនះឈ្នះ អស់សត្រូវ យ៉ាងនោះឯង ។

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ**
ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះឈ្មោះថា នក្ខត្តប្ញក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ ទានដែលបុគ្គលបានបូជាហើយ ដល់ព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងពេលនោះឈ្មោះថា ជាគ្រឿងបូជាល្អ
**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា**
ក្នុងថ្ងៃនោះ កាយកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចំរើន មនោកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចំរើន។
**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ** បុគ្គលដែលធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចំរើន យ៉ាងនេះ ហើយក៏រមែងបាននូវប្រយោជន៍ដ៏ចំរើនទាំងឡាយ ។

## ធម៌សុខោ

**សុខោ ពុទ្ធានមុប្បាទោ** កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខ,
**សុខា សទ្ធម្មទេសនា** កិរយាសម្តែងនូវព្រះសទ្ធម្ម គឺបរិយត្តិធម៌ និងព្រះនព្វលោកុត្តរ-ធម៌ ជាទីនាំមកនូវសេចក្តីសុខ,
**សុខា សង្ឃស្ស សាមគ្គី** សេចក្តីព្រមព្រៀងគ្នានៃព្រះសង្ឃ ជាគុណជាតិនាំមកនូវសេចក្តីសុខ,
**សមគ្គានំ តបោ សុខោ** តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នកព្រមព្រៀងគ្នា ជាហេតុនាំមកនូវសេចក្តីសុខ,
**ទិវា តបតិ អាទិច្ចោ** ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ,
**រត្តិមាភាតិ ចន្ទិមា** ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់,

**សន្ណទ្ធោ ខត្តិយោ តបតិ** ព្រះមហាក្សត្រលុះទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យទើបរុងរឿងបាន,
**ឈាយី តបតិ ព្រាហ្មណោ** ព្រាហ្មណ៍លុះតែចម្រើននូវឈាន ទើបរុងរឿងបាន,
**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា** ឯព្រះពុទ្ធជាម្ចាស់ ទ្រង់រុងរឿងដោយតេជៈទាំងថ្ងៃទាំងយប់,
**ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា** សេចក្តីសុខសួស្តី សូមកើតមានក្នុងកាលទាំងពួង ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

## បទលើកទង់ព្រះពុទ្ធសាសនា

១- សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហមព្រមទាំងពណ៌ស ហង្សបាទ និងពណ៌ ដ៏ភ្លឺផ្លេក ។
២- ប្រទេសតូចធំ បានស្ម័គ្រស្មាគម ជំនុំគ្នាច្រើន អនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក ប្រសើរ ពន់ពេក ក្រៃកន្លង ។
៣- ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃព្រះសម្ពុទ្ធ ធំចម្បង
ចូរយើងរាល់គ្នាយកចិត្តចាំចង នឹកដល់ ព្រះអង្គ ជាអម្ចាស់ ។
៤- ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជា ពុទ្ធសាសន៍
ត្រូវមានសាមគ្គីទាំងក្មេងទាំងចាស់ ប្រឹងប្រែង ឲ្យណាស់ គ្រប់ៗគ្នា ។
៥- សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធិ ថ្លៃថ្លា ហើយមានជ័យជោគ
ផ្សាយពេញលោកា ដោយជន ជ្រះថ្លាច្រើនសែនលាន ។
៦- មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ ដ៏កល្យាណ
ទាំងមនុស្សទេវតាស្នេហាគ្រប់ប្រាណ ប្រាថ្នា ចង់បាន សេចក្តីសុខ ។
៧- យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ យើងនឹង បានសុខ ក្សេមក្សាន្តត្រាណ ។
៨- ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ស្ថាន និព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត ជាតិយើង នឹងបាន សោយសុខា ។

# បទដាក់ទង់ព្រះពុទ្ធសាសនា

១- ជាតិយើង អ្នកកាន់សាសនា ត្រូវដឹងច្បាស់ថា ព្រះពុទ្ធជិនស្រី
ទ្រង់មាន ឆព្វណ្ណរង្សី គឺព្រះរស្មី ទាំងប្រាំមួយពណ៌ ។
២- ផ្សាយចេញ ពីព្រះកាយទ្រង់ រុងរឿងឫទ្ធិវង្ស ប្រសើរបវរ ឆៀលឆ្វាត់
កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ ស្រស់ល្អសោភា ។
៣- កំណើត នៃព្រះរស្មី កើតដោយបារមី នៃព្រះភគវា
ធ្វើទាន ឥតមានរុញរា កាលដែលនៅជា ព្រះពោធិសត្វ ។
៤- រស្មីពណ៌ខៀវនុ៎ះណា កាលឆ្កៀលនេត្រា ទ្រង់ដោយចិត្តកាត់
ឲ្យទាន ដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រ នាមស្រីពិរាស្រ្ត ។
៥- រស្មី ពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អារ សាច់ផៃធ្វើមាស
បិតពុទ្ធរូប ភ្លឺឱភាស ព្រះឥន្ទជាងមាស ទ្រង់វៃបណ្ឌិត ។
៦- រស្មី ក្រហមនុ៎ះណា កាលដែលមាតា ពស់ខាំស្លាប់ពិត
បទុម ស៊ូប្តូរជីវិត កាត់បេះដូងបិតធ្វើថ្នាំមាតា ។
៧- រស្មី ពណ៌សសុទ្ធសាធ កាលជាព្រះបាទវេស្សន្តរក្សត្រា
ឲ្យដំ-រីសសោភា ដល់ព្រាហ្មណ៍ប្រាថ្នា យកពោធិញ្ញាណ ។
៨- រស្មី ពណ៌ដូចជើងហង្ស កាលមាតាទ្រង់ យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឲ្យយក្សសាមាន្យ ស៊ីប្តូរជីវិត ។
៩- រស្មី ពណ៌ផ្លេកពណ្ណរាយ កាលជាទន្សាយ ឈ្មោះសោមបណ្ឌិត
ឲ្យទាន សាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
១០- រស្មី ខៀវលឿងក្រហម សហង្សបាទព្រម ភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារ ចងចាំទុកអើយ ។

# អត្ថន័យទង់ព្រះពុទ្ធសាសនា

ពណ៌ខៀវកាលឆ្កៀលព្រះនេត្រា ឲ្យឥន្ទព្រាហ្មណ៍ណាកាលជាស្តេច
នាមស្រីពិរាស្រ្តចង់សម្រេច ឲ្យបានសារពេជ្ញសាស្តាចារ្យ ។
ពណ៌លឿងកាលអារសាច់ធ្វើមាស បិតលន់អង្គព្រះពុទ្ធបដិមា

ព្រះឥន្ទជាជាងច្នៃរចនា ថ្វាយពរសាធុការពេញផែនដី ។
ក្រហមជាពណ៌ឈាមបេះដូង ឆ្អៀលពីដើមទ្រូងដោយឃ្នាតខ្មី
បិតពិសពស់ខាំព្រះជននី គង់រស់ជីវិតជាស្បើយទៅ ។
ពណ៌សឲ្យទានដំរីស មង្គលបវរមាសឆ្អិនឆ្អៅ
ត្រូវវាស្រូបណ្តេញមិនឲ្យនៅ ព្រមទាំងកូនចៅភរិយាណា ។
ហង្ស បាទលោហិត សាច់មំសំ អារសាច់ខ្លួនតាំងដូរមាតា
កាលយក្សវាចាប់បរិភោគក្ការ ជីវិតមាតារស់រឹងខ្មី ។
ផ្លេក ពណ្ណរាយកាល ជាទន្សាយ ឲ្យទានពុំស្តាយជីវិតអី
លោតចូលភ្នក់ភ្លើងពុំថាអ្វី ឲ្យជាចំណីឥន្ទព្រាហ្មណ៍ណា ។
កាលដែលបានត្រាស់ជាព្រះពុទ្ធ ជាម្កុដត្រៃភពក្នុងលោកា
ពណ៌ទាំងប្រាំមួយនេះសោតណា ប្រែមកក្លាយជាឆព្វណ្ណរង្សី ។
ពេលនេះក្នុងលោកគេសន្មតិ យកពណ៌នេះកត់ជាសេចក្តី
ហៅទង់សាសនាព្រះជិនស្រី ពាសពេញផែនដីផ្ទៃពសុធា ។
យើងខ្ញុំរាល់គ្នាសូមគោរព វន្ទាចមភពទង់សាសនា
សូមមានមង្គលឈ្នះមារា សត្រូវនានាក្នុងភពបី ។
សូមឲ្យយើងខ្ញុំប្រញាប់ដល់ ដើរកាត់តាមផ្លូវទៅបុរី
ជាស្ថានបរមសុខសួស្តី ដោយព្រះបារមីនិព្វានហោង ។

## ធម្មនិយាម ៣០

សូមក្រាបបង្គំប្រណម្យវន្ទា ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា ។
**មួយ** វញ្ហយភពជាតិគ្រប់ចុងក្រោយ បារមីនាំឲ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
**ពីរ** គឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌ ស្ទឹងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
**បី** ឥរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្តាចាកផ្ទៃ

មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្ងៃហឫទ័យជ្រះថ្លា ។
**បួន** សួនឧទ្យានទីឋានប្រសូត ក្នុងព្រៃរហូតឈើស្រូតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ ចក្រវាឡបព្វតាខ្ទ័រខ្ទារអ៊ូអរ ។
**ប្រាំ** ព្រះប្រសូតចុះស្រូតយាងឈាន ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្លឺសីហនាទ ។
**ប្រាំមួយ** ប្រមើលទតមើលនិមិត្ត ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាតយាត្រាសាងផ្នួស ។
**ប្រាំពីរ** ធីរោផ្តាច់ប្តូរព្យាយាម ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង ។
**ប្រាំបី** មហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា។
**ប្រាំបួន** ជូនភ័ព្វទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា ទេវធីតាមារមកគ្រាសាយ័ណ្ហ ។
**ដប់** គាប់ហឫទ័យអានាបាណៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវ័នជាន់ឆ្លងកាមា ។
**ដប់មួយ** ជំនួយពីព្រះបារមី ផ្ចាញ់មារអប្រិយព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។
**ដប់ពីរ** មុនីអង្គទ្រង់សម្រេចញាណ ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ ពោធិញាណខ្ពស់ឯកកក្រើកធរណី ។
**ដប់បី** ក្សត្រថ្លៃគង់ក្នុងមហាឋាន វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកស្ទួយស្ថានទី ចេតិយព្រះមុនីប្រាំពីរកន្លែង ។
**ដប់បួន** ជូនព្រហ្មជុំអារាធនា សូមព្រះភគវាយាងត្រាស់សម្តែង
ព្រះធម៌ប្រពៃវិស័យសូរ្យសែង ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ ។
**ដប់ប្រាំ** ចាំច្បាស់ទ្រង់ត្រាស់ធម្មចក្រ ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហបូជា ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ ។
**ដប់ប្រាំមួយ** ទ្រង់គង់ត្រាស់ឱវាទ បាដិមោក្ខស្អាងស្អាតឱវាទផូរផង់

បេះដូងព្រះធម៌ពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។
**ជប់ឆ្នាំពីរ** ទ្រង់គង់វត្តជេតពន ប្រោសដល់មហាជននិវន្តរ៍ប្រក្រតី
ទ្រង់យកអរុណជេតពនសួស្តី ជេតពនជិនស្រីអាស្រ័យជានិច្ច ។
**ជប់ឆ្នាំបី** ទ្រង់សម្តែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា ។
**ជប់ឆ្នាំបួន** ទ្រង់គង់ឋានត្រៃត្រិង្ស ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្តែងអភិធម្មសក្តិសមអស្ចារ្យ ថ្វាយព្រះមាតាសុខាអមតៈ ។
**ម្ភៃ** គឺព្រះអង្គទ្រង់ចាកទេវលោក ស្តេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ ។
**ម្ភៃមួយ**គឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ
អរហត្តផលតម្កល់ប្រក្រតី ឆាប់ក្តីយូរក្តីវិស័យពុទ្ធញាណ ។
**ម្ភៃពីរ** ប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ ត្រូតសត្វកោដិលានមានពីរវារៈ ។
**ម្ភៃបី** ទ្រង់លៃវិន័យអាជ្ញា បញ្ញត្តិសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក មានហេតុជាក់លាក់ទើបដាក់វិន័យ ។
**ម្ភៃបួន** អង្រួនហឫទ័យករុណា ជាតកទេសនាសាស្តាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍ ។
**ម្ភៃប្រាំ**ទ្រង់ប្រោសដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានៈព្រះញាតិវង្សា ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។
**ម្ភៃប្រាំមួយ** ទ្រង់គង់ធ្ងន់ក្នុងធម៌ បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្តេចយាងទទួលស្រុះស្រួលដោយអង្គ គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌ ។
**ម្ភៃប្រាំពីរ** ទ្រង់គង់ចាំវស្សា បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ។
**ម្ភៃប្រាំបី** ទ្រង់គង់យ៉ាងហ្មត់ចត់ មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យ៉ាងទាំងអស់ ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា។
**ម្ភៃប្រាំបួន** ទ្រង់គង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា

បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា សោយរសមំសាហប្ញទ័យបរិសុទ្ធ ។
**សាមសិប** អវសានទ្រង់បានចូលឈាន មុននឹងនិព្វានឈានច្រើនបំផុត
២៤សែនកោដិសមាបត្តិបរិសុទ្ធ រួចហើយទ្រង់ផុតរលត់សង្ខារ ។
**អហំ** រីខ្ញុំ បង្គំវន្ទា ឆ្ពោះព្រះភគវាព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃផូរផង់សីលា ចិន្តាលំអុតព្រះពុទ្ធនិយាម ។
សូមឲ្យសព្វសត្វបដិបត្តិតាមធម៌ សាសនាបវរល្អដូចព្រះនាម
**អរហំ សម្មា** គ្មានការទាក់ទាម កិលេសរវាមរវាតសូន្យបង់ ។
សូមឲ្យសាសនាសម្មាសម្ពុទ្ធ បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា ។
សូមមនុស្សទេវតាមានការគោរព ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្តីប្រាថ្នា អស់នូវតណ្ហាទុក្ខាចប់ហោង ។

*កំបោរត្រូវរមៀតតែងផ្លាស់ពណ៌ ឧស្សាហ៍ស្តាប់ធម៌លោកទេសនា*
*ចូលជិតនារីប្រុសរតនា គ្រាប់ក្បួនកមរាប្រាជ្ញាឃ្លាស ។*

# គោតមប្រវត្តិ

…ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
…មកចាប់ផ្ទៃមាតា ស្រីស្រិង្គារស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
…ក្នុងថ្ងៃព្រហស្បតិ៍អា- សាឍមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
…កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
…កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។

✍...ឆ្នាំចពិសាខនា ថ្ងៃសុខជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
✍...កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
✍...នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
✍...កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។
✍...ស្តេចមានព្រះរាជបុត្រ បរិសុទ្ធភក្ត្រស្រស់ថ្លា
គួរឲ្យព្រះរាជា ស្តេចជំពាក់ចិត្តពេកក្រៃ ។
✍...តែទ្រង់បានកាត់ផ្តាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។
✍...បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
✍...កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
✍...កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្ករកិរិយា គ្មាននរណាធ្វើដូចអី ។
✍...បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។
✍...ត្រាស់ដឹងបានពីរខែ ទ្រង់គ្នាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្តាលដងព្រឹក្សព្រៃ ។
✍...គឺក្នុងឆ្នាំរកា អាសាធមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្តើមពោលស្តីធម៌ទេសនា ។
✍...ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្តា មានរហូតដល់សព្វថ្ងៃ ។

| | |
|---|---|
| ✍...នាថ្ងៃមួយនោះណា | គួរសោកាណាម្នាស់ថ្លៃ |
| គឺថ្ងៃព្រះជិនស្រី | កាត់ព្រះទ័យដាក់សង្ខារ ។ |
| ✍...គឺក្នុងថ្ងៃអាទិត្យ | ឆ្នាំម្សាញ់ពិតមាឃមាសា |
| នៅចំពោះមុខមារ | នាបាវាលចេតិយ ។ |
| ✍...បីខែកន្លងទៅ | មិនឈប់នៅយឺតយូរអី |
| ដល់ថ្ងៃព្រះជិនស្រី | ទ្រង់និព្វានចាកលោកា ។ |
| ✍...គឺក្នុងឆ្នាំនោះឯង | មានការផ្សេងតែមាសា |
| គឺខែពិសាខនា | ថ្ងៃអង្គារពេញបូណ៌មី ។ |
| ✍...ដោយអំណាចអានុភាព | ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍ |
| នឹកគុណព្រះមុនី | សូត្រប្រវត្តិព្រះសាស្ដា ។ |
| ✍...សូមឲ្យសម្រេចបុណ្យ | ដែលជាគុណល្អថ្លៃថ្លា |
| អន្ទោលក្នុងសង្សារ | សូមប្រាថ្នាជួបបណ្ឌិត ។ |
| ✍...សូមជួបព្រះសិរអារ្យ | ជាសាស្ដាដ៏ពិសិដ្ឋ |
| សូមចាក់ធ្លុះធម៌ពិត | សមដូចចិត្តប្រាថ្នាហោង ។ |

✍✍📖✍✍

# បទព្រហ្មអារាធនាធម៌ទេសនា

(អារាធនាលោកសំដែងធម៌)

**ព្រហ្មា ច លោកាធិបតី សហម្បតី កតញ្ជលី អន្ធិវរំ អាយាចថ សន្តីធ សត្តាប្បរជេក្ខជាតិកា ទេសេតុ ធម្មំ អនុកម្បិមំ បជំ សទ្ធម្មភេរឹ វិនយញ្ច ភាយំ សុត្តញ្ច ពន្ធំ អភិធម្មចម្មំ អាភោជយន្តោ ចតុសច្ចទណ្ឌំ បញ្ចោធនេយ្យេ បរិសាយ មជ្ឈេ ។**

| | |
|---|---|
| សហម្បតីព្រហ្ម | ឱនបង្គំអារាធនា |
| សម្ដេចព្រះភគវា | ដោយគាថាយ៉ាងនេះឯង ។ |
| ព្រះពុទ្ធទ្រង់អនុកូល | ព្រមទទួលនិងសំដែង |
| ដោយតុណ្ហីភាពថ្លែង | តាមភាវៈគុណករុណា ។ |
| ទើបក្រោកចាកទីនោះ | ភក្ត្រាឆ្ពោះព្រៃមិគទា |

យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។
ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គិយជាអាទិ៍
ឲ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សំដែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សា ៤៥ ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រៃ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឲ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង ។

## អារាធនាធម្មកថិកសំម្តែងធម៌ទេសនា

អហំរីខ្ញុំម្ចាស់ សូមឱកាសក្រាបប្រណិបត្តិ
ដល់អស់ពួកបរិស័ទ ដែលលះកាត់ក្តីកង្វល់ ។
ហើយមកប្រជុំគ្នា ព្រោះប្រាថ្នាយកកុសល
ហេតុនេះសូមតម្កល់ តាំងចិត្តស្តាប់ធម៌ទេសនា ។
ដើម្បីជាការបុណ្យ នឹងជាគុណច្រើនណាស់ណា
អំណាចស្តាប់ទេសនា ដោយជ្រះថ្លាក្នុងសន្តាន ។
សូមតាំងចិត្តឲ្យស្អាត ខ្ញុំអារាធនាថ្កាន
និមន្តលោកនិទាន ទេសន៍ទូន្មានយើងរាល់គ្នា ។
ហេតុនេះពុទ្ធបរិស័ទ ដែលប្រណិបត្តិគាល់ត្រៀបត្រា
កុំពោលកុំចរចា និយាយគ្នាបែរមុខក្រោយ ។
សូមផ្ចង់នូវសញ្ញា ផ្ទៀងសោតាស្តាប់កុំធ្លោយ
ទើបនឹងបានផលសោយ អានិសង្សប្រាំប្រការ ។

# សរសើរធម៌ទេសនា

ហេតុតែព្រះគុណចេះឆ្លាស់ឆ្លៀត ធម៌ណាចង្អៀតចេះកែខៃ
វែកញែកចេញច្បាស់អស់សង្ស័យ បញ្ញាទន់ខ្ចីគង់ស្តាប់បាន ។
ធម៌នេះពីរោះអ្វីប្លែកៗ ពីរោះពន់ពេកក្នុងសន្តាន
ទោះបីអ្នកល្ងង់គង់ស្តាប់បាន ដោយបានរសធម៌ដ៏ប្លែកៗ ។
ធម៌នោះពីរោះអ្វីម្លេះណា ដែលព្រះករុណាទេសថ្មី ៗ
សង្ខេបឯរំ បញ្ចប់ខ្លី យើងខ្ញុំប្រុសស្រីស្តាយពេកណា ។
មិនទាន់អស់ចិត្តនឹងសាច់ធម៌ តែទូលអង្វរមិនហ៊ានថា
ខ្លាចនឿយព្រះទ័យព្រះករុណា សព្វសាធុការបញ្ចប់ខ្លី ។
នាកាលសម័យព្រះភគវា ស្តេចគង់ធម្មាប្រោសប្រទាន
ព្រះធម៌នាំសត្វទៅនិព្វាន រាប់ម៉ឺនសែនលានស្ទើរគ្មានសល់ ។
ហត្ថាទាំងគូគងប្រណម្យ លើកហត្ថបង្គំគុណកែវបី
ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថ្លៃ សូមមានសិរីដល់យើងខ្ញុំ ។
ខ្ញុំសូមខមាទោសទាំងឡាយ ក្រែងឆ្គងដោយកាយឬវាចា
ចិត្តមិនគ្រោតគ្រាតសន្តានណា ដូចមានគាថាសូត្រក្រោយហោយ ។

កាលពីក្មេងឲ្យស្វែងរៀនចំណេះ ដល់ធំឲ្យចេះរកទ្រព្យសម្បត្តិ
ដល់ទៅចាស់ឲ្យស្វះកាន់សីលសត្យ ហៀបនឹងស្លាប់ឲ្យហាត់ចិត្តភាវនា។

# ពុទ្ធប្បវត្តិសង្ខេប

យើងខ្ញុំបរិស័ទពុទ្ធសាសនា ឱនកាយវាចាចិត្តគោរព
ចំពោះព្រះពុទ្ធដែលជាម្លប់ គ្រប់គ្នាត្រូវចាំឲ្យទៀងទាត់ ។
ចងចាំថ្ងៃខែឆ្នាំឲ្យច្បាស់ នៃព្រះពុទ្ធម្ចាស់គឺប្រវត្តិ
សង្ខេបខ្លីៗឲ្យរត់មាត់ កំណត់ចាំបានពេលទាំងអស់ ។
យាងចុះកាន់គភ៌ឆ្នាំរកា អាសាធមាសាថ្ងៃព្រហស្បតិ៍
ប្រសូតឆ្នាំចថ្ងៃសុក្រស្មោះ ពិសាខឈើលាស់ដើមរដូវ ។
សោយរាជ្យកត្តិកថ្ងៃអាទិត្យ ប្រជុំព្រេងព្រឹទ្ធនាឆ្នាំឆ្លូវ

បួសថោះអាសាធព្រហស្បតិ៍ត្រូវ ត្រាស់នូវរកាពិសាខពុធ ។
បរិនិព្វានថ្ងៃអង្គារ បរិស័ទគ្រប់គ្នាកើតតក់ស្លុត
នៅខែពិសាខព្រះសម្ពុទ្ធ រលត់បញ្ចក្ខន្ធនាឆ្នាំម្សាញ់ ។
យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យកុំគ្នាន់ក្នាញ់
អ្នកប្រព្រឹត្តធម៌ឈ្មោះស្រឡាញ់ ចំពោះអង្គអញ្ញតថាគត ។
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំសាវតារនៃព្រះពុទ្ធ
គឺថ្ងៃខែឆ្នាំឲ្យហ្មត់ចត់ ទើបបានកំណត់ជាពុទ្ធជន ។

## គុណរបស់ទាន

ទានចិញ្ចឹមបុត្របរិសុទ្ធក្នុងផ្ទៃ រហូតដល់ថ្ងៃបុត្រថ្លៃចាកគភ៌
ទានចិញ្ចឹមស្មោះទឹកដោះបបរ កូនរស់បានល្អព្រោះធម៌សប្បុរស ។
ទានថ្វាយដល់សង្ឃផ្ទង់ឧទ្ទិសទាន ប្រេតរួចពីឃ្លានព្រោះទានរំដោះ
ទានជាទេវធម៌លម្អសប្បុរស ទានមានចិត្តស្មោះសង្គ្រោះជីវិត ។
ទានគឺជាទ្រព្យជាប់តាមសន្តាន ជាមិត្តរួមប្រាណឆ្លងភពងងឹត
ទានកាច់បំបាក់មោហៈក្នុងចិត្ត បានត្រាស់ដឹងពិតត្បិតទានបារមី ។
ហៃកូនប្រុសស្រីគប្បីចាំទុក គុណម្ដាយឪពុកទានាធិបតី
កូនដឹងមង្គល ៣៨ ចៀសកម្មអប្រិយផុតភ័យអបាយ ។

---

អគ្គបណ្ឌិត **ម៉ុត សាខឿ**

## ហេតុនាំឲ្យកើតបុណ្យមាន៣យ៉ាង

**១.បសាទោ** *មានចិត្តជ្រះថ្លា*

**២.សទ្ធោ** *មានសេចក្ដីតក់ស្លុត*

**៣.គេសុចរិតា** *ការប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត*

**បុណ្យ...**

បុណ្យនាំឲ្យបានកើតក្នុងឋានសួគ៌ បុណ្យជាគ្រឿងតែងតួយ៉ាងចំណាន
បុណ្យជាសេចក្ដីសុខដល់ខ្លួនប្រាណ បុណ្យជាលំអានដាននៃអ្នកប្រាជ្ញ ។

| | |
|---|---|
| បុណ្យជាឈ្មោះនៃសេចក្តីស្អាតល្អ | បុណ្យនាំបានស្មោះសររុងរឿងស្វាច |
| បុណ្យជាឫទ្ធិមានតេជៈអំណាច | បុណ្យជាគ្រឿងអាចដាក់ដល់និព្វាន។ |

(និពន្ធដោយ **ឈុំ នាយស្មេន**)

# សេចក្តីត្រិះរិះរបស់នាងវិសាខា

សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានថ្វាយទាន
នូវប្រាសាទថ្មីតាមទ្រព្យដែលមាន ជាវិហារទានថ្វាយចំពោះសង្ឃ ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានឱនអង្គ
ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់ ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាខ្ញុំបានថ្វាយភត្ត
ផ្សំដោយមំសៈធ្វើដោយហ្មត់ចត់ សាលាកភត្តជាអាហារទាន ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបព្រះទ្រង់ញាណ
ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន ថ្វាយចីវរទានសំពត់សាច់ល្អ ។
សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបសង្ឃបវរ
ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ ទឹកដោះគោល្អ និងទឹកអំពៅ ។
មកដល់ឥឡូវខ្ញុំបានសម្រេច គ្រប់មុខស្រេចបាច់ឥតមានសល់នៅ
ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ ក្នុងដំណើរទៅកាន់ព្រះនិព្វាន ។

---

អគ្គបណ្ឌិត **ប៊ុត សាវង្ស**

# ចែកបុណ្យដល់ទេវតា

ទេវតាទាំងឡាយ ដែលស្ថិតនៅលើផែនដីក្តី ស្ថិតនៅឰដ៏អាកាសក្តី នាគទាំងឡាយ ដែលមានឫទ្ធិច្រើនក្តី ព្រមទាំងស្តេចយមរាជ សក្កទេវរាជ សូមអនុមោទនា នូវបុណ្យរបស់យើងទាំងឡាយ ។

# ពុទ្ធសាសនាសូមតាំងនៅយូរអង្វែង

សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនា ផ្សាយទូទៅ

ពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធ ទ្រង់ត្រាស់ថា **នត្ថិ សន្តិបរំ សុខំ** ពុំមានសេចក្ដីសុខដទៃ ក្រៅអំពីសេចក្ដីស្ងប់ឡើយ ។

# ថ្ងៃពេញបូណ៌មីនៃព្រះគោតម

អហំខ្ញុំសូមតាំងប្រណម្យ ថ្វាត់ថ្វាយបង្គំព្រះមានព្រះភាគ
ទ្រង់យាងចុះមកប្រោសសត្វលោក ចាប់ផ្ទៃចូលមកចាប់គភ៌មាតា ។
នាមសិរិមហាមាយានារីរ័ត្ន ចំថ្ងៃល្អផុតព្រហស្បតិ៍ណា
ពេញបូណ៌មីអាសាធឆ្នាំរកា ក្នុងញាតិវង្សាសែនអររ៉ែក្រៃ ។
ថ្ងៃសុក្រពេញបូណ៌មីខែវិសាខ ឆ្នាំចទ្រង់ចាកចេញពីផ្ទៃ
មានផ្កាឈូកទ្រអស្ចារ្យក្រៃ ៧ជំហានមានន័យផុតលោកា ។
ចូលវ័យ១៦ទ្រង់មានឫទ្ធិ ឡើងគ្រងរាជ្យពិតអាទិត្យទិវា
ពេញបូណ៌មីកត្តិកឆ្នាំឆ្លូវណា ប្រជារាជការសុខកន្លង ។
ព្រះជន្មបាន២៩វស្សាគត់ ទ្រង់បានបុត្រារាហុលផង
កើតភ័យឈឺចាស់ស្លាប់ចាប់ចង ចោលពិម្ពារងទុក្ខខ្លោចផ្សា ។
ទ្រង់យាងកាន់ផ្នួសថ្ងៃព្រហស្បតិ៍ ១៥កើតស្មោះអាសាធណា
ត្រូវនឹងឆ្នាំថោះកើតបញ្ញា ឆ្លាតឈ្លាសស្រាវស្វែងរកធម៌ ។
អស់រយៈ៦វស្សាគត់ បានត្រាស់សម្ពុទ្ធល្បីលឺខ្ទរ
ថ្ងៃពុធពេញបូណ៌មីវិសាខល្អ រកាន់ះន៏សែនអស្ចារ្យ ។
បានត្រាស់ដឹងហើយមិនទំនេរ ទ្រង់គិតគ្នាន់គ្នេរដោះបញ្ហា
បំពេញពុទ្ធកិច្ច ៥ប្រការ រាល់ទិនទិវាឥតមានអាក់ ។
ពីរខែក្រោយទ្រង់បានត្រាស់ អាទិត្យសុទ្ធសឹងពេញបូណ៌មីជាក់
អាសាធរកាប្រោសបញ្ចវៈ គីយ៍ដោយធម្មចក្រកិច្ចតបស្នង ។
៧ ខែក្រោយមកទ្រង់ប្រទាន បាតិមោក្ខទូន្មានសាវ័កផង
ពេញបូណ៌មីខែមាឃល្អកន្លង ប្រតិបត្តិលើកជ្រោងពុទ្ធសាសនា ។
ពេញបូណ៌មីខែមាឃលើកទី២ ព្រះជន្មក្បែរទី៨០វស្សា
ទ្រង់ថ្លែងប្រាប់ទៅអានន្ទថា បីខែទៀតណា បាលាហើយ ។
អង្គារពេញបូណ៌មីខែវិសាខ ឆ្នាំម្សាញ់យើងចាកផុតភពត្រើយ

ចូលកាន់និព្វានគ្មានវិលឡើយ ណាអានន្ទអើយនៅសុខា ។
វីបុណ្យយើងខ្ញុំបានស្វាធ្យាយ ពេញបូណ៌មីពណ្ណរាយអង្គភគវា
សូមបានចាកផ្លុះព្រះធម្មា ទាន់ព្រះសិអារ្យយាងប្រោសសត្វ។
ម្យ៉ាងទៀតសូមឧទ្ទិសបុណ្យកុសល សូមឲ្យបានដល់ញាតិសព្វសត្វ
ក្នុងសង្សារវដ្តផុតវិបត្តិ កាយស្ងប់ចិត្តស្ងាត់កុំបីហ្មង ។

| |
|---|
| វាចាសត្យជាពាក្យមិនស្លាប់ពិត នាមគោត្រកិត្តិឥតស្លាប់សោះសា<br>ជនមិនប្រមាទមិនមរណា និព្វានឋានសុខាមិនចាស់ស្លាប់ ។ |

# ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ

(តាំងនមោ ៣ ចប់)

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃជាទីពឹងទីរលឹក ។ ខ្ញុំព្រះករុណាសូមក្រាបនមស្ការបូជាព្រះគុណនៃអង្គសម្មាសម្ពុទ្ធ ដែលទ្រង់ពេញពោរទៅដោយព្រះមេត្តាករុណា រកប្រមាណមិនបាន ។ ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាងក្នុងការសន្សំព្រះបារមីដើម្បីត្រាស់ហើយប្រកាសធម៌នាំវេនេយ្យសត្វចេញចាកពីវដ្តៈ ។ ខ្ញុំព្រះករុណាបូជាព្រះពុទ្ធចេតិយដោយសេចក្តីជ្រះថ្លាដ៏ក្រៃលែង សូមតាំងសច្ចាធិដ្ឋានដោយផលានិសង្សនៃបុណ្យដែលខ្ញុំព្រះករុណាបានធ្វើក្នុងថ្ងៃនេះ សូមជាបច្ច័យឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា ។ អង្គព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងធម៌យ៉ាងណា សូមឲ្យខ្ញុំព្រះករុណាមានចំណែកនៃធម៌របស់ព្រះអង្គក្នុងកាលដ៏សមគួរផងចុះ ។ ទោះបីកើតក្នុងភពជាតិណា សូមកើតនៅក្រោមម្លប់នៃព្រះពុទ្ធសាសនា កណ្តាលកល្យាណមិត្តបានសេពគប់នឹងសប្បុរសដែលជាអ្នកដឹងនូវធម៌ដ៏ប្រសើរ សូមជាបុគ្គលសម្មាទិដ្ឋិ មានឱកាសសិក្សាធម៌ ស្តាប់ធម៌ ប្រព្រឹត្តធម៌ ដែលជាបច្ច័យឲ្យចម្រើនទៅដោយសតិនិងបញ្ញាបញ្ជូនតទៅគ្រប់ជាតិ រហូតដល់ព្រះនិព្វានហោង ។ (ចម្លងចេញអីពីបូជនីយដ្ឋានព្រះពោធិព្រឹក្ស ព្រះពុទ្ធ២៨ ព្រះអង្គ)

# ទង់ព្រះពុទ្ធសាសនា

ទង់ព្រះពុទ្ធសាសនា មានពណ៌៦គឺ:

**១.ពណ៌ខៀវ** តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាស្តេចស្រីពិរាស្ត្រមានឥន្ទ្រព្រាហ្មណ៍ មកសុំព្រះនេត្រទាំងគូរបស់ព្រះអង្គ ។

**២.ពណ៌លឿង** តំណាងកាលព្រះពុទ្ធយោនយកកំណើតជាវិនិបណ្ឌិត មានព្រះឥន្ទ្រនិមិត្តធ្វើជា ជាងទងមកសុំសាច់ព្រះអង្គ ដើម្បីបិតបំពេញរូបបដិមាដែលខ្វះខាត ។ វិនិបណ្ឌិតបានកាត់សាច់របស់ខ្លួនឲ្យជាងទងនោះ យកទៅច្នៃប្រើតាមបំណង ។

**៣.ពណ៌ក្រហម** តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាមាណពឈ្មោះ បទុមកុមារមានមាតាត្រូវពស់ចឹកជិតមរណា ហើយត្រូវពេទ្យប្រាប់ថា មានតែឈាមចេញពីបេះដូងមនុស្សមួយមុខគត់ ដែលអាចព្យាបាលជម្ងឺបែបនេះបាន។ បទុមកុមារសុខចិត្តបូជាបេះដូងរបស់ខ្លួន ដើម្បីបិតពិសពស់ខាំមាតាឲ្យមានជីវិតរស់ឡើងវិញ ។

**៤.ពណ៌ស** តំណាងកាលព្រះពុទ្ធយោនយកកំណើតជាវេស្សន្តរ ហើយបានឲ្យដំរីស (បច្ច័យនាគ) ជាទានដល់ព្រាហ្មណ៍ ។

**៥.ពណ៌ទាខ្សបាន** តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាវិជ្ជាធរមានយក្សមកចាប់មាតាយកទៅ ។ វិជ្ជាធរក៏បានអារសាច់របស់ខ្លួនឲ្យយក្សស៊ី ដើម្បីលោះយកមាតាមកវិញ ។

**៦.ពណ៌ឥន្ទធនូ** (ពណ៌ផ្លេកចម្រុះ) តំណាងកាលព្រះពុទ្ធយោនយក កំណើតជាសត្វទន្សាយ មានឥន្ទ្រព្រាហ្មណ៍មកសុំសាច់ជាអាហារ ។ ទន្សាយពោធិសត្វឲ្យសាច់ជាទានដល់ឥន្ទ្រព្រាហ្មណ៍ដោយលោតចូលទៅក្នុងភ្នក់ភ្លើង ។

## អនុមោទនារភ្វាយាចនគាថា

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ**

សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ប្រកបព្រមហើយដោយ ហិរិ និង ឱត្តប្បៈ (ថែមទាំង) មានចិត្តចុះស៊ប់ចំពោះធម៌មានពណ៌ស (គឺសុចរិតធម៌) ។ អ្នកប្រាជ្ញទាំងឡាយលោកឲ្យនាមថា អ្នកមានទេវធម៌ក្នុងលោក ។

**សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មឹ ជិនសាសនេ**
**កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ**

បុគ្គលឯណា បានស្តាប់នូវព្រះសទ្ធម្មរបស់សាស្តា(ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅ នៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**ឯសានិសំសោ ធម្មេ សុចិណ្ណេ**
**ន ទុគ្គតឹ គច្ឆតិ ធម្មចារីតិ ។**

សេចក្តីថា មានតែធម៌ប៉ុណ្ណោះទេ តែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំល្អហើយ តែងនាំសេចក្តីសុខមកឲ្យ នេះជាអានិសង្សនៃធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិឡើយ ។

# បុរាណភាសិត

**ពុទ្ធោតិលោកទីបោវ** សត្វលោកផ្ញើលភ្ញាក់ពីព្រោះអាស្រ័យប្រទីបពន្លឺគឺព្រះពុទ្ធថ្លៃ ឲ្យលោកទាំងបីបានឃើញផ្លូវពិត ។

**ពុទ្ធោ សុរិយោ តមោនុទោ** ព្រះពុទ្ធបីដូចព្រះអាទិត្យបំបាត់ងងឹតឲ្យឃើញផ្លូវត្រូវ។

**យេ យន្តិ សរណំ ពុទ្ធំ** សត្វណាបានតាំងចិត្តតម្កល់នៅ យកគុណព្រះពុទ្ធជាទីពឹងទៅ ប្រព្រឹត្តជាប់នៅក្នុងអង្គអាត្មា **នត្ថិ តេសំ ទុក្ខំ សទា** សត្វណាភាវនាដោយចិត្តជ្រះថ្លា សត្វនោះនឹងបានក្សេមក្សាន្តចិន្តា រួចពីទុក្ខាគ្រប់កាលទាំងពួង ។

**ធម្មោតិលោកទីបោវ** សត្វលោកផ្ញើលភ្ញាក់ព្រោះអាស្រ័យ ប្រទីបពន្លឺគឺព្រះធម៌ថ្លៃ ឲ្យលោកទាំងបីបានឃើញផ្លូវពិត ។

**ធម្មោ សុរិយោ តមោនុទោ** ព្រះធម៌បីដូចជាព្រះអាទិត្យ បំបាត់ងងឹតឲ្យឃើញផ្លូវត្រូវ ។

**យេ យន្តិ សរណំ ធម្មំ** សត្វណាបានតាំងចិត្តតម្កល់នៅ យកគុណព្រះធម៌ជាទីពឹងទៅ ប្រព្រឹត្តជាប់នៅក្នុងអង្គអាត្មា **នត្ថិ តេសំ ទុក្ខំ សទា** សត្វណាភាវនាដោយចិត្តជ្រះថ្លា សត្វនោះនឹងបានក្សេមក្សាន្តចិន្តា រួចពីទុក្ខាគ្រប់កាលទាំងពួង ។

**សង្ឃោតិលោកទីបោវ** សត្វលោកផ្ញើលភ្ញាក់ព្រោះអាស្រ័យ ប្រទីបពន្លឺគឺព្រះសង្ឃថ្លៃ ឲ្យលោកទាំងបីបានឃើញផ្លូវពិត ។

**សង្ឃោ សុរិយោ តមោនុទោ** ព្រះសង្ឃបីដូចជាព្រះអាទិត្យ បំបាត់ងងឹតឲ្យឃើញផ្លូវត្រូវ ។

**យេ យន្តិ សរណំ ធម្មំ** សត្វណាបានតាំងចិត្តតម្កល់នៅ យកគុណព្រះសង្ឃជាទីពឹងទៅ ប្រព្រឹត្តជាប់នៅក្នុងអង្គអាត្មា។

**នត្ថិ តេសំ ទុក្ខំ សទា** សត្វណាភាវនាដោយចិត្តជ្រះថ្លា សត្វនោះនឹងបានក្សេមក្សាន្តចិន្តា រួចពីទុក្ខាគ្រប់កាលទាំងពួង ។

## ធាតុចេតិយនមស្ការគាថា

**មហាគោតមសម្ពុទ្ធោ　　កុសិនារាយ និព្វុតោ**
**ធាតុវិត្ថារកំ　កត្វា　　តេសុ តេសុ វិសេសតោ**

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ សារីរិកធាតុ ព្រះមហាគោតម ដែលទ្រង់និព្វាន ក្រោមសាលព្រឹក្សធំ ជិតបុរីរម្យ ក្រុងកុសិនារា ។ កិរិយាផ្សាយនូវព្រះធាតុនានា ផ្សេងៗពីគ្នាក្នុងទីទាំងឡាយ ខ្ញុំសូមបង្គំ ប្រណម្យក្រាបថ្វាយ ព្រះធាតុទាំងឡាយគ្រប់ទៅនោះៗ។

**ឧណ្ហីសំ ចតស្សោ ទាឋា　　អក្ខកា ទ្វេ ច សត្តមា**
**អសម្ភិន្នាវ តា សត្ត　　សេសា ភិន្នា វ ធាតុយោ**

ព្រះបរមសារីរិកធាតុ ល្អស្អាតទាំងឡាយ ដែលមិនបែកសោះប្រាំពីរព្រះអង្គ គឺព្រះឧណ្ហីសៈធាតុបញ្ចង់ មានមួយព្រះអង្គ នៅគង់ល្អស្អាត និងព្រះទាឋា សារីរិកធាតុទាំង៤អង្គស្អាត គ្មានឃ្លាតបែកចេញ ព្រះអក្ខកធាតុ នៅស្អាតពេញលេញ គ្មានបែកបាក់ចេញ ទាំងពីរព្រះអង្គ ព្រះសារីរិកធាតុ ភ្លឺស្អាតត្រចង់ ប្រាំពីរព្រះអង្គ គង់នៅទាំងអស់ ព្រះសារីរិកធាតុ ដ៏សេសពីនោះ បែកចេញចំពោះ បំណែកធំតូច

**មហន្តា បញ្ច នាឡី ច　　មជ្ឈិមា ច ឆ នាឡិយោ**
**ខុទ្ទកា បញ្ច នាឡី ច　　សម្ភិន្នា តេ ធាតុមតា**

ព្រះបរមធាតុ មុនីនាថសាស្តា ដែលបែកចេញជា ចំណែកតូចធំ លោកបានពោលទុកថាមានទំហំ មានតូចមានធំ មានខ្នាតកណ្តាល ។ ព្រះធាតុខ្នាតធំ ចំនួនប្រាំនាឡិ ព្រះធាតុកណ្តាល ប្រាំមួយនាឡិគត់ ព្រះធាតុខ្នាតតូច ប្រាំនាឡិប្រាកដ តាមលោកកំណត់បីយ៉ាងដូច្នេះ ។

**មហន្តា ភិន្នាមុគ្គា ច　　មជ្ឈិមា ភិន្នតណ្ឌុលា**

**ខុទ្ទកា សាសបមត្តា ឯទំ ធាតុប្បមាណិកា**

ឯព្រះបរមធាតុ មានខ្នាតបីយ៉ាង លោកបានពោលអាង ទុកជាលំដាប់ ព្រះធាតុខ្នាតធំ ទំហំប៉ុនគ្រាប់ សណ្តែកបាយកាប់ កាត់មួយកំណាត់ ។ ព្រះធាតុខ្នាតកណ្តាល ដូចកាលគេកាត់ ប៉ុនមួយកំណាត់ នៃគ្រាប់អង្ករ ព្រះធាតុខ្នាតតូច ល្អិតល្អបវរ លោកបានព្យាករណ៍ ថាប៉ុនគ្រាប់ស្ពៃ ។

**មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា**
**ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ**

ព្រះសារីរិកធាតុ នៃព្រះភគវា មានពណ៌ផ្សេងគ្នា ទាំងបីវិសាល ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ពន្លឺឱភាស វិសេសពេកក្តាត់ ។ ព្រះធាតុកណ្តាល វិសាលដូចរតន៍ កែវផ្លេកប្រាកដ ស្មើរចាប់ប្រទាំព្រះធាតុខ្នាតតូច ដូចផ្កាថ្កុលសម ពណ៌សស្រគាំ ពុំគួរងឿងឆ្ងល់ ។ ខ្ញុំសូមបង្គំ ប្រណម្យទៅដល់ ព្រះធាតុមង្គលទាំង ឡាយនោះផង តេជៈខ្ញុំថ្វាយឱនកាយរាបរង វាចាចិត្តផងសូមឆ្លងទៅដល់។
ទីព្រះបរមធាតុ មុនីនាថទសពល សូមជាមង្គល សុខសព្វវេលា សូមឲខ្ញុំបាន ដល់ឋានសួគ៌ា រហូតដល់នាព្រះនិព្វានហោង ។

**ឯកោ ទូបោ រាជគហេ ឯកោ វេសាលិយា អហុ**
**ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ**
**ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ**
**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ**

ព្រះសថូបមួយបាន ប្រតិស្ឋាននា រាជគ្រឹះភារា មហាបុរី មួយប្រតិស្ឋាន ក្រុងវេសាលី មួយនៅបុរី កបិលពស្តុសក្កៈ ។ ព្រះសថូបមួយនៅ អល្លកប្បកៈ ព្រះសថូបសោភៈ មួយនៅរាមគ្រាម មួយនៅវេដ្ឋ- ទីបកៈដោយនាម ពួកក្សត្រនិងព្រាហ្មណ៍ ទុកជាសរណៈមួយនៅនាក្រុង បាវេយ្យកៈ នៅក្នុងមល្លៈ រដ្ឋជនបទ ព្រះសថូបមួយមាន ទីឋានប្រាកដ នៅក្នុងរាជរដ្ឋ កុសិនារា ។

**ឯតេ សារីរិកា ថូបា ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។**

ព្រះសថូបទាំងឡាយ ទាំងប្រាំបីនោះ ជាទីបញ្ចុះ ព្រះសារីរិកធាតុ ក្នុងជម្ពូទ្វីប ខ្ញុំសូម អភិវាទ នូវព្រះបរមធាតុ ទាំងឡាយទាំងនោះ ។ ក្នុងព្រះសថូប ប្រាំបីអង្គស្មោះ ដែលពួកសប្បុរសលោកតែងបូជា ខ្ញុំសូមបង្គំប្រណម្យវន្ទា ទាំងមនុស្សទេវា បូជាសព្វកាល។

**ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ**
**ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ**

ព្រះទាឋាធាតុ មុនីនាថមួយអង្គ ប្រតិស្ឋានត្រង់ ក្នុងត្រៃត្រិង្សា ព្រះទាឋាធាតុ មួយអង្គថ្លៃថ្លា ប្រតិស្ឋាននា ពិភពនាគនាយ ។ ព្រះទាឋាធាតុ មួយអង្គព្រោងព្រាយ ឋិតនគរនាយ គន្ធាររដ្ឋ ព្រះទាឋាធាតុមួយអង្គប្រាកដ ឋិតនៅរាជរដ្ឋ សីហឡទ្វីប ។

**ឥមា ចតស្សោ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋាធាតុ ទាំងឡាយឯណា ដែលព្រះសាស្ដា ទ្រង់ប្រតិស្ឋានទាំងបួនកន្លែងនោះឯងមែនមាន ទ្រង់ទុកប្រទាន ឲ្យមនុស្សទេវតា។ ជាទីគោរព ប្រតិបត្តិបូជាខ្ញុំសូមវន្ទា ក្រាបថ្វាយបង្គំ អំពីចម្ងាយ ឱនកាយប្រណម្យ ចំពោះព្រះបរមធាតុនោះឯង។

**ឧទ្ធំ ទក្ខិណទាឋា ច តាវតឹសេ បតិដ្ឋិតា**
**អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា**
**វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា**
**វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋាធាតុ ខាងលើខាងស្តាំ ព្រះឥន្ទ្រានាំទៅត្រៃត្រិង្សា ព្រះទាឋាស្តាំខាងក្រោម សោភា ប្រតិស្ឋាននា សីហឡបុរី ។ ព្រះទាឋាឆ្វេង ខាងលើសិរសី នៅនាបុរីក្នុងដែនគន្ធារទាឋាឆ្វេងក្រោម នៃព្រះឈ្មោះមារនៅក្នុងភារា ពិភពនាគនោះ។
ខ្ញុំព្រះករុណា វន្ទាចំពោះ នូវព្រះធាតុនោះ គ្រប់ទីទាំងឡាយដែលមនុស្សទេព្តា តែងបូជាថ្វាយ ព្រះធាតុទាំងឡាយ ក្នុងទីនោះៗ។

**ព្រហ្មលោកេ ទុស្សធាតុ- វាមអក្ខកធាតុយោ**
**សព្វេ ព្រហ្មាតិបូជេន្តិ ថូបំ ទ្វាទសយោជនំ**

ព្រះទាឋាធាតុ មុនីនាថឧត្តម ដែលព្រះមហាព្រហ្ម ឈ្មោះឃដិការទទួលយកពី ព្រះសាស្តាចារ្យ ទៅទុកនមស្សការ នៅព្រហ្មលោក ។ និងអក្ខកធាតុឆ្វេង នៃព្រះមានជោគ នៅក្នុងព្រហ្មលោក ទាំងពីរព្រះអង្គមានព្រះសថូបកម្ពស់ខ្ពង់ខ្ពស់ ដប់ពីរយោជន៍លង់ បញ្ចុះព្រះធាតុ ។ ខ្ញុំសូមបង្គំ ព្រះបរមលោកនាថចំពោះព្រះធាតុនៅព្រហ្មលោកនាយ ។

**តាវត្តឹសម្ហិ ទេវានំ ចុឡាមណិម្ហិ កេសកំ**
**សព្វេ ទាវាតិបូជេន្តិ បសន្នា ពុទ្ធសាសនេ**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុតោ**

ទេវតាទាំងឡាយ ជាអ្នកជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បូជាចំពោះ នូវព្រះកេសធាតុព្រះបរមទ្រង់យស នៅក្នុងទីខ្ពស់ ឋានត្រៃត្រិង្សា។ ព្រះចូឡាមណី ចេតិយនោះណាខ្ញុំសូមវន្ទា ក្រាបថ្វាយបង្គំ ចំពោះព្រះធាតុ នៃព្រះបរម ទេវតាតូចធំ មូលមកបូជា ។

**ចត្តាឡីស សមា ទន្តា កេសា លោមា នខាបិ ច**
**ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទនូវព្រះទន្តធាតុ ទាំងសែសិបផង និងព្រះកេសធាតុ មុនីនាថជាចម្បង ព្រះលោមធាតុផង និងព្រះនខធាតុ ។ ដែលពួកទេវតា នាំគ្នាខ្មីឃ្មាត នាំយកព្រះធាតុ មួយអង្គៗ ទៅកាន់ចក្រវាឡ ដទៃពុំលង់ មួយអង្គៗ ក្នុងចក្រវាឡមួយខ្ញុំព្រះករុណា វន្ទាលើកស្ទួយ បង្គំមួយៗ គ្រប់ទាំងចក្រវាឡដែលពួកទេវតា មនុស្សាត្រអាល បូជាគ្រប់កាល ដោយក្តីជ្រះថ្លា ។

**អដ្ឋារសទ្ធេ វស្សសតេ ធម្មាសោកោ តទា អហុ**
**ចតុរាសីតិសហស្សា ចេតិយា ច ការាបិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

នាកាលព្រះពុទ្ធ សករាជបាន ដោយលោកពោលអាន ទុកជាកំណត់ ពីររយដប់ប្រាំ-បីឆ្នាំប្រាកដ នោះជាមហាក្សត្រ ព្រះនាមហៅថា ។ ព្រះធម្មាសោក ព្រះទ័យជ្រះថ្លា ក្នុងពុទ្ធសាសនា បានសាងចេតិយ ប្រាំបីម៉ឺនបួន ពាន់ធួនជាថ្មីថ្វាយព្រះជិនស្រី ក្នុង

ពុទ្ធសាសនា ។ ជាទីត្រេកអរ ទាំងមនុស្សទេព្តា តែងទៅបូជា ចេតិយទ្រង់យស ព្រោះមានព្រះធាតុប្រសើរខ្ពង់ខ្ពស់ជាទីអនុគ្រោះ ដល់មនុស្សទេព្តា ។ ខ្ញុំសូមបង្គំ ព្រះបរមសាស្តាចំពោះព្រះមហាព្រះធាតុទាំងឡាយនៅក្នុងចេតិយ ដែលស្តេចសាងថ្វាយ ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា តេជៈបារមី នៃព្រះភគវាទុក្ខរោគ

ភយា កុំបីកើតមាន សូមសុខសព្វកាល ត្រអាលក្សេមក្សាន្ត សម្បត្តិធនធាន ចម្រើនឥតអាក់ ព្រមទាំងកូនចៅ ញាតិផៅក្លើម្រាក់ កុំបីបែកបាក់និរាសព្រាត់ព្រាយក្នុងវង្សត្រកូល មូលមិត្តសប្បាយ សម្បត្តិទាំងឡាយ កុំបីខ្វះខាត ។

តាំងពីពេលនេះ រៀងៗរាល់ជាតិ កុំឲ្យឃ្លៀងឃ្លាត ពីក្តីប្រាថ្នាសូមឲ្យខ្ញុំបាន ដល់ឋានទេវតា និងព្រះមហា និព្វាននាយហោង ។

## វិធីបវារណារូបិយៈ(ប្រាក់)

បើទាយកមានប្រាថ្នាចង់លះរូបិយៈដើម្បីភិក្ខុ គប្បីជាអ្នកឈ្លាសឆ្លាតក្នុងកិច្ចបវរណាដោយវិធីបវារណាបច្ច័យ៤ ដែលលោកសម្តែងទុកក្នុងអដ្ឋកថា តតិយសមន្តប្បាសាទិកា (ទំព័រ៣២០ថា:)

**ទី១. ឥទំ ហិរញ្ញំ កប្បិយការកនំ ហត្ថេ ភវិស្សតិ តេវលំ តុម្ហេ(ចត្តារោ) បច្ចយេ បរិភុញ្ជថ** រូបិយវត្ថុមានចំនួន...មាននៅក្នុងដៃកប្បិយៈការកៈ (ឈ្មោះនេះ) សូមលោកម្ចាស់ប្រើប្រាស់ បច្ច័យ៤តែម្យ៉ាងចុះ ។ ក្នុងសង្កាត់ទី១នេះ ទាយកគប្បីយករូបិយវត្ថុទៅប្រគល់ឲ្យក្នុងដៃរបស់កប្បយការកៈ រួចទើបបវរណាចំពោះមុខភិក្ខុ។

**ទី២. ឥទំ ហិរញ្ញំ មម បុរិសានំ ហត្ថេ ភវិស្សតិ តេវលំ តុម្ហេ (ចត្តារោ) បច្ចយេ បរិភុញ្ជថ** រូបិយវត្ថុមានចំនួន......មាននៅក្នុងដៃនៃបុរសរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ប្រើប្រាស់បច្ច័យ៤តែម្យ៉ាងចុះ ។ ក្នុងសង្កាត់ទី២នេះ ទាយកគប្បីប្រគល់រូបិយវត្ថុនោះ ទៅឲ្យក្នុងដៃរបស់បុរសខ្លួន គឺមនុស្សដែលខ្លួនទុកចិត្តរួចបវារណាចំពោះមុខរបស់ភិក្ខុ ។

**ទី៣. ឥទំ ហិរញ្ញំ មយ្ហំ ហត្ថេ ភវិស្សតិ តេវលំ តុម្ហេ (ចត្តារោ) បច្ចយេ បរិភុញ្ជថ** រូបិយវត្ថុមានចំនួន...មាននៅក្នុងដៃរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ប្រើប្រាស់បច្ច័យ៤តែម្យ៉ាងចុះ ។ ក្នុងសង្កាត់ទី៣នេះ ទាយកគប្បីទុកដាក់រូបិយវត្ថុនោះដោយខ្លួនឯង ។

**សេចក្តីបញ្ជាក់:** ក្នុងកម្មវិធីបវារណាទាំង៣សង្កាត់នេះ ទាយកអាចបវរណា ដោយសង្កាត់ណាមួយក៏បានឥតមានទាស់ខុសអ្វីឡើយ ។ ប៉ុន្តែត្រូវយល់ឲ្យច្បាស់ថា ការបវារណាមិនមែនបានន័យថា ត្រូវយករូបិយវត្ថុនោះទៅប្រគេនចំពោះភិក្ខុទេ គឺ ក្រោយពីទាយកបានបវារណារួចហើយ ត្រូវប្រគល់រូបិយវត្ថុនោះ ឲ្យកប្បិយការកៈ ឬ បុរសដទៃ ឬទុកក្នុងដៃរបស់ខ្លួនពេលណាភិក្ខុត្រូវការដោយបច្ច័យណា ជនទាំងឡាយ មានកប្បការកៈជាដើមនោះ គប្បីដោះស្រាយបច្ច័យនោះ ដោយរូបិយវត្ថុនោះចុះ ។

## មហាផល ៩ យ៉ាង

❖ **ផ្លែឈើទាំង ៩នេះមិនគួរធ្វើទឹកភេសជ្ជៈទេគឺៈ**

១. **តាល** ផ្លែត្នោត

២. **នាឡិកេរ** ផ្លែដូង

៣. **បនស** ផ្លែខ្នុរ

៤. **សពុជ** ផ្លែខ្នុរសម្លូ

៥. **អលាពុ** ផ្លែឃ្លោក

៦. **កុម្ភណ្ឌ** ផ្លែល្ពៅ

៧. **បុស្សផល** ផ្លែឪឡឹក

៨. **តិបុស** ផ្លែត្រសក់

៩. **ឯឡាលុក** ផ្លែត្រឡាច ។

មហាផល និងអបរណ្ណជាតិគ្រប់ប្រភេទ មានគតិដូចជាធញ្ញជាតិដែរ មិនគួរធ្វើ ទឹកបាន[២]ទេ ជាការ ទ្រង់ហាមហើយ ។

*(បាករណ្ឌកថាខ្មែរ ភាគ៥/ទំព័រ៣៧៨,ភេសជ្ជក្ខន្ធកៈ)*

ពាក្យថា អបរណ្ណជាតិ បានដល់សណ្តែកបាយ និងសណ្តែករាជមាសជាដើម (សណ្តែក គ្រប់ប្រភេទ) ។

*(ចាករអដ្ឋកថាខ្មែរ ភាគ៣/ទំព័រ៥៨)*

## ធញ្ញជាតិបានដល់ស្រូវ ៧ ប្រភេទគឺៈ

**១. សាលិ** ស្រូវសាលី

**២. វិហិ** ស្រូវខ្សាយ

**៣. យវោ** ស្រូវដំណើប

**៤. គោធុមោ** ស្រូវស្រងែ

**៥. កង្គុ** ថ្លៅ

**៦. វរកោ** ពោត,ស្កួយ,ឬស្មៅកន្ទុយដំរី

**៧. កុទ្រូសកោ** ស្មៅគែលលក ។

*(សមន្តខ្មែរ/ភាគ ៥/ទំព័រ៣៧៣)*

## សមណកប្ប

## (របស់ដែលគួរដល់សមណៈ)

**១. អគ្គិបរិចិតំ** វត្ថុដែលចម្អិនដោយភ្លើង

**២. សត្ថបរិចិតំ** វត្ថុដែលចោះ ឬចិតដោយសស្ត្រា

**៣. នខបរិចិតំ** វត្ថុដែលចុចដោយក្រចក

**៤. អពីជំ** វត្ថុដែលគ្មានពូជ(ផ្លែខ្ចី)

**៥. និព្វដ្ដពីជំ** ផ្លែឈើដែលមានពូជតែបន្លេចគ្រាប់ចេញបាន។

(អដ្ឋកថាខ្មែរ ភាគ ៤ /ទំព័រ ៧២-៧៣)

## កិច្ចក្នុងវិន័យ

ភិក្ខុត្រូវប្រើសមណេរ ឬគ្រហស្ថឲ្យកាន់ផ្លែឈើ ដោយដៃម្ខាងហើយខ្លួនលោកកាន់ដៃម្ខាង ។ ភិក្ខុត្រូវពោលថា៖

**កប្បិយំ ករោហិ** (ប្រែថា: ) អ្នកចូរធ្វើរបស់នេះឲ្យគួរ សាមណេរ ឬគ្រហស្ថត្រូវពោលតបវិញថា **កប្បិយំ ភន្តេ** (ប្រែថា: ) គួរលោកម្ចាស់ ។

**ត្រូវចាំថា**

ហាមពោលថា គួរហើយលោកម្ចាស់ ឬក៏ពោលថា នឹងគួរហើយលោកម្ចាស់ ។

សាមណេរ ឬគ្រហស្ថ ត្រូវពោលឲ្យស្មើគ្នាជាមួយនឹងការចាក់ផ្លែឈើនោះថា គួរ លោកម្ចាស់ ។

(សារត្ថទីបនី ភាគ ៣/ទំព័រ ២៧)

## អង្គនៃការប្រគេន ៥ យ៉ាង

### អដ្ឋកថាពោលថា

**១. ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ** វត្ថុដែលបុរសមានកម្លាំងយ៉ាងកណ្តាលល្មមលើកឡើងបាន ។

**២. ហត្ថបាសោ បញ្ញាយតិ** ហត្ថបាសប្រាកដ ។

**មានវិនិច្ឆ័យដូច្នេះ៖**

២ ហត្ថ ១ ចំអាម គប្បីជ្រាបថា ហត្ថបាស បើភិក្ខុ អង្គុយកំណត់តាំងពីទីបំផុតផ្នែកខាងក្រោយ របស់អាសនៈទៅបើឈរកំណត់តាំងពីទីបំផុតផ្នែកកែងជើងទៅ បើដេកកំណត់តាំងពីទីបំផុតផ្នែកឆ្អឹងខ្នងដែលដេកទៅ ដោយហោចទៅ ផ្នែកខាងក្នុងនៃអវៈយវៈដែលជិតជាង វៀរដៃដែលលាតចេញ របស់ទាយក ដែលអង្គុយក្តី ឈរក្តី ដេកក្តី ។ ក៏បណ្តាលអ្នកឲ្យ និងអ្នកទទួលប្រគេនចំណែកមួយនៅលើអាកាស ចំណែកមួយនៅលើផែនដី គប្បីកំណត់ប្រមាណ ហត្ថបាស ខាងសីសៈ របស់អ្នកឈរលើផែនដី និងខាងក្នុងផ្នែកចុងនៃអវៈយវៈ ដែលជិតជាងរបស់អ្នកឈរលើអាកាស វៀរលែងតែដៃដែលលាតចេញ ដើម្បីប្រគេនឬដើម្បីទទួល ។ ប្រសិនបើថា មួយផ្នែកនៅក្នុងរណ្តៅ មួយផ្នែកទៀតនៅមាត់រណ្តៅ ឬមួយផ្នែកទៀតនៅលើដើមឈើ មួយផ្នែកទៀតនៅលើផែនដី ក៏គប្បីកំណត់ ប្រមាណហត្ថបាស ដោយន័យដូចពោលហើយមកនេះឯង ។

**៣. អភិហារោ បញ្ញាយតិ** ទាយកអ្នកប្រគេន បង្អោនចូលមកប្រាកដ ។

**៤. ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា កាយេន វា កាយបដិពទ្ធេន វា និស្សគ្គិយេន វា ទេតិ ។**

ទេវតាក្តី មនុស្សក្តី តិរច្ឆានក្តី ប្រគេនដោយកាយ ឬដោយវត្ថុជាប់ដោយកាយ ឬក៏ដោយការបោះឲ្យ ។

**៥. តំ ចេ ភិក្ខុ កាយេន វា កាយបដិពទ្ធេន វា បដិគ្គណ្ហាតិ ។** ចំណែកភិក្ខុវិញទទួលវត្ថុនោះ ដោយកាយ ឬដោយវត្ថុជាប់ដោយកាយ ។

(អដ្ឋកថាខ្មែរ ភាគ ៤ / ទំព័រ ២៤៨)

## ភិក្ខុធ្វើការចែកសប្បិរបស់សង្ឃ

## ឱ្យទៅជាបុគ្គល

*ក្នុងអដ្ឋកថាសេនាសនៈខន្ធកៈពោលថា*

បើមានទាយកគេថ្វាយសប្បិជាដើម ដល់សង្ឃ ត្រូវចែកគ្នាថា៖

**ឥទំ បិណ្ឌបាតោ មហាថេរស្ស បាបុណាតិ អវសេសំ អម្ហាកំ បាបុណាតិ ខជ្ជតិ ។**

សប្បិនេះ រមែងដល់ព្រះមហាថេរៈ សប្បិដែលនៅសល់ រមែងដល់ពួកយើង ដូច្នេះរមែងគួរ ។

(អដ្ឋកថាខ្មែរ ភាគ ៦/ ទំព័រ ២៥៤)

## ភិក្ខុធ្វើការចែកចង្ហាន់បិណ្ឌបាត

**អយំ បិណ្ឌបាតោ មហាថេរស្ស បាបុណាតិ អវសេសំ អម្ហាកំ បាបុណាតិ ។**

ចង្ហាន់បិណ្ឌបាតនេះ ជារបស់ព្រះមហាថេរៈ ចង្ហាន់បិណ្ឌបាតដែលនៅសល់ រមែងដល់ពួកយើង ។

## សាច់ទាំង១០យ៉ាង

### ដែលព្រះពុទ្ធទ្រង់ហាម

សាច់ដែលព្រះមានព្រះភាគ ទ្រង់ហាមឃាត់មិនឲ្យភិក្ខុសាមណេរឆាន់ លោកហៅថា **អកប្បិយមំសៈ** មានន័យថា សាច់ដែលមិនគួរ; អកប្បិយមំសៈនោះ មាន ១០ យ៉ាង គឺ៖

១. **មនុស្សមំសំ** សាច់មនុស្ស

២. **ហត្ថិមំសំ** សាច់ដំរី

៣. **អស្សមំសំ** សាច់សេះ

| | |
|---|---|
| ៤. **សុនខមំសំ** | សាច់ឆ្កែ |
| ៥. **អហិមំសំ** | សាច់ពស់ |
| ៦. **សីហមំសំ** | សាច់រាជសីហ៍ |
| ៧. **ព្យគ្ឃមំសំ** | សាច់ខ្លាធំ |
| ៨. **ទីបិមំសំ** | សាច់ខ្លាដំបង |
| ៩. **អច្ឆមំសំ** | សាច់ខ្លាឃ្មុំ |
| ១០. **តរច្ឆមំសំ** | សាច់ខ្លារខិន |

សាច់ទាំង ១០ យ៉ាងនោះ ភិក្ខុសាច់មនុស្ស ត្រូវអាបត្តិថុល្លច្ច័យ ចំណែកសាច់ ៩ យ៉ាងទៀត ត្រូវអាបត្តិទុក្កដ ។ក្នុងអដ្ឋកថា លោកពន្យល់ដូច្នេះ៖

**ឥតិ ឥមេសំ មនុស្សាទីនំ ទសន្នំ មំសម្បិ អដ្ឋិបិ លោហិតម្បិ ចម្មម្បិ លោមម្បិ សព្វំ ន វដ្ដតិ ។**

សាច់ក្តី ឆ្អឹងក្តី ឈាមក្តី ស្បែកក្តី រោមក្តី របស់សត្វទាំង ១០ យ៉ាង មានមនុស្សជាដើមនេះ មិនគួរទាំងអស់ ដោយប្រការដូច្នេះ ។

**យង្កិញ្ចិ ញត្វា វា អញត្វា វា ខាទន្តស្ស អាបត្តិយេវ ។**

កាលភិក្ខុដឹងក៏ដោយ មិនដឹងក៏ដោយ ឆាន់សាច់យ៉ាងណានីមួយ ( ក្នុងសាច់ទាំង ១០ ) រមែងត្រូវអាបត្តិដោយពិត ។

ម្យ៉ាងទៀត *ភិក្ខុមិនទាន់បានពិចារណាជាមុន មិនត្រូវឆាន់សាច់* បើឆាន់ត្រូវអាបត្តិទុក្កដ មានពុទ្ធប្បញ្ញត្តថា៖

**ន ច ភិក្ខវេ អប្បដិវេក្ខិត្វា មំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស** “ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានពិចារណាជាមុនហើយ មិនត្រូវឆាន់សាច់ទេ ភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ”

ពាក្យថា មិនបានពិចារណាជាមុន ហើយឆាន់សាច់ ក្នុងអដ្ឋកថាលោកបានពន្យល់ ដូច្នេះ

**អប្បដិវេក្ខិត្វាតិ អប្បដិបុច្ឆិត្វា; សចេ បន អសុក មំសន្តិ ជានាតិ បដិបុច្ឆនកិច្ចំ នត្ថិ អជានន្តេន បន បុច្ឆិត្វាវ ខាទិតព្វំ ។**

បទថា **អប្បដិវេក្ខិត្វា** ( មិនទាន់បានពិចារណា ) បានដល់ មិនទាន់សាកសួរ ប្រសិនបើភិក្ខុដឹងថា នេះជាសាច់អ្វី កិច្ចដែលនឹងត្រូវសាកសួរ រមែងមិនមាន តែកាលមិនដឹង ( មិនស្គាល់ ) ត្រូវសាកសួរជាមុនសិន សឹមឆាន់ ។

## រំលឹកគុណព្រះពុទ្ធ

ខ្ញុំសូមរំលឹកគុណ សរសើរបុណ្យព្រះជិនស្រី
កាលស្តេចចាប់បដិ- សន្ធិផ្ទៃមាតា ។
បវរព្រះកន្លោង មាតាហោងឆ្នាំរកា
នាខែអាសាធណា ថ្ងៃព្រហស្បតិ៍ពេញបូណ៌មី ។
នាកាលព្រះពោធិសត្វ ប្រសូតថ្វាត់ចេញចាកផ្ទៃ
នៅក្នុងឆ្នាំចនៃ ខែពិសាខពេញបូណ៌ជ្រះ ។
ថ្ងៃសុក្រឯថ្ងៃត្រង់ ខំតម្រង់ចិត្តឲ្យណាស់
ទន្លេញឲ្យចាំច្បាស់ ថ្វាយបង្គំយកបុណ្យទៅ ។
នាកាលព្រះពោធិសត្វ ស្តេចទ្រង់កាត់ព្រះទ័យគិត
ទ្រង់ចេញព្រះផ្នួសពិត ឆ្នាំថោះខែអាសាធហោង ។
ថ្ងៃព្រហស្បតិ៍សម្តី ពេញបូណ៌មីជាក់ជាម្តង
ឲ្យអស់ទាំងអ្នកផង ដឹងកំណើតព្រះពោធិ ។
នាកាលពោធិសត្វ ទ្រង់បានត្រាស់ឆ្នាំរកា
ថ្ងៃពុធប្រាកដជា ខែវិសាខពេញបូណ៌មី ។
នាកាលពោធិញាណ ចូលនិព្វានក្នុងឆ្នាំម្សាញ់
នាខែវិសាខពេញ បូណ៌មីថ្ងៃអង្គារ ។

ត្រូវទាំងយាមអង្គារ ខំឧស្សាហ៍សូត្ររៀនរក
ទន្ទេញឲ្យចាំយក ថ្វាយបង្គំបានបុណ្យណាស់ ។
ព្រោះហេតុដឹងកំណើត ព្រះអង្គកើតនោះជាក់ច្បាស់
ទាំងបួសទាំងបានត្រាស់ ទាំងចូលព្រះនិព្វានហោង ។

## អានិសង្សអដ្ឋសីល

ខ្ញុំសូមឱនកាយ លើកហត្ថឡើងថ្វាយ បង្គំវន្ទា
រលឹកព្រះគុណ សម្តេចភគវា សូមជួយឈ្នះមារ
សត្រូវទាំងឡាយ ។
គុណសីលទាំង៥ សូមជួយថែទាំ បិទបាំងរាងកាយ
គុណសីលទាំង៨ រស្មីព្រោងព្រាយ ជួយបាំងអបាយ
ភូមិភ័យនរក ។
គុណសីលទាំង១០ មូលមកប្រសព្វ សូមជួយដោះទុក្ខ
កុំឲ្យខ្ញុំយល់ ពីឋាននរក ជាងជួយឲ្យសុខ
បរលោកលោកិយ ។
កុំឲ្យមានហ្មង អស់សត្រូវផង ខ្ទបខ្ទាចបារមី
គុណសីលទ្រទ្រង់ គ្រប់គ្រងសព្វថ្ងៃ រៀងរាល់ជាតិនៃ
កុំឃ្លាតឡើយហោង ។

---

## ធម៌ឧទ្ទិសទាន

រីកុសលទានសីល ខ្ញុំសូមផ្តាច់ផ្តិល មន្ទិលទោសា
ថ្វាយទានថ្មីៗ ដោយក្តីជ្រះថ្លា ដោយកាយវាចា
ចិត្តឥតហ្មងសៅ ។
កុសលទាំងនោះ ខ្ញុំសូមឧទ្ទិស ចំពោះជូនទៅ
មាតាបិតា គ្រូអាចារ្យពង្សផៅ ទោះស្លាប់រស់នៅ
បានដូចបំណង ។

កុសលទាំងនេះ ទុកជាជំនិះ ជិះកាត់ចម្លង
ឲ្យរួចផុតទុក្ខ ទាំងជប់ពីរកង សោយសុខកន្លង
ដល់ឋានព្រះនិព្វាន។

## សុមង្គលគាថា

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចម្រើនដ៏គ្រប់យ៉ាងចូរមានដល់ខ្ញុំ
**រក្ខន្តុ សព្វទេវតា** ទេវតាទាំងឡាយចូររក្សានូវខ្ញុំ
**សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ
**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង
**សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង
**សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឲ្យបានគ្រប់ពេលកុំបីចន្លោះឡើយ។

## យំកិញ្ចិ

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចា មនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុតេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ នជានន្តិ ទេវាគន្ត្វា និវេទយុំ សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ។**

*ប្រែថា:* **យំកិញ្ចិ កុសលកម្មំ កិរិយំ មម** អំពើជា កុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន វាចា មនសា** ដោយទ្វារទាំងបីគឺកាយ វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងឱ្យទៅកើតក្នុងស្ថានត្រៃត្រឹង្សសួគ៌បាន **យេ សត្តា អសញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្សឬទេវតាទាំងឡាយ ឬព្រហ្មដែលជាសត្វមាន សញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណាជាអញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី
**កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុតេ** សត្វទាំងឡាយទាំងអស់នោះចូរ ឱ្យបាននូវចំណែក បុណ្យ ហើយចូរសោយនូវផលបុណ្យ ដែលខ្ញុំបាន ធ្វើហើយ បានឧទ្ទិស

ផ្សាយឱ្យទៅនេះចុះ **យេតំ កតំ សុវទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបាន ធ្វើហើយនោះ បើសត្វទាំងឡាយឯ ណាបានដឹងច្បាស់ ហើយសត្វទាំងឡាយនោះចូរឱ្យបានសោយ នូវផលបុណ្យដែលខ្ញុំបាន ឧទ្ទិសឱ្យទៅនោះចុះ **យេច តត្ថ នជានន្តិ** ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើជាសត្វ ទាំងឡាយឯណាមិនបានដឹងនូវ បុណ្យដែលខ្ញុំបានធ្វើហើយ នោះ **ទេវា គន្ទា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅអោយដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផងថា ជន ឯណោះគេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយផលបុណ្យនោះដល់អ្នកទាំងឡាយៗ ចូរអនុ មោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំង ឡាយឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាទាំងអស់នោះចូរឱ្យបាននូវ ភោជនជាទី គាប់ចិត្តដែល សម្រេចដោយបញ្ញប្ញទ្ធិតាមចិត្តខ្ញុំដែល ឧទ្ទិសផ្សាយទៅឱ្យនេះចុះ។

(*បត្តិទានគាថានេះ សំរាប់សូត្របានក្នុងទីទាំងពួងក្នុងកាលដែលធ្វើកុសលអ្វីមួយហើយស្រេច*)

## បត្តិទានគាថា

**យា ទេវតា សន្តិ វិហារវាសនី ថូបេ យរេ ពោធិយរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី ឧបាសកា គាមា ច ទេសា និគមា ច ឥស្សរា សប្បាណភូតា សុខិតា ភវន្តុ តេជលាពុជាយេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកានិយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ។**

**ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍី សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ។**

*ប្រែថា:* **យា ទេវតា សន្តិ វិហារវាសនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយ ឯណាមានប្រក្រតីនៅក្នុងទី វត្តជាទីនៅនៃសង្ឃឮដ៏ខឿនព្រះសថូប ឮដ៏ខឿនព្រះពោធិព្រឹក្ស ក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គល គឺយើងទាំងឡាយបូជាហើយ ដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្ត ជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយ ជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសក និងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែល ជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរជនធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឲ្យ បានដល់នូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យ នូវធម៌ដ៏ប្រសើរ ជានិយ្យនិកធម៌ហើយ ចូរធ្វើនូវធម៌ ជាគ្រឿង អស់ទៅនៃសេចក្តីទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឲ្យធម៌របស់សប្បុរសទាំងឡាយ ស្ថិតនៅអស់កាលយូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ) **សង្ឃោ ហោតុ សមគ្គោ វ** សូមព្រះសង្ឃព្រម ព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចំរើនផង ដើម្បីសេចក្តីសំរេច ផលប្រយោជន៍ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្ត ធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍឹ សម្បាបុណោ យ្យាម ធម្មារិយប្បវេទិតេ** សូមយើងទាំងឡាយ បានដល់នូវសេចក្តីចំរើនក្នុងធម៌ ដែលព្រះអរិយទាំងឡាយលោកសំដែងហើយ។

(បត្តិទានគាថានេះ សំរាប់សូត្រចំពោះតែក្នុងទីវត្តអារាមក្នុងកាលដែលចប់ធម៌ទេសនា ឬ ក្នុងវេលាដែលសូត្រធម៌ណាចប់ហើយ។)

# **ឥមិនាបុញ្ញកម្មេ**

**ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា អាចរិយូបការា**

**ច មាតាបិតា ច ញាតកា (បិយា មមំ) សុរិយោ ចន្ទិមា**

**រាជា គុណវន្តា នរាបិ ច ព្រហ្មមារា ច ឥន្ទ្រា ច លោកបាលា**

**ច ទេវតា យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច**

**សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ សុខញ្ច**

**តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។**

*ប្រែ:* ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ អាចារ្យទាំងឡាយ មានឧបការៈ មាតាបិតានឹងញាតិទាំងឡាយ (មាតាបិតាជាទីស្រឡាញ់) ព្រះអាទិត្យ ព្រះចន្ទ ព្រះរាជា នរជនអ្នកមានគុណទាំងឡាយ ព្រះព្រហ្មនិងមារាធិរាជ ព្រះឥន្ទទាំងឡាយ លោកបាលមហារាជ និងទេវតាទាំងឡាយ ព្រះយមរាជនិងមនុស្សទាំងឡាយ ជាមិត្តនឹងគ្នាក្តី មានចិត្តជាកណ្តាលក្តី មានពៀរនឹងគ្នាក្តី សូមឲ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នាបុណ្យទាំង ឡាយ ដែលខ្ញុំបានកសាងសន្សំហើយ ចូរឲ្យនូវសេចក្តីសុខទាំង៣ប្រការ សូមឲ្យអ្នកទាំងឡាយបានដល់នូវ អមត មហានិព្វាន ឲ្យបានឆាប់រួសរាន់ទាន់សេចក្តីប្រាថ្នាហោង ។

**ឥមិនា បុញ្ញកម្មេ ឥមិនា ឧទ្ទិសេន ច ខិប្បាហំ សុលភេ ចេវ**

**តណ្ហុបាទានឆេទនំ យេ សន្តា នេ ហីនា ធម្មា យាវ និព្វាន**

**តោ មមំ នស្សន្តុ សព្វទា យេវ យត្ថ ជាតោ ភវេ ភវេ ឧជុចិត្ត**

**សតិបញ្ញា សល្លេខោ វិរិយម្ហិនា មារា លភន្តុ មោកាសំ (នោ**

**កាសំ) កាតុញ្ច វិរិយេសុ មេ ពុទ្ធោ ទីបវរោ នាថោ ធម្មោ នា**

**ថោ វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ**

**តេសោត្តមានុភាវេន មារោកាសំ លភន្តុ មា ។**

*ប្រែ:* ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឲ្យខ្ញុំបានដោយងាយយ៉ាងរួសរាន់ទាន់ចិត្ត នូវមគ្គផលជាគ្រឿងផ្តាច់បង់ នូវតណ្ហានិងឧបាទាន ធម៌ទាំងឡាយណា ជាធម៌ថោកទាប គឺអកុសលធម៌នៅក្នុងសន្តានចិត្តខ្ញុំ សូមឲ្យវិនាសបាត់រៀងរាល់កាលទៅ រហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន បើខ្ញុំអន្ទោលទៅចាប់កំណើត ក្នុងភពតូចនិងភពធំ ណា ៗ សូមឲ្យខ្ញុំជាបុគ្គលមានចិត្តត្រង់មានសតិបញ្ញាមានចិត្តស្អាតផូរផង់ ទាំងសូមឲ្យមានព្យាយាមផង មារទាំងឡាយចូរកុំបាននូវឱកាស ដើម្បីធ្វើឲ្យខូចព្យាយាមខ្ញុំឡើយ ព្រះពុទ្ធដូចជាប្រទីបឬកោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាទីពឹង ដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេក

ពុទ្ធ ក៏ជាទីពឹងនៃខ្ញុំដែរ ដោយឧត្តមានុភាព នៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃនោះ មារចូរកុំបាននូវឱកាស ចូលមកជ្រៀតជ្រែកឡើយ ។

(**គិហិបដិបត្តិពិសេស**)

## យំកិញ្ចិ

(*ប្រែកាព្យមួយបែប*)

បុណ្យដែលខ្ញុំបានធ្វើហើយ ព្រះគុណអើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឲ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា នាំផលាទាំងអស់នេះ ។
ទៅជូនឲ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណោះ មិនប្រហែសបញ្ជូនមក ។

សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកគ្រប់ៗគ្នា ។
ដើម្បីសោយផលទាន ទទួលបាននូវសុខជា
កូនចៅទាំងអស់គ្នា សូមបូជាជូនទៅហោង ។

## យំកិញ្ចិមួយបែបទៀត

កុសលកម្មតិចតួចឯណា ដែលចិត្តជ្រះថ្លាហើយខ្ញុំបានធ្វើ
ដោយកាយវាចាចិត្តខ្ញុំអើពើ គួរនាំទៅលើកើតឋានត្រៃត្រិង្ស ។
សត្វមានសញ្ញាឯណាបានដឹង បុណ្យដែលខ្ញុំខំប្រឹងខំធ្វើនេះក្តី
សូម្បីពួកសត្វជាអសញ្ញី ក៏ខ្ញុំគប្បីចែកបុណ្យនេះឲ្យ ។
ថាពួកសត្វនោះមិនដឹងហើយ ក៏សូមឲ្យទេវតាមានឫទ្ធិ
អញ្ជើញទៅប្រាប់ទៅដាស់តឿនចិត្ត ដោយក្តីអាណិតសត្វក្នុងលោកា ។
ឲ្យបានដឹងហើយដោយចិត្តមេត្តា ត្រេកអរគ្រប់គ្នាក្នុងលោកទាំងមូល
សូមមានអាហាររស់នៅដោយស្រួល ដោយបានទទួលផលបុណ្យនេះហោង ។

📖📖📖

**ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា**
**សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ**
**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។**

ព្រះសុរិយារុងរឿងពេលថ្ងៃ ចន្ទពេញបូណ៌មីរុងរឿងពេលយប់
អង្គក្សត្រទ្រង់គ្រឿងរុងរឿងនរប្តី អ្នកចូលឈានគ្រប់រុងរឿងសាសនា ។
ព្រះពុទ្ធរុងរឿងដោយតេជៈបុណ្យ តេជៈនៃគុណតេជៈសីលា
តេជៈព្រះធម៌តេជៈបញ្ញា រុងរឿងអស្ចារ្យទាំងយប់ទាំងថ្ងៃ ។

## បេរកឋិនទាន

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** (៣ដង)

*(ចាំតាម គ្រូ-អាចារ្យ)*

**មយំ ភន្តេ ឥមំ កឋិនចីវរំ សានិសំ សំ សង្ឃស្ស ទេម សាធុ នោ**
**ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសំ សំ កឋិនំ អត្ថរិតុំ បដិគ្គណ្ហាតុ**

**មាតាបិតុ អាចិនញ្ញេច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...។ តតិយម្បិ...។**

បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើ្វយ យើងខ្ញុំព្រះករុណាទាំងឡាយ សូមវេរនូវសំពត់នេះជាសំពត់ដើម្បីកឋិនចីវរ ព្រមទាំងអានិសង្សលាភចំពោះព្រះសង្ឃ ។ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើ្វយ សូមព្រះសង្ឃមេត្តាទទួលយកនូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភរបស់យើងខ្ញុំទាំងឡាយ ដើម្បីក្រាលកឋិន ដើម្បីសេចក្តីចម្រើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាយូរអង្វែងទៅហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

## ពាក្យវេរសេនាសនៈថ្វាយ

## ចំពោះព្រះសង្ឃ

បុគ្គលដែលមានសទ្ធាបានកសាងសេនាសនៈរួចហើយ បើមានប្រាថ្នាវេរថ្វាយសង្ឃគប្បីប្រតិស្ឋានសេនាសនៈនោះ សម្រាប់សង្ឃដែលបានមកហើយ និងមិនទាន់បានមកអំពីទិសទាំងបួន ។ ហើយពោលថ្វាយដោយពាក្យថា៖

(**ឱកាស!**) **មយំ ភន្តេ** (**ឥមំ សេនាសនំ**) **អាគតានាគតស្ស ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម ។**

(ខ្ញុំសូមគោរព!) បពិត្រព្រះសង្ឃដ៏ចម្រើនយើងខ្ញុំព្រះករុណាទាំងឡាយ សូមថ្វាយនូវសេនាសនៈ នេះដល់ភិក្ខុសង្ឃ ដែលបានមកហើយ និង មិនទាន់បានមកអំពីទិសទាំង ៤ ។

បើប្រាថ្នានឹងវេរសាលាក្តី កប្បិយកុដិក្តី កុដិតូចក្តី ឬកុដិធំ បង្គន់ក្តី កុដិតូបក្តី ទាំង ៥ យ៉ាងនេះ និងវេរ របស់ណាមួយឲ្យយកឈ្មោះ របស់នោះ ទាំងបាលី ទាំងសម្រាយមកដាក់ ត្រង់កន្លែងវង់ក្រចកនោះ ហើយសូធ្យវេរចុះ ។

❖ *<u>ឈ្មោះសេនាសនៈផ្សេងៗដែលគួរវេរ</u>*

| | |
|---|---|
| **ឥមំ សាលំ** | នូវសាលានេះ |
| **ឥមំ កប្បិយកុដឹ** | នូវកប្បិយ កុដិនេះ |
| **ឥមំ កុដឹ** | នូវកុដិតូច ឬនូវតូបនេះ |

**ឥមំ វិហារំ** នូវកុដិធំ នេះ

**ឥមំ វច្ចកុដឹ** នូវបង្គន់នេះ

# ពាក្យវេរបិណ្ឌបាតថ្វាយចំពោះព្រះសង្ឃ

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧបាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (ភិក្ខំ) សបរិក្ខារំ សង្ឃស្ស ទេម តេគុណវន្តាទយោ ឥមំ(ភិក្ខំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ...... តតិយម្បិ......។**

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន វីចង្ហាន់បិណ្ឌបាត នៃយើងខ្ញុំព្រះករុណាទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើម យើងខ្ញុំទាំងឡាយ សូមវេរ (នូវភិក្ខា)នេះ ព្រមទាំងបរិក្ខារ ប្រគេន ដល់ព្រះសង្ឃ សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមនោះ សម្គាល់(នូវភិក្ខា) នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះបានអនុមោទនារួច ហើយ សូមឲ្យរួចរំដោះ ចាកទុក្ខទោសទាំងពួង ហើយសូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរ តាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាច ផលានិសង្ស ដែលហូរជូនទៅ មិនដាច់នេះហោង .....។

.....អស់វារៈពីរដងផង។ .....អស់វារៈបីដងផង។

# ការវេរសង្ឃទាន

វីផលទាននៃយើងខ្ញុំទាំងឡាយ ដែលបានចាត់ចែងតម្កល់ចំពោះសង្ឃ ហើយដោយប្រពៃ **ភោន្តោទេវា** យើងខ្ញុំគ្រប់គ្នា ព្រមទាំងទេវតា **អនុមោទន្តុ** សូមលោកអ្នកជ្រះថ្លា អនុមោទនានឹងទាននេះនៃ **វតនោ ទានំ** ទាននេះខ្ញុំតាំងចិត្តដោយប្រពៃ **និរាសន្ធំ** ខ្ញុំគ្មានសង្ស័យនឹងទាននេះនៃ គង់បានប្រាកដ **សង្ឃេខិណោ** ខ្ញុំសូមបង្វែរទានដ៏បរិសុទ្ធ ថ្វាយចំពោះសង្ឃ មានសីលហ្មត់ចត់ សូមឲ្យខ្ញុំបានផុត

អបាយទាំង ៤ **អាសវក្ខយា** ហើយសូមប្រាថ្នាឲ្យបានជួបជួន ទាន់ព្រះសិអារ្យមេត្រី នាំខ្លួន អាសវៈទាំង ៤ កុំបីតាមទាន់ខ្ញុំឡើយហោង ។

## បូជាព្រះបរមសារីរិកធាតុ

ព្រះតថាគត ភគវន្តមុនីអង្គឯណា ទ្រង់បានត្រាស់ហើយ(ឋិតនៅ)អស់៤៥វស្សា ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ព្រះវស្សាគត់(ឥឡូវនេះ) ខ្ញុំព្រះអង្គបានអរាធនាព្រះបរមសារីរិកធាតុនៃព្រះអង្គ មកប្រតិស្ឋានក្នុងទីចំពោះមុខ យើងខ្ញុំព្រះអង្គហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់គង់នៅព្រះធរមាននៅឡើយ ហើយដូចបានស្តេចយាងមកក្នុងទីនេះ យ៉ាងដូច្នោះដែរ យើងខ្ញុំគ្រប់ព្រះអង្គ គ្រប់ៗគ្នា សូមបូជាចំពោះ ព្រះអង្គដោយគ្រឿងសក្ការៈទាំងឡាយ ហើយសូមនមស្ការ ចំពោះព្រះអង្គដោយគោរព សូមព្រះភគវន្តមុនីសព្វញ្ញុពុទ្ធបរមលោកនាថដែលតែងតែប្រោសប្រទានសន្តិសុខ ដល់សត្វលោក ទ្រង់ព្រះមេត្តា ប្រោសទទួលនូវគ្រឿងសក្ការៈទាំងឡាយ របស់យើងខ្ញុំព្រះអង្គឱ្យបានហិតប្រយោជន៍ និង សេចក្តីសុខ សព្វកាលវេលា ជាយូរអង្វែង តរៀងទៅហោង !។

## ចែកព្រះបរមសារីរិកធាតុ

ទោណព្រាហ្មណ៍ ជាអ្នកចែកព្រះសារីរិកធាតុ ។ គេចែកព្រះធាតុជាពីរចំណែក ព្រះសារីរិកធាតុដែលនៅល្អស្អាតមិនបាក់បែក១ចំណែក ព្រះសារីរិកធាតុដែលបែកបាក់ល្អិតៗ១ចំណែក ព្រះសារីរិកធាតុដែលនៅល្អស្អាតមិនបាក់បែកនោះមាន៧ ព្រះអង្គព្រះឧណ្ហីសធាតុ(ឆ្អឹងថ្ងាស) ១, ព្រះទាឋាធាតុ(ព្រះចង្កូម)ទាំង ,ព្រះអក្ខកធាតុ(ឆ្អឹងដងកាំបិត)ទាំង ២ រួមជា ៧ ព្រះអង្គ។ ព្រះសារីរិកធាតុក្រៅពីនេះបែកចេញជាចំណែកតូចនិងចំណែកធំមានចំនួន១៦នាឡិ មានខ្នាត៣យ៉ាងៈ

**ក-ព្រះធាតុខ្នាតធំ** មានចំនួន៥ នាឡិ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ មានពណ៌ដូចមាស ។

**ខ-ព្រះធាតុខ្នាតកណ្តាល** មានចំនួន៦ នាឡិ មានទំហំប៉ុនកំណាត់គ្រាប់អង្ករមានពណ៌ដូចកែវផ្លេក(កែវផលិក) ។
**គ-ព្រះធាតុខ្នាតតូច** មានចំនួន៥ នាឡិ មានទំហំប៉ុនគ្រាប់ស្បៃមានពណ៌ដូចផ្កាថ្កុលគឺពណ៌សស្រគាំ ។
ព្រះទាឋាធាតុ(ព្រះចង្កូម) ស្តាំខាងលើប្រតិស្ឋាននៅឋានត្រៃត្រិង្ស ព្រះទាឋាធាតុ(ព្រះចង្កូម) ស្តាំខាងក្រោមប្រតិស្ឋាននៅសីហឡទ្វីប ព្រះទាឋាធាតុ(ព្រះចង្កូម) ឆ្វេងខាងលើប្រតិស្ឋានក្នុងដែនគន្ធារៈ ព្រះទាឋាធាតុ(ព្រះចង្កូម) ឆ្វេងខាងក្រោមប្រតិស្ឋានក្នុងពិភពនាគ ព្រះទុស្សធាតុ និងព្រះអក្ខកធាតុខាងឆ្វេងប្រតិស្ឋាន ប្រតិស្ឋានក្នុងព្រះសថូបកំពស់១២យោជន៍នៅឋានព្រហ្មលោក ព្រះអក្ខកធាតុខាងស្តាំប្រតិស្ឋានក្នុងថូបារាមចេតិយក្រុងអនុរាធបុរៈលង្កាទ្វីប ព្រះកេសធាតុដែលព្រះអង្គកាត់កាលទ្រង់ព្រះផ្នួស ប្រតិស្ឋានក្នុងចូឡាមណីចេតិយនាឋានត្រៃត្រិង្ស ព្រះទន្តធាតុទាំង៤០គត់ព្រះកេសធាតុ ព្រះលោមធាតុ និងព្រះនខធាតុ(ក្រចកព្រះហស្ត) ទេវតាទាំងឡាយនាំទៅនូវព្រះធាតុ ១អង្គៗទៅកាន់ចក្រវាឡដទៃ គឺព្រះធាតុមួយអង្គៗក្នុងចក្រវាឡមួយៗ ។

❋ក្នុងគម្ពីរបឋមសម្ពោធិត្រង់ធាតុវិភជ្ជនបរិវត្តន៍ប្រាប់ថា ពុទ្ធបរិក្ខារមាន១០យ៉ាងប្រតិស្ឋាននៅប្រទេសផ្សេងៗគ្នា ។

| | |
|---|---|
| ១.កាយពន្ធនិងបាត្រ | ប្រតិស្ឋាននៅនគរបាដលិបុត្រ |
| ២.សំពត់ឧទកសាដក | ប្រតិស្ឋាននៅនគរបញ្ចាលរាជ |
| ៣.សំពត់ធម្មក្ខន្ធ | ប្រតិស្ឋាននៅនគរកោសលរដ្ឋ |
| ៤.ឈើស្ទន់ | ប្រតិស្ឋាននៅនគរមិថិលា |
| ៥.សំពត់តម្រងទឹក | ប្រតិស្ឋាននៅនគរវិទេហរដ្ឋ |
| ៦.កាំបិតកោរនិងបំពង់ម្ជុល | ប្រតិស្ឋាននៅនគរឥន្ទបត្ត |
| ៧.ទ្រនាប់ព្រះបាទនិងស្លោកបាត្រ | ប្រតិស្ឋាននៅឧសសិព្រាហ្មណ៍គ្រាម |
| ៨.គ្រឿងកម្រាល | ប្រតិស្ឋាននៅមកុដនគរ |
| ៩.ត្រៃចីវរ | ប្រតិស្ឋាននៅនគរភទ្ទរដ្ឋ |
| ១០.និសីទនសន្ថ័ត | ប្រតិស្ឋាននៅនគរកុរុរដ្ឋ ។ |

កាលព្រះអង្គទ្រង់គង់ធរមាននៅ ទ្រង់ប្រតិស្ឋានស្នាមព្រះបាទទុក ៥កន្លែងគឺ

លើកំពូលភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ នៅយោនកបុរី ១នៅឆ្នេរស្ទឹងនម្មទា ១ ។

កាលព្រះពុទ្ធបរមគ្រូ ទ្រង់បរិនិព្វានហើយមានធាតុចេតិយជាដំបូង ៨កន្លែង ព្រះបាទអជាតសត្រូវសាងក្នុងនគររាជគ្រឹះ១ក្សត្រលិច្ឆវី សាងក្នុងនគរវេសាលី១ ក្សត្រសាក្យៈសាងក្នុងនគរកបិលពស្តុ១ ថូលិយក្សត្រ សាងក្នុងនគរអល្លកប្បកៈ ១ ក្សត្រកោលិយៈសាងក្នុងរាមគ្រាម ១ ព្រាហ្មណ៍អ្នកវេដ្ឋទីបកៈសាងក្នុងដែនវេដ្ឋទីបកៈ ១ពួកក្សត្រមល្លៈអ្នកក្រុងបាវា សាងក្នុងក្រុងបាវា១ ពួកក្សត្រមល្លៈអ្នកក្រុងកុសិនារា សាងក្នុងក្រុងកុសិនារា ១ ។

បើរាប់បញ្ចូលព្រះស្តូបដែលទោណព្រាហ្មណ៍ សាងក្នុងក្រុងកុសិនារាតម្កល់ ព្រះតុម្ពៈនិងព្រះស្តូបដែលពួកក្សត្រមោរិយៈ សាងក្នុងក្រុងបិប្ផលិវ័នតម្កល់ព្រះអង្គារៈ ២ផងទៀតត្រូវជា ១០កន្លែង ។

## ចេតិយ របស់ព្រះពុទ្ធជាម្ចាស់ចែកចេញជា ៤យ៉ាង

ក-ចេតិយបញ្ចុះសារីរិកធាតុ ហៅថាធាតុចេតិយ

ខ-ចេតិយបញ្ចុះគ្រឿងពុទ្ធបរិក្ខារ ហៅថាបរិភោគចេតិយ

គ-ចេតិយបញ្ចុះព្រះធម៌ មានបដិច្ចសមុប្បាទធម៌ជាដើម ហៅថា ធម្មចេតិយ

ឃ-ព្រះពុទ្ធរូបដែលគេសាងឡើង ដើម្បីស្នងព្រះសម្មាសម្ពុទ្ធកាលគង់ព្រះជន្ម នៅហៅថាឧទ្ទិស្សកចេតិយ ។

## ការផ្សាយមេត្តាទៅកាន់ទិសទាំង១០

**១-សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងកើត កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**២-សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងលិច កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៣-សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងជើង កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៤-សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងត្បូង កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៥-សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសអាគ្នេយ៍ កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៦-សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងពាយ័ព្យ កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៧-សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងឦសាន កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៨-សព្វេ ទក្ខិណាយ  អនុទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងនិរតី កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**៩-សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងក្រោម កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

**១០-សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ។**

សូមសត្វទាំងអស់ដែលនៅក្នុងទិសខាងលើ កុំបីមានពៀរ កុំបីមានព្យាបាទ កុំបីមានទុក្ខ សូមរក្សាខ្លួននៅជាសុខចុះ ។

*(បិដកលេខ៧១ ទំព័រ៩៨)*

## ការផ្សាយមេត្តាចិត្តដល់សព្វសត្វ

**១ សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបូព៌ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**២ សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអគ្នេយ៍ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**៣ សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំង
ពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**៤ សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**៥ សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**៦ សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**៧ សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**៨ សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំង
ពួង (ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**៩ សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**១០ សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ សត្តា អវេរា ហោន្តុ** សត្វទាំងឡាយទាំងពួង សូមកុំឲ្យមានពៀរនឹងគ្នា។
**សុខិតា ហោន្តុ** សូមឲ្យបាននូវសេចក្ដីសុខ
**និទ្ទុក្ខា ហោន្តុ** សូមកុំឲ្យមានទុក្ខ
**អព្យាបជ្ឈា ហោន្តុ** សូមកុំឲ្យបៀតបៀនដល់គ្នានឹងគ្នា
**អនីឃា ហោន្តុ** សូមកុំឲ្យមានសេចក្ដីព្រួយលំបាក
**ទីឃាយុកា ហោន្តុ** សូមឲ្យមានអាយុវែង
**អរោគា ហោន្តុ** សូមកុំឲ្យមានរោគ
**សម្បត្តីហិ សមិជ្ឈន្តុ** សូមឲ្យបានសម្រេច ដោយសម្បត្តិគ្រប់យ៉ាង
**សុខី អត្តានំ បរិហរន្តុ** សូមឲ្យរក្សានូវខ្លួនជាសុខចុះ
**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ** សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវ សេចក្ដី

ទុក្ខ សូមឲ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្ដីសោក សូមឲ្យជាសត្វបាត់សេចក្ដីសោកទៅហោង ។

## អធិដ្ឋានកថា

- សូមឲ្យសាសនាព្រះសម្ពុទ្ធ រុងរឿងបំផុតអស់កាលយូរ
- សូមព្រះសទ្ធម្មព្រះបរមគ្រូ ស្ថិតស្ថេរនៅយូរគ្រប់ប្រាំពាន់ឆ្នាំ
- សូមឲ្យព្រះពុទ្ធសាសនា រុងរឿងចម្រើន
- សូមឲ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសកលលោក
- សូមឲ្យលោកទាំងមូលប្រកប ដោយសន្តិភាព
- **ព្រះសក្យមុនីសម្ពុទ្ធ** ទ្រង់ត្រាស់ថា "**នត្ថិ សន្តិ បរំ សុខំ**" ពុំមាន

សេចក្ដីសុខដ៏ទៃក្រៅអំពីសេចក្ដីស្ងប់ឡើយ ។

## ពុទ្ធកាលប្បវត្តិសង្ខេប

ទ្រង់យាងចាប់បដិសន្ធិក្នុងផ្ទៃព្រះនាង សិរិមហាមាយា ជាព្រះវរមាតានៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាធ ឆ្នាំរកា នានគរកបិលពស្តុ ទ្រង់ប្រសូតនៅ ថ្ងៃសុក្រ ពេញបូណ៌មី ខែវិសាខ ឆ្នាំច វេលាថ្ងៃជិតត្រង់ ក្រោមដើមសាលព្រឹក្ស (រាំងភ្នំ) នៅក្នុងព្រៃលុម្ពិនីចន្លោះ នគរកបិលពស្តុ និង ទេវទហៈ។

## រាជវង្ស កំណើត

រាជវង្ស គោតម ព្រះរាជាបក្សសម្ព័ន្ធ សាក្យៈសោយរាជសម្បត្តិ នៅនគរកបិលពស្តុ ព្រះអគ្គមហេសីព្រះនាម **សិរិមហាមយា** ជាបុត្រីព្រះរាជាបក្សសម្ព័ន្ធកោឌយៈ នៅនគរទេវទហៈ ជាប់ព្រំដែននគរកបិលពស្តុ ព្រះនាង សិរិមហាមយា ទ្រង់បានសុបិននិមិត្តឃើញដំរីសមួយមានភ្លុក៦ ចុះពីស្ថានតុសិត ហើយចូលមកក្នុងព្រះឧទរព្រះនាងផ្នែកខាងស្ដាំ ទំនាយថាព្រះនាងនឹងមានរាជបុត្រមួយព្រះអង្គ ប្រកបដោយបុណ្យបារមីយ៉ាងលើសលុបខ្ពស់អស់សព្វសត្វទាំងពួង។

តាមរយៈគម្ពីរមហាវេស្សន្តរជាតក មានទេវបុត្រមួយព្រះអង្គ ព្រះនាម សន្តុសិតទេវបុត្រ បានយាងចុះពីឋានតុសិតមកចាប់កំណើតក្នុងផ្ទៃព្រះនាង។ ក្នុងកំឡុងដែលព្រះពោធិសត្វនៅក្នុងឧទរនៃព្រះមាតា មានទេវបុត្រ៤អង្គតែងចូលទៅរក្សាក្នុងទិសទាំង៤ ដោយគិតថា កុំអោយមានមនុស្ស និងអមនុស្សណាមួយមកបៀតបៀនព្រះពោធិសត្វ និងព្រះមាតាព្រះពោធិសត្វបានឡើយ។ ព្រះនាងមាយា បានទ្រង់គភ៌អស់ចំនួន១០ខែគត់។ ដល់គម្រប់១០ខែ គឺនៅថ្ងៃសុក្រ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំច ព្រះនាងមានព្រះរាជបំណងនឹងស្ដេចយាងទៅកាន់នគរទេវទហៈដែលជាជាតិភូមិរបស់ព្រះនាង ទើបក្រាបបង្គំទូលព្រះបាទសុទ្ធោទនមហារាជថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ប្រាថ្នានឹងទៅកាន់នគរទេវទហៈ។ គ្រានោះព្រះបាទសុទ្ធោទនៈ ទ្រង់អនុញ្ញាតិ ហើយទ្រង់ត្រាស់បង្គាប់អោយពួកសេវកាមាត្យរៀបចំក្បួនដើម្បីដង្ហែរព្រះនាងទេវី។ ទៅដល់ចន្លោះព្រំប្រទល់នគរទាំងពីរ គឺកបិលវត្ថុនិងទេវទហៈមានសាលវ័នជាមង្គលមួយឈ្មោះ លុម្ពិនីវ័ន ដែលមានផ្ការីកយ៉ាងល្អ និងហ្វូងបក្សី៥ពណ៌។ ព្រះនាងទេវីក៏ប្រាថ្នានឹងឈប់សម្រាកទីនោះ។ ខណៈដែលព្រះនាងយាងទៅដល់ក្រោមដើមសាលព្រឹក្សមួយដើម ខ្យល់កម្មជ្ជវាតក៏បណ្ដាលកម្រើកឡើងនៅក្នុងព្រះឧទរនៃព្រះនាង។ មហាជនបានជ្រាបហេតុជិតនឹងប្រសូត្រ ក៏បានរៀបចំបិទបាំងនៅក្រោមដើមនោះ ហើយថយចេញមក។ ព្រះនាងទ្រង់ឈោងចាប់មែកសាលព្រឹក្សប្រថាប់ឈរ ព្រះពោធិសត្វក៏ប្រសូត្រចាកព្រះឧទរនៃព្រះវរមាតាក្នុងវេលានោះ។

កាលដែលព្រះបរមពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ថាន (ឈរលើផែនដី) ដោយព្រះបាទជាន់ស៊ប់ ឆ្ពោះព្រះភក្ត្រទៅកាន់ទិស្សឧត្តរ ទ្រង់យាងឈានទៅបាន៧ជំហាន ក៏រមិលមើលនូវទិសទាំងពួង ទ្រង់ពោលនូវ អាសតិវាចា គឺវាចាដ៏ឧត្តមផងថាៈ

-**អគ្គោហមស្មិ លោកស្ស** អាត្មាអញជាកំពូលមនុស្សនៃលោក
-**ជេដ្ឋោហមស្មិ លោកស្ស** អាត្មាអញជាចម្បងជាងគេទាំងអស់ក្នុងលោក
-**សេដ្ឋោហមស្មិ លោកស្ស** អាត្មាអញជាបុគ្គលប្រសើរជាងគេក្នុងលោក

**-អយមន្តិមា មេ ជាតិ នត្ថិទានិ បុនព្ភវោតិ** ជាតិនេះជាជាតិចុងក្រោយបំផុតរបស់អាត្មាអញអំណរតទៅមុខ អាត្មាអញលែងកើតទៀតហើយ
ក្នុងថ្ងៃដែលព្រះពោធិសត្វប្រសូត្រនោះ ព្រះរាជទេវីពិម្ពារ១ ឆន្នអាមាត្យ១ កាឡុទាយីអាមាត្យ១ ព្រះអានន្ទ១ សេះកណ្ឋកៈ១ មហាពោធិព្រឹក្ស១ កំណប់ទ្រព្យទាំង៤រណ្តៅ១ បានកើតឡើងព្រមគ្នា។ ពួកអ្នកនគរបាននាំព្រះពោធិសត្វត្រឡប់ទៅនគរកបិលពស្តុវិញ។

## ពិធីថ្វាយព្រះនាម

ក្រោយពីព្រះរាជឱរសប្រសូតបានប្រាំថ្ងៃ ព្រះបាទសុទ្ធោទនៈបានជ្រើសរើសព្រាហ្មណ៍ដ៏ពូកែៗ ៨នាក់ ដើម្បីអោយថ្វាយព្រះ

នាម មើលនិងទាយនូវលក្ខណៈរបស់ព្រះពោធិសត្វ។ ព្រះនាមរបស់ព្រះបរមពោធិសត្វត្រូវបានជ្រើសរើសថា សិទ្ធត្ថ ដែលប្រែថា អ្នកសំម្រេចប្រយោជន៍គ្រប់យ៉ាង។ ក្រោយពីមើលលក្ខណៈព្រះពោធិសត្វរួច ឃើញថា ព្រះអង្គប្រកបដោយ មហាបុរិសលក្ខណៈ៣២ប្រការ ព្រាហ្មណ៍៧នាក់ក៏លើកម្រាមដៃពីរទាយថា បើព្រះរាជកុមារស្ថិតនៅជាក្សត្រ ព្រះអង្គនឹងបានជា
ស្តេចចក្រពត្តិ បើព្រះអង្គចេញសាងផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធ កាលនោះព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេឈ្មោះ កោណ្ឌញ្ញព្រាហ្មណ៍បានពិចារណាលើទីកន្លែងដែលទ្រង់ប្រសូត គឺនៅក្នុងឧទ្យានក៏លើកម្រាមដៃតែមួយទាយថា ព្រះរាជកុមារប្រាកដជានឹងបានត្រាស់ជាព្រះពុទ្ធ។ ក្រោយពេលព្រះអង្គប្រសូតបាន៧ថ្ងៃ ព្រះមាតាព្រះអង្គក៏សោយទីវង្គត់។ ព្រះរាជកុមារសិទ្ធត្ថ ត្រូវបានព្រះមាតុច្ឆាព្រះអង្គព្រះនាមមហាបជាបតីគោតមីបីបាច់រក្សាតមក ។

## រាជពិសេក

ព្រះសិទ្ធត្ថទ្រង់ចំរើនព្រះជន្មបាន ១៦ព្រះវស្សា ទ្រង់បានរៀប អភិសេកជាមួយបុត្រីស្តេចសុប្បពុទ្ធ ព្រះនាម ពិម្ពាយសោធរាដែលជា នារីល្អឯកលើសអស់សព្វនារី ទាំងពួង។ ដោយចង់អោយព្រះសិទ្ធត្ថក្លាយជាស្តេចចក្រពត្តិ ព្រះបិតា គឺព្រះបាទសុទ្ធោទនៈ



បានរៀបចំ ចាត់ចែងគ្រប់យ៉ាង ដើម្បីឃាឃាំងអោយព្រះសិទ្ធត្ថទ្រង់គង់នៅជាស្តេចដោយសុខសប្បាយ។ ព្រះបាទសុទ្ធោទនៈទ្រង់បានជ្រើសរើសយកតែមនុស្សក្មេងៗមកនៅបំរើព្រះពោធិសត្វ ឯមនុស្សចាស់ជរា ឈឺជាដើម ព្រះអង្គមិនអោយព្រះពោធិសត្វបានឃើញឡើយ។ ព្រះបាទសុទ្ធោទនៈទ្រង់ចាត់អោយគេសង់ប្រាសាទបី តម្រូវទៅតាមកាលរដូវទាំងបី គឺសំរាប់រដូវក្តៅ រដូវរងារ និងរដូវរំហើយ។ លុះព្រះបរមពោធិសត្វព្រះជន្មបាន២៩ព្រះវស្សា ព្រះនាងពិម្ពា ក៏ប្រសូតព្រះរាជបុត្រមួយអង្គព្រះនាម រាហុល។

## និមិត្ត៤យ៉ាង

ដោយចង់ឲ្យព្រះសិទ្ធត្ថបានជាស្តេចចក្រពត្តិ ដូចដែលព្រាហ្មណ៍ទាយទុកនោះ ព្រះសុទ្ធោទនទ្រង់ចាត់ឲ្យគេឃាមមិនឲ្យមានមនុស្សចាស់ ជរា ឈឺ ឬស្លាប់ ឲ្យព្រះសិទ្ធត្ថទ្រង់យល់ឃើញឡើយ អ្នកបម្រើភិលៀងនៅក្នុងដំណាក់របស់ព្រះអង្គមានសុទ្ធសឹងយុវវ័យទាំងអស់។ ការគង់នៅក្នុងរាជវាំង ព្រះសិទ្ធត្ថទ្រង់សោយសុខដោយកាមលោកីយគ្រប់ប្រការ។ នៅថ្ងៃមួយ ព្រះបរមពោធិសត្វទ្រង់មានព្រះទ័យអផ្សុកយ៉ាងខ្លាំង ព្រះអង្គក៏ត្រាស់ឲ្យឆន្នអាមាត្យរៀបចំក្បួនដើម្បីនឹងទៅក្រសាលឧទ្យាន។ នៅតាមផ្លូវព្រះអង្គទតឃើញបុរសចាស់ មានឆ្អឹងជំនីរដូចជាបង្កង់ មានខ្នងកោង មានឈើច្រត់ជាគ្រឿងទប់ទល់ កំពុងញាប់ញ័រក្រហល់ក្រហាយ មានវ័យកន្លងហើយ លុះព្រះពោធិសត្វឃើញហើយ ក៏សួរទៅឆន្នអាមាត្យថា បុរសនេះធ្វើដូចម្តេច បានជាសក់គាត់មិនដូចជាសក់អ្នកឯទៀត ទាំងកាយគាត់ក៏មិនដូចកាយអ្នកដទៃដែរ។ ឆន្នអាមាត្យក៏ក្រាបបង្គំទូលថា បពិត្រព្រះអង្គ នេះគេហៅថា បុរសចាស់ តពីនោះគាត់នឹងមិនរស់នៅយូរប៉ុន្មានទេ។ ទោះព្រះអង្គក៏គង់នឹងចាស់ជាធម្មតា មិនអាចកន្លងសេចក្តីចាស់ទៅបានទេ។ កាលកន្លងទៅ ព្រះអង្គក៏យាងក្រសាលឧទ្យានម្តងទៀត។ ព្រះអង្គបាន

ទតឃើញបុរសមានអាពាធដល់នូវសេចក្ដីទុក្ខ ឈឺធ្ងន់ ដេកត្រាំក្នុងទឹកមូត្រនិងលាមក របស់ខ្លួន មានជនទាំងឡាយដទៃលើកឲ្យក្រោកឡើង ផ្ដេកឲ្យដេក លុះទតឃើញ ហើយ ព្រះអង្គក៏សួរទៅឆន្នអាមាត្យថា បុរសនេះធ្វើដូចម្ដេច បានជាភ្នែករបស់គាត់មិន ដូចជាភ្នែកអ្នកដទៃ ក្បាលក៏មិនដូចជាក្បាលអ្នកដទៃ។ ឆន្នអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនេះហៅថា បុរសឈឺ។ បុរសនេះមិនអាចនឹងរួចពីជំងឺបាន ឡើយ ទោះព្រះអង្គក៏នឹងមានជំងឺជាធម្មតា មិនអាចកន្លងសេចក្ដីឈឺចាប់បានឡើយ។ ថ្ងៃបន្ទាប់ក្រោយមក ព្រះពោធិសត្វក៏ទៅក្រសាលឧទ្យានទៀត។ ម្ដងនេះ ព្រះអង្គបាន ទតឃើញបុរសស្លាប់ ក៏ត្រាស់សួរឆន្នអាមាត្យ នោះជាអ្វី។ ឆន្នអាមាត្យក្រាបទូលថា បពិត្រព្រះអង្គ ព្រោះបុរសនោះហៅថាធ្វើមរណកាលហើយ។ ញាតិទាំងឡាយនឹងមិន ឃើញបុរសនោះទៀតឡើយ ទាំងបុរសនោះសោតក៏លែងបានឃើញញាតិទាំងឡាយ របស់គាត់ដែរ។ ទោះបីព្រះអង្គក៏នឹងធ្វើមរណកាលដូចគ្នា មិនអាចកន្លងសេចក្ដីស្លាប់ បានឡើយ។ ព្រះបរមពោធិសត្វក៏មានសេចក្ដីសង្វេគជាខ្លាំង សញ្ជប់សញ្ជឹងគិតថា ជរា ព្យាធិ និងមរណា តែងមានប្រាកដដល់សត្វលោក។

ទ្រង់សង្វេគក្នុងព្រះទ័យ ថ្ងៃកន្លងមកបន្ទាប់ព្រះអង្គក៏ទៅក្រសាលឧទ្យានម្ដងទៀត។ ព្រះពោធិសត្វបានទតឃើញបុរសមានសីសៈរលីង ជាអ្នកបួស ស្លៀកដណ្ដប់សំពត់កា សាវព្រស្ដ លុះឃើញហើយ ក៏សួរឆន្នអាមាត្យ បុរសនេះធ្វើដូចម្ដេច បានជាក្បាល របស់គាត់មិនដូចក្បាលអ្នកដទៃ ទាំងសំពត់របស់គាត់ ក៏មិនដូចរបស់អ្នកដទៃ។ ឆន្នអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះគេហៅថា អ្នកបួស។ បុរសនោះ ប្រព្រឹត្តធម៌ដោយប្រពៃ មិនបានបៀតបៀន តែងអនុគ្រោះដល់សត្វដទៃ។ ព្រះអង្គក៏ ពិចារណាថា អ្នកបួសគឺជាការស្រួលណាស់ព្រោះមិនបៀតបៀនគេ តែងអនុគ្រោះ ដល់គេ។ នៅក្នុងរាជវាំង ព្រះអង្គទ្រង់ទតឃើញជារឿយៗ ភិលៀង អាមាត្យ ទាំងឡាយដេកលក់ ខ្លះហៀរទឹកមាត់ ខ្លះរបូតសំពត់អាវ នៅស្ដូកស្ដឹងគ្មានវិញ្ញាណដូច ជាអង្កត់ឈើមួយដុំ ធ្វើឲ្យព្រះអង្គទ្រង់មានការសង្វេក និងគិតដល់និមិត្តទាំង៤ដែល ព្រះអង្គទតឃើញ។ ព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាដល់សមណអ្នកបួសយ៉ាងស្រគត់ ស្រគមគួរជាទីជ្រះថ្លានៃសត្វលោកទាំងឡាយ ព្រះអង្គក៏មានសទ្ធាពេញព្រះហរទ័យ ត្រេកអរជាក្រៃពេក ក៏គិតនឹងចេញសាងផ្នួស។

# សាងផ្នួស



ទ្រង់យាងសាងព្រះផ្នួសក្នុងព្រះជន្ម ២៩ឆ្នាំ ព្រះសិទ្ធត្ថ គោតមមានការនឿយណាយខ្ពើមរអើមរូបសង្ខារ និងលោកសន្និវាសនេះ យ៉ាងខ្លាំងហើយព្រះអង្គសព្វព្រះហរទ័យដោះស្រាយបញ្ហាជិវិតដោយការចេញសាងព្រះផ្នួស ដើម្បីស្វែងរកនូវព្រះសម្មាសម្ពោធិញាណធម៌ ។ កណ្តាលរាត្រីស្ងាត់ព្រះសិទ្ធត្ថ ចូលទៅបបោសអង្អែលរាហុលបុត្រាជាទីស្រលាញ់ ងាកបែរសម្លឹងទៅភរិយា**ពិម្ពា**កំពុងលង់លក់ក្នុងបន្ទំ មានដំណាលថា ទេវតានៅស្ថានតុសិតបានចុះមកជួយព្រះសិទ្ធត្ថដោយធ្វើអោយព្រះនាងពិម្ពា និងរាហុល លង់លក់ក្នុងបន្ទំយ៉ាងស៊ប់ ដើម្បីកំអោយភ្ញាក់ធ្វើការរំខានដល់ការសម្រេចចិត្ត របស់ព្រះអង្គ ហើយជប់សេះរាជរដ្ឋ ជូនដំណើរព្រះសិទ្ធត្ថទៅដល់ព្រៃទៅហោង។ ព្រះអង្គទ្រង់ដកព្រះខ័នចាប់ក្តាប់កោរព្រះកេសា ហើយអធិដ្ឋានថា «បើអាត្មាអញនេះ ពិតជាបានត្រាស់ជាព្រះពុទ្ធ មែន ចូរកេសាទាំងឡាយនៃអាត្មាអញនេះឈប់ដុះតទៅទៀតចុះ» អធិដ្ឋានហើយព្រះសិទ្ធត្ថទ្រង់បាច ព្រះកេសាទាំ ងឡាយឡើងទៅលើអាកាស ហ្វូងទេវតាទាំងឡាយកាន់ភាជន៍មាស មកទទួលត្រងយកទៅទុកនៅស្ថានទេវលោ កក្នុងគ្រានោះទៅ។

កោណ្ឌញ្ញព្រាហ្មណ៍ គឺព្រាហ្មមួយអង្គក្មេងជាងគេ ដែលកាលធ្វើពិធីថ្វាយព្រះនាមបានទាយថាព្រះអង្គពិតជាបានត្រាស់ដឹងជាព្រះពុទ្ធនោះ កាលបើដឹងថាព្រះសិទ្ធត្ថចេញសាងផ្នួសហើយ ក៏មានសទ្ធាជ្រះថ្លារួមជាមួយសមណៈព្រាហ្មណ៍៤ អង្គទៀតចេញ ទៅបួសតាមបំរើព្រះអង្គដែរ អ្នកបួសទាំង៥នាក់នោះហៅថា បញ្ចវគ្គិយ៍ភិក្ខុ។

# ធ្វើទុក្ករកិរិយា



ការធ្វើទុក្ករកិរិយារបស់ព្រះពុទ្ធកាលបានបួសស្រេចបាច់អស់ហើយ ព្រះសិទ្ធត្ថ គោត្តម ទ្រង់បានចូលទៅធ្វើការសិក្សាធម៌ក្នុងសំណាក់ព្រាហ្មណ៍តាបស ពីរព្រះអង្គ មាននាមថា អាឡារតាបស១ និង ឧទកតាបស១ ដោយយល់ថាក្នុងសំណាក់តាបសទាំងពីរព្រះអង្គ ពុំអាចស្វែងរក សម្មាសម្ពោធិញាណនៃការត្រាស់ដឹងបាន ព្រះអង្គក៏បានសម្រេចព្រះទ័យលាចាកតាបសទាំងពីរ ហើយស្វែងរកសច្ចៈធម៌ដោយព្រះអងឯងវិញ។ ព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា គឺការប្រតិបត្តិធម៌យ៉ាងតឹងរឹងធ្វើអោយមានការពិបាក ដល់រូបកាយយ៉ាងក្រៃលែង ដូចជាមានការអត់អាហាររហូតរូបរាងកាយស្គាំស្គមជាខ្លាំង ការប្រព្រឹត្តទុក្ករកិរិយា អស់រយពេល៦ព្រះវស្សា ព្រះអង្គក៏នៅតែស្វែងរកសច្ចៈធម៌ពុំបានឡើយ។ មានដំណាលថា មានទេព និម្មិតបានមកដេញពិន ថ្វាយអោយព្រះអង្គទ្រង់បានសន្តាប់ ដំបូងខ្សែពិនដែលធូរដេញទៅពុំធ្វើអោយមានការពីរោះទេ ទើបអ្នកដេញចាប់ផ្តើមរឹតខ្សែរពិណហើយចាប់ផ្តើមដេញម្តងទៀតដោយខ្សែពិណ រឹតតឹងពេកគ្រាន់តែកេះទឹង ខ្សែរពិណដាច់បាត់តែម្តងទៅ។ ទេពនិម្មិតជាអ្នកដេញពិណរៀបចំដាក់ខ្សែរពិណជាថ្មី ហើយរៀបរិតអោយត្រូវ មិនតឹងពេក មិនឲ្យធូរពេក លុះរៀបចំបានត្រូវហើយ ទើបចាប់ដេញបានជាភ្លេងយ៉ាងពីរោះថ្វាយព្រះអង្គទ្រង់បានសន្តាប់ ព្រះសិទ្ធត្ថ គោត្តម ទ្រង់ពិចារណាប្រៀបធៀបការប្រព្រឹត្តប្រតិបត្តិដោយយកពិធីដេញពិនជាគោលឃើញថា ការធ្វើប្រតិបត្តអោយតឹងរ៉ឹងពេកក៏ជាហេតុមិនអាចនាំមកនូវការ ត្រាស់ដឹងបានឡើយ ហើយការប្រព្រឹត្ត ប្រតិបត្តិតឹងរ៉ឹងពេកធ្វើ

អោយដាច់ ក៏ជាហេតុមិនអាចអោយព្រះអង្គត្រាស់ដឹងបានឡើយ។ លុះទ្រង់ពិចារណាហេតុផលដូចនេះ ហើយទើបព្រះអង្គទ្រង់លះបង់ការធ្វើទុក្ករកិរិយាចោល ហើយចាប់ផ្ដើមសោយ អាហារជាធម្មតាវិញ។ ព្រះបញ្ចវគ្គិយ៍ ភិក្ខុឃើញដូចនោះ ក៏គិតគ្នាថា អោ!.ព្រះសិទ្ធត្ថ គោតម អស់សេចក្ដីព្យាយាមហើយតើ ព្រះអង្គមិនអាចត្រាស់ដឹងជាព្រះពុទ្ធបានឡើយ ហើយក៏បបួលគ្នាឈប់ តាមបំរើព្រះអង្គទៀតតាំងពីនោះមក។

## ត្រាស់ដឹង



ក្រោយពីលះបង់ចោលការធ្វើទុក្ខរៈកិរិយា ព្រះសិទ្ធត្ថក៏ចាប់ផ្ដើមប្រព្រឹត្តប្រតិបត្តិតាមបែបមជ្ឈិមបដិបទាវិញ ព្រះ អង្គទ្រង់យ៉ាងទៅកាន់ រដ្ឋមគធ ក្នុងស្រុកពោធិគយា ទ្រង់យាងទៅដល់មាត់ស្ទឹងនរញ្ជរ ដ៏មានទឹកថ្លាគួរជា ទីស្នាក់អា ស្រ័យនៃសមណៈទាំងឡាយ ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្សមួយខាងលិចស្ទឹង បែរព្រះភក្ដទៅទិសបូព៌ទ្រង់យក ស្បូវភ្លាំងដែលសាត្ថិយ កុមារប្រគេននៅតាមផ្លូវ ទៅក្រាលធ្វើជាកំរាលគង់ពីលើ មានសេចក្ដីដំណាលថា រតនបល្ល័ង្ក មួយកំពស់១៤ហត្ថ ផុសទ្រព្រះអង្គពីក្រោម ព្រះសិទ្ធត្ថទ្រង់គង់ភ្នែនពែនព្រះបាទលើរតនបល្ល័ង្កដោយសុខស្រួល ហើយតាំងអារម្មណ៍អធិដ្ឋានដោយអង្គថា៖ «ស្បែក សរសៃ សាច់ និង ឈាម របស់អាត្មាអញ ចូររីងស្ងួតចុះ បើអា ត្មាអញមិនបានសម្រេចការត្រាស់ដឹងទេ អាត្មាអញនឹងមិនក្រោក ចាកពីរតនបល្ល័ង្កនេះឡើយ»។ ព្រះអង្គទ្រង់ចាប់ផ្ដើ មចំរើន អានាបានុស្សតិធ្វើព្រះចិន្ដាអោយស្ងប់ចាកនីវរណធម៌ទាំង ឡាយ ហើយទ្រង់បានសម្រេចឈានជាលំ

ដាប់។ ទ្រង់សញ្ជឹងគិតឃើញនូវស្ទឹងសង្ខារខន្ធ និងសញ្ញាខន្ធ ដែលហូរតាមបណ្ដោយស្ទឹងរូបខន្ធ និងវិញ្ញាណខន្ធ ទ្រង់ឆ្វេង យល់ឃើញ សត្វលោកកំពុងជាប់ជំពាក់គ្មានទីបញ្ចប់ នូវទុក្ខវេទនា ក៏ព្រោះតែការភ័ន្តច្រលំនៃសញ្ញាខន្ធរបស់គេ មនុស្សម្នាក់ៗមានជំនឿថា អ្វីៗដែលជារបស់មិនទៀងទាត់ ថាជារបស់ទៀងទាត់ អ្វីៗដែលមិនមែនរបស់ខ្លួន អនត្តា ថាជារបស់ខ្លួន ព្រះអង្គទ្រង់បានបញ្ចេញអោយឃើញ នូវការយល់ដឹងរបស់ព្រះអង្គចំពោះភាវៈខាងគំនិតប្រាជ្ញាដែល ជាប្រភពនៃសេចក្ដីទុក្ខ ដូចជាការភ័យខ្លាច ខឹង ស្អប់ ក្រអឺតក្រអាង ច្រណែន ប្រចណ្ឌ លោភ និងល្ងង់ខ្លៅជាដើម។ សេចក្ដីទុក្ខប្រភេទនេះ មានភាពផ្ទុយស្រលះ និងការពិចារណាដ៏ត្រឹមត្រូវ ព្រះអង្គទ្រង់ឆ្វេងយល់យ៉ាងច្បាស់ថា ប្រ ភពទុក្ខទាំងឡាយពិតជាកើតឡើងដោយសារអវិជ្ជា។ ដើម្បីរំដោះសេចក្ដីទុក្ខនេះ ត្រូវទំលុះនូវអវិជ្ជា ហើយរុលចូល ជ្រៅទៅក្នុងបេះដូងរបស់វា និងវែករក បុព្វហេតុ នៃសេចក្ដីពិតនៃស្ទឹងទាំង៥គឺ៖

- **រូបខន្ធ ១**
- **វេទនាខន្ធ ១**
- **សញ្ញាខន្ធ ១**
- **សង្ខារខន្ធ ១**
- **វិញ្ញាណខន្ធ ១**

ឥឡូវនេះព្រះអង្គទ្រង់បានយល់ច្បាស់ថា ភាពពិតមិនស្ថិតស្ថេរ អនិច្ចំ និងភាពមិនមែនជារបស់ខ្លួន អនត្តា គឺចាកលក្ខខណ្ឌចាំបាច់នៃជីវិត បើគ្មានធម៌ អនិច្ចំ និងអនត្តាទេ ក៏គ្មានអ្វីអាចកើតឡើងចំរើនលូតលាស់បានឡើយ។

## ផ្ចាញ់មារ

បុត្រីមារ មកផ្ចាញ់ព្រះពេលព្រលប់ព្រះសិទ្ធត្ថ ទ្រង់គង់លើរតនបល្ល័ង្កក្រោមពោធិព្រឹក្ស ទ្រង់បានផ្ចាញ់មារដែល នាំកូនស្រីក្រមុំទាំង ៣ នាក់គឺ តណ្ហា,អរតី និង រាគា មកបញ្ចូលចិត្តព្រះសមណគោតម ដើម្បីឲ្យព្រះអង្គលះបង់ការស្វែងរក ការត្រាស់

ដឹងចោលតែ ព្រះបរមពោធិសត្វពុំមាការ ចាប់រម្មណ៍ឡើយ ធ្វើឲ្យនាងទាំង ៣ វិនាសអន្តរធានទៅ ។ បន្ទាប់ពីទទួលបរាជ័យក្នុងការបញ្ចុះបញ្ចូលចិត្តព្រះ**សមណគោតម** មកមារក៏នៅតែមានចិត្តឫស្យាចង់ផ្ចាលផ្ចាញ់ព្រះអង្គទៀត មារបានលែងកងទ័ពបិសាចកាចសាហាវតូចធំទាំងឡាយជាច្រើនឲ្យមកច្បាំងដណ្តើមយកបល្ល័ង្កពីព្រះអង្គទៀត។ មារជិះលើដំរីឈ្មោះ គ្រីមេខលា កំពស់ ១៥០ យោជន៍



(១ យោជន៍មាន ១៦ គីឡូម៉ែត្រ)និមិត្តដៃមួយពាន់កាន់នូវគ្រឿងសាស្ត្រាវុធគ្រប់ប្រការ មានតំណាលថា មារបានបញ្ចេញកងពលសេនាដ៏ច្រើនតាន់តាប់ មកពីមុខកំរាស់ ១២ យោជន៏ ខាងឆ្វេងស្តាំ កំរាស់១២យោជន៍ ខាងលើ៩យោជន៍។ ទេវតាទាំងឡាយដែលជានាក់ថៃរក្សាព្រះអង្គ មានសក្កទេវរាជមហាព្រហ្ម ស្តេចនាគកាលបានបញ្ចេញឫទ្ធធ្វើឲ្យកងពលរបស់មារខ្លបខ្លាចរត់ប្រាសអាយុរៀងៗខ្លួន។ កងពលមារមួយកងទៀតលើកមកពីទិសឧត្តរ មារាធិរាជដែលភ័យញញើតស្រែកប្រាប់ពលរេហ៍ថា នែពួកយើង សិទ្ធត្ថនេះមានរិទ្ធបារមីខ្លាំងពូកែណាស់ ចូរពួកយើងកុំចូលមកចំពីមុខ។ មារចាប់ថ្លែងសរឲ្យកើត ជាខ្យល់ព្យុះដែលមានកម្លាំងបោកបក់ភ្នំឲ្យរលំបាន តែខ្យល់នោះមិនបានធ្វើអោយកំរើកសូម្បីតែជាយស្បង់ចីវរព្រះ អង្គបន្តិចឡើយ មារបង្កើតឲ្យមាន ភ្លៀង រន្ទះ ផ្លេកបន្ទោរ ភ្លើង ភក់ក្តៅ ងងឹត សូន្យសុងពីគ្រប់ទិសទី និងគ្រឿងប្រហារផ្សេងៗ បាចសាចមកលើព្រះអង្គ តែគ្រឿងប្រហារទាំងនោះមិនបានបៀតបៀនអ្វីដល់ព្រះអង្គឡើយ តែក្លាយទៅជាគ្រឿងសក្ការបូជាព្រះអង្គទៅវិញ។ ឃើញដូចនោះ មារាធិរាជក៏បរដំរីដៃកាន់អាវុធ ១ ពាន់ចូលទៅជិតព្រះអង្គស្រែកគំរាមថា៖ «នែសិទ្ធត្ថ! ចូរអ្នកដើរចេញពីរតនបល្លង្កនេះភ្លាមទៅ រតនបល្លង្កនេះរបស់យើង»

ព្រះសមណគោតមទ្រង់ត្រាស់ពោលទៅកាន់មារវិញថា «ម្នាលមារ រតនបល្លង្កនេះ កើតមកមិនមែនសំរាប់រូបអ្នកទេ គឺពិតជាកើតមកសំរាប់យើង ដែលជាអ្នកបំពេញនូវបារមីទេតើ អ្នកមិនមែនជាអ្នកបំពេញបារមីទេ ចូរថយចេញភ្លាមទៅ»។ ក្រុងមាររឹតតែខឹងខ្លាំងឡើង ហើយក៏គ្រវែងចក្រាវុធ ដ៏មានមុខស្រួចសំដៅព្រះអង្គចក្រាវុធនោះក៏ក្លាយជាពិដានការពារព្រះអង្គទៅវិញ រីឯក្រុមរេហ៍ពល ដែលដកភ្នំគ្រវែងមកលើព្រះអង្គពេលនោះដែរ តែភ្នំទាំងនោះក្លាយជាកំរងផ្កាបូជាព្រះអង្គទៅវិញ។
ដោយទ័លគំនិត មិនដឹងនឹងរកអ្វីតទល់យកឈ្នះលើព្រះអង្គបាន មារសំឡុតព្រះអង្គថា តើព្រះអង្គមានភស្តុតាងគុណធម៌អ្វីជាអាង។ ព្រះពុទ្ធធ្វើការត្រិះរិះថា រតនបល្ល័ង្កតែងកើតមានដល់ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះ អង្គ ហើយរតន
បល្ល័ង្កនេះកើតឡើងចំពោះអាត្មាអញ ហើយក៏សំរាប់តែអាត្មាអញតែម្នាក់ប៉ុណ្ណោះទ្រង់ព្រះចិន្តាដូចនេះហើយក៏សួរទៅមារវិញថា «ម្នាលមារ បើរតនបល្ល័ង្កនេះជារបស់អ្នក តើអ្នកមានអ្វីជាសាក្សី » ក្រុងមារឆ្លើយតបដោយខែងវែងថា «ពលរេហ៍យើងទាំងអស់នេះជាបន្ទាល់» ចុះសិទ្ធត្ថ ឯងវិញ មានអ្វីជាសាក្សី ។ ព្រះសមណគោតមទ្រង់លើក ព្រហស្តស្តាំ ចង្អុរព្រះធរណី និងអំពាវនាវប្រាប់ធរណី ឲ្យជួយធ្វើសាក្សី ទទួលដឹង លឺនូវអំពើល្អរបស់ព្រះអង្គ ព្រះអង្គទ្រង់ត្រាស់ថា ក្រឡាមហារប្រថពីនេះហើយជាសាក្សីរបស់យើង។ សមុទ្រ ឬកាយវិការនៃព្រះហស្តនេះគឺ «ការផ្ចាញ់មារ» រឺថា «ការយកព្រះធរណីធ្វើ ជាសាក្សី» គ្រាន់តែមានព្រះបន្ទូលដូច្នេះ មហាប្រថពីក៏លាន់រញ្ជួយកក្រើកឡើង ទទួលខ្លួនជាសាក្សីបន្ទល់ចំពោះព្រះអង្គ ក្នុងគ្រានោះព្រះអង្គទ្រង់នឹកដល់ដំរី បច្ច័យនាគេន្ទ ដែលព្រះអង្គទ្រង់ប្រទានដល់អ្នកស្រុក
**កលិង្គរាស្ត្រ** កាលព្រះទ្រង់សោយព្រះជាតិជា វេស្សន្តពោធិសត្វ គ្រានោះដំរីគ្រីមេខលា ដែលជាអតីតជាតិ ជានាគេន្ទនោះ ក៏ឱនក្បាល លុតជង្គង់ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព រីនាងគង្ហីងព្រះធរណីបានចេញមក ហើយយកដៃច្បូតសក់ហូរចេញជាទឹកក្លាយជាសមុទ្រ លេចពលរេហ៍មហាមារអស់ជាច្រើន។ មហាមារឃើញដូច្នោះហើយក៏ក្រាបថ្វាយបង្គំព្រះអង្គដោយសរសើរថា «បពិត្រមហាបុរស អ្នកជាអ្នកមានញាណញេយ្យដ៏អស្ចារ្យមែន យើងខ្ញុំព្រះករុណាសូមនមស្សការដោយគោរព»។

ព្រលឹមអរុណរះ ព្រះនាងសុជាតាបានរៀបចំម្ហូបអាហារ ដើម្បីយកទៅថ្វាយបូជា ដល់ដើមពោធិព្រឹក្សដែលព្រះនាងបានធ្វើការបន់ស្រន់សុំរាជបុត្រនៅទីនោះ មកដល់ដើមពោធិព្រឹក្ស ព្រះនាងទ្រង់យល់ឃើញព្រះសម្មាសម្ពុទ្ធត្រេកអរប្រកបដោយ សទ្ធាជ្រះថ្លាជាក្រៃពេក ហើយបានថ្វាយ មធុបាយាស ឲ្យដឹកភាជន៍មាសដល់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ពូតមធុបាយាស ជា ៧ពុំនូតហើយទ្រង់សោយ ទ្រង់បានយកភាជន៍មាសគ្រវែងចូលទៅក្នុងគង្គារ ដែលលិចទៅបះទង្គិចភាជន៍មាសនៃព្រះពុទ្ធអង្គមុនៗ ធ្វើអោយនាគរាជដែលកំពុងដេកលក់ភ្ញាក់ឡើងហើយប្រកាសថា អោ! មានព្រះពុទ្ធត្រាស់មួយអង្គទៀតហើយតើ! ព្រះសមណៈ សិទ្ធត្ថ គោតម បានត្រាស់ជាព្រះពុទ្ធនៅថ្ងៃពុធ ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥ វស្សា។

## បឋមទេសនា



ព្រះពុទ្ធទ្រង់ទេសនាពន្យល់បញ្ញវគ្គីយ៍ជាមិត្តសំឡាញ់ព្រះពុទ្ធទ្រង់ត្រាស់ថា សភាវៈធម៌របស់តថាគតនេះរមែងមិនញុំាងសត្វទាំងឡាយណាដែលជិតជាប់កាមអោយត្រាស់ដឹងបានឡើយ តថាគត នឹងមិនធ្វើការប្រៀនប្រដៅ ដល់សត្វលោកដោយប្រការ យ៉ាងនោះឡើយ។ គ្រានោះសហម្បតី ព្រហ្មជាតសីលោកា ទ្រង់ចូលគាល់ព្រះសាស្តាអោនសិរសីលើដៃបង្គំ អារាធនាអោយព្រះអង្គទ្រង់ប្រោស ប្រណីដល់សត្វនានា ព្រះពុទ្ធក៏ទ្រង់

អនុគោល យល់ព្រមទទួលសំដែង ធម៌ទេសនាអោយសត្វលោកដោយ ករុណាតាំងពីពេល នោះមក ។ ព្រះពុទ្ធទ្រង់និមន្តទៅកាន់ក្រុងពារាណសី ចូលទៅព្រៃឥសិបតនមិគទាយវន ជាទីស្នាក់អាស្រ័យនៃបញ្ចវគ្គិយ៍ភិក្ខុ ភិក្ខុ៥អង្គបាន ឃើញព្រះពុទ្ធទ្រង់យាងមកពីចំងាយ ក៏ជំនុំប្រាប់គ្នាថា យើងទាំងឡា យចូរកុំធ្វើគារវបង្គំព្រះសិទ្ធត្ថ ដែលអស់សេចក្តីព្យាយាមរលីងហើយ នោះអោយសោះ តែដោយអំណាចបុណ្យបារមីនៃព្រះអង្គ ពេលដែល ព្រះពុទ្ធទ្រង់យាងមកដល់ បញ្ចវគ្គិយ៍ ទាំងប្រាំបែរជាក្រាបបង្គំនិមន្តព្រះតថាគតដោយជ្រះថ្លាក្រៃលែងទៅវិញ។ ព្រះអង្គទ្រង់សន្តោសប្រោសទេសនាធម្មចក្រកប្បវត្តនសូត្រ ដែលហៅថា បឋមទេសនាប្រោសដល់បញ្ចវគ្គីយ៍បានសម្រេចសោតាបត្តិមគ្គក្នុងគ្រានោះឯង ។ តាំងពីពេលនោះមកមានមនុស្សជាច្រើនបានចូលទៅបួសរៀនក្នុងសំណាក់ព្រះអង្គ ហើយបានសម្រេចមគ្គផលទៅតាមការគួររៀងៗខ្លួន ។ ព្រះអង្គទ្រង់យាងទៅកាន់ក្រុងកបិលពស្តុ ចូលទៅកាន់សំណាក់ព្រះបាទសុទ្ធោទន បិតានិង ព្រះនាងពិម្ពាយ ជាព្រះជយា។ ព្រះនាងពិម្ពាទ្រង់បង្គាប់អោយរាហុល បុត្រចូលទៅ សុំចែកទ្រព្យសម្បត្តិពីសំណាក់ បិតា ព្រះពុទ្ធក៏ទ្រង់បំបួសរាហុលជា សាមណេរ តាំងពីពេលនោះមក។

## ពុទ្ធកិច្ច

ព្រះសម្មាសម្ពុទ្ធទ្រង់បំពេញពុទ្ធកិច្ច ៥ប្រការជានិច្ចអស់រយៈពេល ៤៥វស្សាគឺ៖

- **ពេលព្រលឹម** ទ្រង់និមន្តបិណ្ឌបាត
- **ពេលរសៀល** ទ្រង់សំដែងធម៌ទេសនាប្រោសដល់សាធារណជន។
- **ពេលព្រលប់** ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃទាំងឡាយ។
- **ពេលអធ្រាត្រ** ទ្រង់ដោះស្រាយប្រស្នាទេវតាទាំងឡាយ។
- **ពេលជិតភ្លឺ** ទ្រង់ប្រមើមើលសត្វលោកដែលមាននិស្ស័យ និងឥតនិស្ស័យ។

## ដាក់ព្រះជន្ម

ពេលចេញវស្សាទី៤៥ ក្នុងព្រះជន្មាយុ ៨០ព្រះវស្សា នាថ្ងៃ ១៥កើតពេញបូណមីខែមាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ដា ក់អាយុ ដោយប្រាប់មារថា ព្រះអង្គនឹងចូលបរិនិព្វាន

ក្នុងរយពេលបីខែទៀត ។ ព្រះភិក្ខុសង្ឃទាំងឡាយជាសាវ័ក ជាពិ សេសគឺ ព្រះអានន្ទ ជាអ្នកបំរើព្រះអង្គផ្ទាល់ កាលបើដឹងថាព្រះពុទ្ធបានកំណត់អាយុសង្ខាររួចទៅហើយ ក៏ យំសោក ស្តាយអាយុសង្ខារព្រះអង្គយ៉ាងខ្លាំង មិនទាន់ចង់អោយព្រះអង្គចូលបរិនិ ព្វានឡើយ។

## បរិនិព្វាន



(ព្រះពុទ្ធទ្រង់ចូលបរិនិព្វាន)

ក្រោយពេលដាក់ព្រះជន្មរួច ហើយ ព្រះអង្គទ្រង់និមន្តទៅ បិណ្ឌបាតគ្រប់ទិសទី ហើយ នៅទីបំផុតព្រះអង្គទ្រង់យាង ទៅដល់នគរកុសិនារា ព្រះ អង្គទ្រង់ប្រឈួនយ៉ាងខ្លាំង ក្រោយពីបាន សោយសាច់ ជ្រូកដែលប្រគេនដោយនាយចុន្ទៈ ទ្រង់យាងចូល ទៅដល់ព្រៃសាលវន្ត ហើយទ្រង់ ត្រាស់អោយអានន្ទ រៀបកន្លែង ថ្វាយព្រះអង្គផ្ទុំព្រះអង្គទ្រង់ផ្ទុំផ្អៀង ទៅខាងស្តាំ ព្រះបាទឆ្វេងត្រួតលើ ព្រះបាទស្តាំ ពេលបច្ចឹមរាត្រីព្រះ អង្គទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា *«អ្វីៗដែលកើតមានហើយ ផ្តុំឡើង ហើយ តែងមានសភាវៈធម៌ និងរលត់ទៅវិញជាធម្មតា អ្នកទាំងឡាយចូរញ៉ាំង ប្រយោជន៍អោយសំរេចដោយកិរិយាមិនប្រមាថចុះ»* ព្រះពុទ្ធទ្រង់មានពុទ្ធដិការតែ ប៉ុណ្ណោះ ព្រះអង្គក៏ទ្រង់រលត់ខន្ធក្នុងពេលនោះទៅ។ ព្រះពុទ្ធទ្រង់ចូលបរិនិព្វាននៅ ថ្ងៃ អង្គារ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ ៥៤៣ មុនគស ក្នុងព្រះជន្ម ៨០ព្រះ វស្សា។

**កំណត់សម្គាល់** ៖ រឿងនិទានអំពីការផ្ចាញ់មារ គ្រាន់តែជាវិធីប្រៀបធៀបឲ្យអ្នកស្តា ប់ និង អ្នកអានងាយយល់ អត្ថន័យនៃទស្សនវិជ្ជាផ្លូវចិត្ត ដែលមនុស្សសាមញ្ញពិបាក

យល់ ។ អ្នកនិពន្ធសាច់រឿងនោះ បានលើកយកតួអង្គមារ និង បុត្រទាំង ៣ ធ្វើជាតំណាងឲ្យដួងចិត្តអាក្រក់របស់បុគ្គលម្នាក់ៗ ដែលប្រយុទ្ធតស៊ូជាមួយនឹងដួងចិត្តល្អនៅចំពោះមុខរាល់ការសម្រេចចិត្តទាំងអស់ ។ មិត្តអ្នកអានជ្រាបហើយថា គ្មានតួអង្គមារ ឬ បុត្រីរបស់មារ ឬ កងទ័ពរបស់មារ ពិតប្រាកដទេ ប៉ុន្តែពួកវាគឺជាចិត្តដែលច្បាំងគ្នានៅក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗ នៅគ្រប់វិនាទី ។

*(ដកស្រង់ចេញពីសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ ១៩)*

## ព្រះបឋមឧទាន

(ព្រះវាចាជាដំបូង)

- **អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
  **គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ។**
  **គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
  **សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
  **វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា។**

កាលតថាគតមិនទាន់បានជួបប្រទះ(**ពោធិញ្ញាណ**) វង្វេងតែស្វះស្វែងរកជាងផ្ទះគឺតណ្ហា, អ្នកធ្វើផ្ទះគឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើតទុក្ខជារឿយៗ ។

នែជាងផ្ទះ! អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះរបស់(តថាគត)ទៀតមិនបានឡើយ ឆ្អឹងជំនីគឺ កិលេស របស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ, ដំបូលផ្ទះគឺ អវិជ្ជា តថាគតកាច់បំបាក់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ, តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ។

---

*(សុតន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា ជរាវគ្គ បិ.៥២,ទំ. ៥៤)*

# មជ្ឈិមពុទ្ធវចនៈ

មជ្ឈិមពុទ្ធវចនៈ គឺព្រះវាចាជាកណ្តាលរាប់ចាប់ពីចន្លោះកណ្តាលវស្សានៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ។

**កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ។**

- ☞ ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ
- ☞ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ
- ☞ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ
- ☞ ការកើតនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ

# របៀបសំពះខ្មែរ

ខ្មែរលើកដៃសំពះ ដោយលើកដៃទាំងពីរ ផ្គុំគ្នាជារាងក្រពុំឈូក ដោយសារប្រជាជនខ្មែរ គោរពប្រតិបត្តិព្រះពុទ្ធសាសនា។ វប្បធម៌ខ្មែរយើងការសំពះមាន៤របៀបគឺ៖

១.សំពះកម្ពស់ត្រឹមដើមទ្រូង

មនុស្សដែលមានវ័យ ឬបុណ្យសក្តិស្មើគ្នា ឬជាមិត្តភក្តិ គេគប្បីលើកដៃសំពះគ្នាទៅវិញទៅមក ដោយដាក់ដៃត្រឹមដើមទ្រូង។




២.សំពះកម្ពស់ត្រឹមមាត់

អ្នកដែលមានឋានៈតូច ឬអាយុតិច សំពះអ្នកដែលមានឋានៈខ្ពស់ ឬអ្នកមានអាយុ

ច្រើនជាង គប្បីលើកដៃប្រណមដោយចុងម្រាមនៅត្រឹមមាត់ ឯអ្នកដែលមានឋានៈខ្ពស់ឬអាយុច្រើន ត្រូវសំពះតបវិញដោយប្រណមដៃកម្ពស់ដើមទ្រូង។




៣.សំពះកម្ពស់ត្រឹមចុងច្រមុះ

កូនសំពះឪពុកម្តាយ ចៅសំពះយាយ សិស្សសំពះគ្រូ គប្បីលើកដៃឡើង ហើយដាក់ម្រាមដៃត្រឹមចុងច្រមុះ។

៤.សំពះកម្ពស់ចិញ្ចើម

សម្រាប់ថ្វាយបង្គំព្រះសង្ឃ វត្ថុសក្តិសិទ្ធិ ថ្វាយបង្គំព្រះមហាក្សត្រ។




---

# ឧទ្ទិសកថា

សូមឧទ្ទិសថ្វាយព្រះរាជមហាកុសលដល់មន្ត្រីជាន់ខ្ពស់ គ្រប់ព្រះអង្គ សម្មតិសង្ឃ អរិយសង្ឃ មហាវីរៈក្សត្រ ព្រះអយ្យកោ និងលោកមេទ័ព គ្រប់ជំនាន់ទាំងអស់ ជីដូន ជីតា និងញាតិទាំងឡាយ សត្តនិករ ក្នុងលោកសន្និវាសយើងនេះ និងសព្រហ្មចារី

ទាំងអស់ សូមនិមន្ត ស្តេចយាង និងអញ្ជើញមកអនុមោទនាផលធម្មទាន សូមនិមន្ត ស្តេចយាង និងអញ្ជើញមកអនុមោទនាផលបុណ្យ សូមនិមន្ត ស្តេចយាង និងអញ្ជើញមកអនុមោទនាមហាកុសល សូមអនុមោទនា ។

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។**

ទាននេះចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបានដល់នូវសេចក្តីសុខចុះ ។

**កុសលផលបុណ្យ** ដែលកើតឡើងអំពី "**ធម្មទាន**" នេះខ្ញុំសូមឧទ្ទិសជូនចំពោះលោក-អ្នកដ៏មានគុណទាំងឡាយមាន មាតា បិតា ជីដូន-ជីតា បុព្វការីជន គ្រូឧបជ្ឈាយាចារ្យព្រមទាំងញាតិកាក្នុងសង្សារវដ្តទាំងអស់ សូមលោក អនុមោទនា ត្រេកអរចំពោះបុណ្យកុសលចេតនា និង បុញ្ញកិរិយានេះ លុះបានអនុមោទនារួចហើយ សូមបានប្រកបដោយសម្មាទិដ្ឋិ មានបញ្ញាយល់ឃើញត្រូវ សម្រេចនូវ សេចក្តីសុខ តាមគន្លងមាគ៌ានៃ "**ព្រះធម៌ព្រះសម្មាសម្ពុទ្ធ**" ចុះ ។

**ឥទំ មេ បុញ្ញំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ**

របុណ្យដែលកើតឡើងអំពីកម្លាំងសទ្ធា-កុសលចេតនាក្នុងធម្មទាននេះ សូមឱ្យបានជាបច្ច័យនាំមកនូវធម៌ជាទីអស់ទៅនូវអាសវក្កិលេស សន្សំឧបនិស្ស័យចេញចាកវដ្តៈ និងការបដិបត្តិរួចចាកទុក្ខបានដល់ត្រើយនាយ ពោលគឺ **ព្រះនិព្វាន** ឮដ៏អនាគតកាល កុំបីឃ្លៀងឃ្លាតឡើយ ។

---

(ចប់ធម៌នមស្ការព្រះបរមសារីរិកធាតុតែប៉ុណ្ណេះ)

# បរាភវសូត្រ

បទបឋ្យាវត្ត

(ទេវតាទូលសួរព្រះសាស្តាថា)

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ ចម្រើនវិនាស
ប្រុសស្រីក្នុងលោក- សន្និវាស ដែលនឹងវិនាស សាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោតម ព្រះអង្គមានបុណ្យ មេត្តានិមន្ត សម្តែងឲ្យទាន
ធម្មជាតិដូចម្តេច ដែលជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

(ព្រះសាស្តា ឆ្លើយតបនឹងទេវតាថា)

**សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**
**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។**

អ្នកដែលចម្រើន តថាគតស្គាល់ងាយ អ្នកដែលអន្តរាយ តថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្ត នឹងបានចម្រើន ។
អ្នកដែលទ្រុស្តធម៌ ស្អប់ធម៌ឥតកើន ឥតកើនចម្រើន វិនាសទៅមុខ ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**
**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី២ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

**អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ**
**អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស
តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្រ ។
សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្រ អសប្បុរស

គាប់ចិត្តក្នុងធម៌ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**
**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី២ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។**

អ្នកដេកច្រើន១ និយាយច្រើន១ និងអ្នកឥតព្រួយ ឥតគិតប្រឹងប្រែង
អ្នកខ្ជិលប្រអូស មិនមានខ្នះខ្នែង ខឹងច្រើនសម្តែង ឲ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះ មិនជាកល្យាណ នាំឲ្យខកខាន ខាតខូចប្រយោជន៍
មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍ ហើយឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ**
**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៣ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី ៤ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

**យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។**

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា
មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**
**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៤ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

**យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ**
**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូម ឬអ្នកដទៃៗ
ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃ សេចក្តីវិនាស ។

**ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**
**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៥ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី ៦ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

**បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**
**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។**

បុរសអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ
លបលាក់របស់ ដែលឆ្ងាញ់ពិសា ស៊ីម្នាក់ឯងជា ប្រធានវិនាស ។

**ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**
**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៦ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ**
**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល សាច់ញាតិសន្តាន

មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្ដីវិនាស ។

**ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ**
**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៧ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន វិនាសទី ៨ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។

**ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ**
**លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ។**

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ ធ្វើទ្រព្យខ្លួនមាន ឲ្យអន្ដរាយ ការល្បែងទាំងឡាយ នោះនាំវិនាស ។

**ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ**
**នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៨ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា ទ្រុស្តនឹងប្រពន្ធ កូនជននានា ហេតុនោះទៅជា នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៩ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន

វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។

**អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ**

**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្ដីតណ្ហា

នាំយកស្រីក្មេង មកធ្វើភរិយា ហេតុនោះទៅជា នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ**

**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១០ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន

វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។

**ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**

**ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។**

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ តាំងបុរសនោះ

ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះ នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**

**ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១១ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន

វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។

**អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**

**សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។**

ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកក្សត់សម្បត្តិ ហើយប្រាថ្នាធំ

ចង់បានជាស្ដេច សោយរាជ្យស្ដុកស្ដម្ភ ហេតុនោះនឹងនាំ ឲ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**

**អរិយទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។**

ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ នៃហេតុវិនាស
ដល់សត្វក្នុងលោក- សន្និវាស គេចពីវិនាស គប់រកចម្រើន ។

**បរាភវសុត្តំ និដ្ឋិតំ**

*បរាភវសូត្រ ចប់ ។*

---

*សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ (សៀវភៅលេខ ៥៤ ទំព័រទី ៣៦)*

## គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**សព្វញ្ញូសិ មហាវីរ លោកជេដ្ឋ នរាសភ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក
ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ ។ (បិដកភាគ៧៤ ទំព័រ១៩)

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**ពហុជ្ជនំ តារយសិ ទេសេន្តោ អមតំ បទំ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ
ព្រះអង្គកាលសម្តែងនូវអមតៈបទ គឺព្រះនិព្វានញុំាងជនដ៏ច្រើន
ឲ្យឆ្លងវដ្តទុក្ខបាន ។ (បិដកភាគ៧៣ ទំព័រ១៨៨)

**រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ**
**វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ ។**

ព្រះអង្គមិនមានបុគ្គលស្មើ ក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង
ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិធម៌
និងការញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ។ (បិដកភាគ៧៧ ទំព័រ១៣)

**លាភាលាភេ ន សជ្ជន្តិ សម្មាននេ វិមានតេ**

**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឲ្យផ្តាំផ្គង នឹងព្រះពុទ្ធទាំងនោះឡើយ ។ (បិដកភាគ៧២ ទំព័រ១០៨)

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលណាមួយ ប្រៀបផ្ទឹមស្មើនឹងព្រះអង្គបានឡើយ ។ (ពុទ្ធប្បវត្តិកថា)

**តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ**

**សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ ។**

ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាសាស្តាចារ្យ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់គ្របសង្កត់នូវពួកមារ ព្រះអង្គជាអ្នកកាត់ផ្តាច់នូវអនុស័យក្កិលេស ទ្រង់ឆ្លងផុតចាកសង្សារហើយ សូមទ្រង់ចម្លងនូវខ្ញុំព្រះអង្គជាសត្វផង ។ (ពុទ្ធប្បវត្តិកថា)

( **ចប់** )

# សន្លឹកប្រាប់ពាក្យខុសត្រូវ

| ទំព័រ | ឈ្មោះធម៌ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

| | | | |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |